CDRI

Cambodia Development Resource Institute

# យុវជន និងមនុស្សជំនាន់មុននៅកម្ពុជា៖ ទំនាក់ទំនងរវាងទាំងពីរជំនាន់ និងទស្សនៈសង្គម និងនយោបាយ

អេង-នេត្រា អាង-ឡែន សូ-ហេងវត្តី ហាវ-ហ្គិចហុង ផុំ-ធាវី

ឯកសារពិភាក្សាលេខ ១១៦

ខែមីនា ឆ្នាំ២០១៩

ឯកសារបោះពុម្ពផ្សាយរបស់វិទ្យាស្ថាន CDRI

ឯកសារពិភាក្សាលេខ ១១៦

# យុវជន និងមនុស្សជំនាន់មុននៅកម្ពុជា៖ ទំនាក់ទំនងរវាងទាំងពីរជំនាន់ និងទស្សនៈសង្គម និងនយោបាយ

អេង-នេត្រា អាង-ឡែន សូ-ហេងវត្តី ហាវ-ហ្គិចហុង ឆំ-ឆាវី

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ភ្នំពេញ ខែមីនា ឆ្នាំ២០១៩

© ២០១៩ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ-CDRI)
រក្សាសិទ្ធិគ្រប់យ៉ាង

ISBN-13: 978-9924-500-11-7

**យុវជន និងមនុស្សជំនាន់មុននៅកម្ពុជា៖ ទំនាក់ទំនងរវាងទាំងពីរជំនាន់ និងទស្សនៈសង្គម និងនយោបាយ**

**សូមយោងឯកសារនេះថា៖**

Eng Netra, Ang Len, So Hengvotey, Hav Gechhong, Chhom Theavy. 2019. *Cambodia's Young and Older Generation: Views on Generational Relations and Key Social and Political Issues.* CDRI Working Paper Series No. 116. Phnom Penh: CDRI.

**វិទ្យាស្ថាន** CDRI
អគារលេខ ៥៦ ផ្លូវលេខ ៣១៥ ខណ្ឌទួលគោក ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
ទូរស័ព្ទ៖ +៨៥៥២៣ ៨៨១៣៨៤, ៨៨១៧០១, ៨៨១៩១៦, ៨៨៣៦០៣
ទូរសារ៖ +៨៥៥២៣ ៨៨០៧៣៤
អ៊ីមែល៖ cdri@cdri.org.kh http://www.cdri.org.kh

កែសម្រួល និងរចនាដោយ៖ អ៊ុំ ចាន់ថា និង យូ សិទ្ធីរិទ្ធ
បោះពុម្ពនៅប្រទេសកម្ពុជាដោយ GIM printing រាជធានីភ្នំពេញ

# មាតិកា


បញ្ជីរូបភាព និងតារាង ... v
សេចក្តីថ្លែងអំណរគុណ ... vi

១. សេចក្តីផ្តើម ... 1
២. របកគំហើញសំខាន់ៗ និងអនុសាសន៍គោលនយោបាយ ... 3
៣. វិធីសាស្រ្តអង្កេត ... 9
៤. ការពិភាក្សាលទ្ធផលអង្កេត ... 12
   ៤.១. ស្ថានភាពសេដ្ឋកិច្ចសង្គម ... 12
   ៤.២. ទំនាក់ទំនងរវាងមនុស្សជំនាន់មុន និងយុវជននៅក្នុងគ្រួសារ ... 17
   ៤.៣. ឥរិយាបថចំពោះសមភាពយេនឌ័រ ការផ្សារភ្ជាប់ និងការគោរព របកគំហើញសំខាន់ៗ ... 21
   ៤.៤. ការជឿទុកចិត្ត ... 26
   ៤.៥.ការយល់ដឹងផ្នែកនយោបាយ ... 28
   ៤.៦. ការចូលរួមនៅកម្រិតមូលដ្ឋាន ... 31
   ៤.៧. ការវាយតម្លៃស្ថាប័នថ្នាក់ជាតិ ... 36
   ៤.៨. ការទទួលបាននិងការប្រើប្រាស់ព័ត៌មាននយោបាយ ... 38
   ៤.៩. អាទិភាព និងការរំពឹងទុកទៅអនាគត ... 43

ការស្ទង់មតិអំពីការចូលរួមរបស់ប្រជាពលរដ្ឋក្នុងសង្គម ... 48
បញ្ជីឯកសារពិភាក្សារបស់វិទ្យាស្ថាន CDRI ... 61

# បញ្ជីរូបភាព និងតារាង


រូបភាព១: ចំនួនសំណាកគំរូភូមិតាមខេត្តធៀបនឹងចំនួនភូមិនិងប្រជាជនសរុប ........ 9
រូបភាព២: សំណាកគំរូយេនឌ័រ និងប្រជាជនសរុបតាមអាយុ ........ 11
រូបភាព៣: ស្ថានភាពគ្រួសារ ........ 14
រូបភាព៤: អ្នកឆ្លើយសម្ភាសន៍រស់នៅជាមួយសមាជិកគ្រួសារ ........ 14
រូបភាព៥: តើអ្នកធ្លាប់ធ្វើចំណាកស្រុកដើម្បីស្វែងរកការងារដែរឬទេ? ........ 14
រូបភាព៦: តើអ្នកប្រើប្រាស់អ៊ិនធើណិតដែរឬទេ? ........ 16
រូបភាព៧: តើមនុស្សជំនាន់អ្នកខុសពីមនុស្សជំនាន់មុនដែរឬទេ? ........ 17
រូបភាព៨: តើអ្នកយល់ស្របនឹងប្រយោគដែរថា មានទស្សនៈនយោបាយផ្ទាល់ខ្លួនគឺជារឿងសំខាន់? ........ 19
រូបភាព៩: តើអ្នកយល់ស្របចំពោះទស្សនៈដែរថាយុវជនអាចជំទាស់ជាមួយឪម្តាយ? ........ 19
រូបភាព១០: តើអ្នកយល់ស្របនឹងប្រយោគដែរថា ការសិក្សានៅមហាវិទ្យាល័យរបស់មនុស្សប្រុសសំខាន់ជាងការសិក្សានៅមហាវិទ្យាល័យរបស់មនុស្សស្រី? ........ 22
រូបភាព១១: តើអ្នកយល់ស្របនឹងប្រយោគដែរថា យេនឌ័រជាឧបសគ្គដល់ភាពជោគជ័យរបស់អ្នកទេ? ........ 22
រូបភាព១២: តើអ្នកយល់ស្របនឹងប្រយោគដែរថា បុរសសមជាអ្នកដឹកនាំជាងស្ត្រីទេ? ........ 23
រូបភាព១៣: តើអ្នកយល់ស្របនឹងប្រយោគដែរថា ដៃគូរស្នេហាអាចរស់នៅជាមួយគ្នាបានមុនពេលអាពាហ៍ពិពាហ៍? ........ 23
រូបភាព១៤: តើអ្នកគិតគូរពីប្រទេសជាតិកម្រិតណា? ........ 24
រូបភាព១៥៖ តើអ្នកមានការផ្សារភ្ជាប់នឹងសាសនាជិតស្និទ្ធប៉ុណ្ណា? ........ 24
រូបភាព១៦: តើអ្នកមានភាពជិតស្និទ្ធនឹងសហគមន៍កម្រិតណា? ........ 25
រូបភាព១៧: តើអ្នកគោរពមេឃុំរបស់អ្នកដែរឬទេ? ........ 26
រូបភាព១៨: តើអ្នកអាចរៀបរាប់ឈ្មោះអ្នកនយោបាយបីនាក់បានទ (ដោយមិនរួមបញ្ចូលនាយករដ្ឋមន្ត្រី)? ........ 29
រូបភាព១៩: តើស្ថាប័នកំពូលទាំងបីមានអ្វីខ្លះ? ........ 29
រូបភាព២០: តើអ្នកយល់ស្របជាមួយនឹងការលើកឡើងដែរថា ខ្ញុំមានកាតព្វកិច្ចទៅបោះឆ្នោត? ........ 30
រូបភាព២១: តើអ្នកយល់ស្របជាមួយនឹងការលើកឡើងដែរថា សន្លឹកឆ្នោតរបស់ខ្ញុំអាចមានឥទ្ធិពលដល់អនាគតប្រទេសជាតិរបស់ខ្ញុំ? ........ 30
រូបភាព២២: តើអ្នកធ្លាប់ចូលរួមសកម្មភាពនៅថ្នាក់មូលដ្ឋាន? ........ 32
រូបភាព២៣: បើធ្លាប់ចូលរួម តើអ្នកធ្លាប់បញ្ចេញយោបល់ក្នុងពេលប្រជុំ? ........ 33
រូបភាព២៤: តើអ្នកមានការបារម្ភដែរឬទេនៅពេលបញ្ចេញមតិក្នុងសកម្មភាពឬ ប្រជុំ? ........ 34
រូបភាព២៥: តើឃុំ/សង្កាត់គួរធ្វើគម្រោងថ្មីដែលគាត់មិនទាន់បានធ្វើដែរឬទេ? ........ 34
រូបភាព២៦៖ តើឃុំ/សង្កាត់គួរផ្តល់គម្រោងអភិវឌ្ឍន៍អ្វីខ្លះ? ........ 35
រូបភាព២៧: តើអ្នកយល់ស្របនឹងប្រយោគដែរថាប្រទេសយើងដើរលើផ្លូវត្រឹមត្រូវ? ........ 36
រូបភាព២៨: តើអ្នកយល់ស្របនឹងប្រយោគដែលថា ស្ថានភាពសេដ្ឋកិច្ចកម្ពុជាបច្ចុប្បន្នភាគច្រើនមានភាពល្អប្រសើរជាង៥ ឆ្នាំមុន? ........ 36
រូបភាព២៩: តើអ្នកយល់ស្របនឹងប្រយោគខាងក្រោមដែរថារាជរដ្ឋាភិបាលបានជួយ (បញ្ហាខាងក្រោម) គ្រប់គ្រាន់ដែរឬទេ? ........ 38
រូបភាព៣០: តើអ្នកមានការបារម្ភក្នុងការស្វែងរកព័ត៌មាននយោបាយក្នុងអ៊ិនធើណិតដែរឬទេ? ........ 41
រូបភាព៣១: តើអ្នកយស់ស្របនឹងប្រយោគដែរថាអ្នកមានការបារម្ភក្នុងការបញ្ចេញទស្សនៈនយោបាយក្រៅប្រព័ន្ធអ៊ិនធើណិត? ........ 41

រូបភាព៣២: តើអ្នកយល់ស្របនឹងប្រយោគដែរថា អ្នកមានការបារម្ភក្នុងចែករំលែកព័ត៌មាននយោបាយ និងការបញ្ចេញមតិយោបល់រឿងនយោបាយតាមប្រព័ន្ធអ៊ិនធើណិត? ....... 42
រូបភាព៣៣: នៅក្នុងទស្សនៈរបស់អ្នកតើអាទិភាពជីវិតខាងក្រោមនេះមានសារៈសំខាន់កម្រិតណា? ....... 44
រូបភាព៣៤: ចំពោះទស្សនៈរបស់អ្នក តើអ្នកកំណត់លំដាប់លំដោយអាទិភាពសម្រាប់អភិវឌ្ឍន៍ប្រទេសជាតិកម្រិតណា? ....... 45
រូបភាព៣៥: ចំពោះទស្សនៈរបស់អ្នក តើអ្នកកំណត់លំដាប់លំដោយអាទិភាពសម្រាប់អភិវឌ្ឍន៍ប្រទេសជាតិកម្រិតណា? ....... 45
រូបភាព៣៦: ចំពោះទស្សនៈរបស់អ្នក តើអ្នកកំណត់លំដាប់លំដោយអាទិភាពសម្រាប់អភិវឌ្ឍន៍ប្រទេសជាតិកម្រិតណា? ....... 46
រូបភាព៣៧: តើអ្នកមានទស្សនៈសុទិដ្ឋិនិយមកម្រិតណាចំពោះអនាគតរបស់ខ្លួនអ្នកផ្ទាល់ និងចំពោះប្រទេសជាតិ?....... 47
រូបភាព៣៨: តើអ្នកមានទស្សនៈសុទិដ្ឋិនិយមកម្រិតណាចំពោះប្រទេសជាតិ?....... 47

# បញ្ជីតារាង

តារាង១: ព័ត៌មានសំណាកគំរូភូមិអង្កេត ....... 10
តារាង២: សំណាកគំរូសម្រាប់អង្កេតប្រជាជនតបសម្ភាសន៍ ....... 10
តារាង៣: ស្ថានភាពសេដ្ឋកិច្ចសង្គមអ្នកឆ្លើយសម្ភាសន៍ ....... 12
តារាង៤: កម្រិតបញ្ចប់ការសិក្សា ....... 13
តារាង៥: ប្រភេទមុខរបរ....... 15
តារាង៦: តើអ្នកមានឧបករណ៍ប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានដូចខាងក្រោមនេះដែរឬទេ? ....... 16
តារាង៧: តើអ្នកណាខ្លះគួរមានសិទ្ធសំរេចចុងក្រោយលើបញ្ហារបស់យុវជន? ....... 18
តារាង៨: ចំណាត់ថ្នាក់អាទិភាពជីវិតរបស់យុវជន ....... 20
តារាង៩: ចំណាត់ថ្នាក់អាទិភាពជីវិតរបស់មនុស្សជំនាន់មុន....... 20
តារាង១០: ក្នុងរយៈពេល១ខែកន្លងទៅ តើអ្នកធ្លាប់ចូលរួមសកម្មភាពមួយណាខ្លះដូចខាងក្រោម(%)? ....... 20
តារាង១១: តើបុគ្គល/ស្ថាប័នណាដែលអ្នកជឿទុកចិត្ត? ....... 27
តារាង១២: តើបុគ្គល/ស្ថាប័នណាដែលអ្នកជឿទុកចិត្ត?....... 27
តារាង១៣: តើអ្នកទុកចិត្តបុគ្គលខាងក្រោមកម្រិតណា?....... 28
តារាង១៤: តើអ្នកទុកចិត្តបុគ្គលខាងក្រោមកម្រិតណា? ....... 28
តារាង១៥: តើនរណាដែលអ្នកគិតថាមានឥទ្ធិពលលើទស្សនៈនយោបាយរបស់អ្នក? ....... 31
តារាង១៦: តើអ្នកធ្លាប់ចូលរួមសកម្មភាពនៅថ្នាក់មូលដ្ឋានណាខ្លះ?....... 33
តារាង១៧: តើស្ថាប័នរដ្ឋណាខ្លះដែលអ្នកពេញចិត្តជាងគេចំពោះការអនុវត្តការងារ (%)?....... 38
តារាង១៨៖ តើអ្នកពេញចិត្តជាងគេនឹងការអនុវត្តការងារស្ថាប័នរដ្ឋណាខ្លះ (%)? ....... 38
តារាង១៩: តើអ្នកទទួលព័ត៌មាននយោបាយពីប្រភពណាខ្លះ? ....... 40
តារាង២០: តើអ្នកប្រើប្រាស់អ៊ិនធើណិតសម្រាប់គោលបំណងអ្វីខ្លះ? ....... 40
តារាង២១: តើអ្នកចែកចាយព័ត៌មាននយោបាយដោយរបៀបដូចម្តេចខ្លះ និងជាមួយនរណាខ្លះ? ....... 43

# សេចក្តីថ្លែងអំណរគុណ

អង្កេតនេះ អាចធ្វើទៅបានដោយមានការជួយជ្រោមជ្រែងពី អ្នកពាក់ព័ន្ធជាច្រើននាក់ដែលមិនអាចរៀបរាប់ឈ្មោះទាំងអស់ក្នុងរបាយការណ៍នេះ។ វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) សូមអរគុណជាអនេកដល់ការគាំទ្រ និងការផ្តល់មតិយោបល់របស់អ្នកចូលរួមទាំងអស់។ CDRI សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ អ្នកឆ្លើយសម្ភាសន៍ដែលបានចំណាយពេលវេលាចូលរួមផ្តល់ព័ត៌មានក្នុងអង្កេតនេះ។ CDRI សូមអរគុណដល់អាជ្ញាធរមូលដ្ឋាន មានថ្នាក់ ភូមិ ឃុំ ស្រុក និង ខេត្ត ដែលបានផ្តល់ការគាំទ្រ ការជួយសម្របសម្រួល និងកិច្ចសហការ។ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ ជំនួយគាំទ្រដែលក្រសួងមហាផ្ទៃផ្តល់ឲ្យដល់ក្រុមសិក្សាស្រាវជ្រាវ។

CDRI សូមថ្លែងអំណរគុណដល់ បណ្ឌិត ហ្វ្រង់ស៊ីសហ្កូបាលូ (Dr Francesco Bailo) នៃសកលវិទ្យាល័យស៊ីដនី (University of Sydney) នៃប្រទេសអូស្ត្រាលី ដែលបានជួយផ្តល់មតិលើផែនការសិក្សាស្រាវជ្រាវ វិធីសាស្ត្រជ្រើសរើសសំណាកគំរូ ការកែតម្រូវទិន្នន័យ និងការវិភាគទិន្នន័យ។ យើងខ្ញុំសូមថ្លែងអំណរគុណដល់ការជួយជ្រោមជ្រែងពីលោកស្រី ប៉ុន ដូរីណា អ្នកសម្របសម្រួលតាមមូលដ្ឋាន និង លោក កែរ បុប្ផា អ្នកគ្រប់គ្រងទិន្នន័យ និងសហការីនៅ CDRI។ យើងខ្ញុំសូមអរគុណសម្រាប់ការចូលរួមយ៉ាងសកម្ម និងការរួមចំណែករបស់គ្រប់ភាគីពាក់ព័ន្ធ ដល់ការសិក្សាស្រាវជ្រាវនេះ។

ជាទីបញ្ចប់ យើងខ្ញុំសូមថ្លែងអំរណគុណយ៉ាងជ្រាលជ្រៅដល់ ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត (Sida) ដែលបានផ្តល់ជំនួយគាំទ្រផ្នែកហិរញ្ញវត្ថុ ធ្វើឲ្យការសិក្សានេះអាចដំណើរបានយ៉ាងរលូន។

# ១. សេចក្តីផ្តើម

យុវជនមានដល់ ៣៣% នៃប្រជាជនសរុប។ ពាក្យ "យុវជន" និង "ប្រជាជនវ័យក្មេង" ក្នុងរបាយការណ៍នេះ សំដៅលើមនុស្សមានអាយុចាប់ពី ១៦ ដល់ ៣០ឆ្នាំ គិតត្រឹមឆ្នាំ២០១៧។ យុវជនទាំងនេះ កើតក្រោយសម័យខ្មែរក្រហម និងមានចំណែកកាន់តែធំឡើងក្នុងចំណោមអ្នកបោះឆ្នោតនៅកម្ពុជា។ អ្នកទាំងនោះ បានចាប់កំណើតនៅពាក់កណ្តាល និងចុងទសវត្សរ៍ទី៩០ ដែលជាសម័យទើបចាប់ផ្តើមធ្វើកំណែទម្រង់ និងមានការរៀបចំបោះឆ្នោតថ្នាក់ជាតិលើកដំបូងក្នុងឆ្នាំ១៩៩៣ ដោយមានការគាំទ្រពីអង្គការសហប្រជាជាតិ។ យុវជនមួយក្រុមទៀតបានចាប់កំណើតនៅចុងទសវត្សរ៍ទី៩០ និងដើមទសវត្សរ៍ទី២០ ក្នុងអំឡុងពេលដែលប្រទេសកម្ពុជាទទួលបានសន្តិភាពពេញលេញ បន្ទាប់ពីមរណភាពរបស់ ប៉ុល ពត ក្នុងឆ្នាំ១៩៩៨ និងនៅពេលដែលកម្ពុជា បានធ្វើសមាហរណកម្មចូលទៅក្នុងទីផ្សារក្នុងតំបន់ និងក្នុងពិភពលោក។

យុវជនរស់នៅក្នុងសម័យមួយដែល ប្រទេសកម្ពុជាមានការរីកលូតលាស់សេដ្ឋកិច្ច និងការផ្លាស់ប្តូរសង្គមយ៉ាងលឿន។ ប្រទេសកម្ពុជារក្សាបានកំណើនសេដ្ឋកិច្ចជាមធ្យម ៧,៩% ក្នុងមួយឆ្នាំ ក្នុងចន្លោះពេលពីឆ្នាំ២០០០ ដល់ ២០១៥។កំណើននេះធ្វើឱ្យគេចាត់ថ្នាក់ប្រទេសកម្ពុជាចូលក្នុងចំណោមបួនប្រទេសដែលមានសេដ្ឋកិច្ចលូតលាស់លឿនបំផុតនៅតំបន់អាស៊ីអាគ្នេយ៍។ តាំងពីមានការបោះឆ្នោតរៀបចំឡើងដោយអង្គការសហប្រជាជាតិក្នុងឆ្នាំ១៩៩៣ មក ទឹកដីភាគច្រើននៃប្រទេសកម្ពុជាមានសន្តិភាព និងមានការពង្រឹងអភិបាលកិច្ចស្ថាប័ន ដែលមានទាំងការបោះឆ្នោតនៅថ្នាក់ក្រោមជាតិ និងការពង្រឹងការផ្តល់សេវាដោយស្ថាប័នរដ្ឋ។

"មនុស្សចាស់" ឬ "មនុស្សជំនាន់មុន" ជាប្រជាជននៅរស់មានអាយុច្រើនជាង ៣០ឆ្នាំ។ មនុស្សជំនាន់មុនបានឆ្លងកាត់សម័យ រាជានិយម ខ្មែរក្រហម និងសង្គមនិយម។ មនុស្សជំនាន់មុន មានបទពិសោធន៍ខុសប្លែកពីយុវជន ព្រោះយុវជនបានធំពេញវ័យ ក្នុងបរិបទមានការបោះឆ្នោតជាទៀងទាត់តាមប្រព័ន្ធពហុបក្ស និងមានប្រជាជនចូលរួមកម្រិតខ្ពស់ក្នុងដំណើរការបោះឆ្នោត។ យុវជនក៏ដើរតួនាទីសំខាន់ក្នុងដំណើរការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងនយោបាយដែរ។ ប៉ុន្តែកន្លងមកពុំទាន់មានអង្កេតណាមួយដែលបានប្រមូល និងវិភាគទិន្នន័យលើយុវជន ដោយផ្តោតលើ ស្ថានភាពសេដ្ឋកិច្ចសង្គម តម្លៃសីលធម៌ អាទិភាព ទំនុកចិត្ត ឥរិយាបថនយោបាយ និង ទំនាក់ទំនងរវាងយុវជននឹងមនុស្សជំនាន់មុន ក្នុងបរិបទ គ្រួសារ សហគមន៍ ស្ថាប័នថ្នាក់មូលដ្ឋាន និងស្ថាប័នថ្នាក់ជាតិ។

របាយការណ៍នេះធ្វើវិភាគលើ លទ្ធផលនៃអង្កេតដែលមានលក្ខណៈតំណាងឲ្យ ទូទាំងប្រទេស។ របាយការណ៍នេះជាលទ្ធផលនៃការសិក្សាដំបូងក្នុង កម្មវិធីសិក្សាស្រាវជ្រាវរយៈពេល៥ឆ្នាំ នៃគម្រោង *ពន្លក* ដែលអនុវត្តឡើងដោយផ្នែកអភិបាលកិច្ច នៃវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) ដោយមានការគាំទ្រពីទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត (Sida)។ គម្រោង *ពន្លក* ធ្វើការសិក្សាលើយុវជនដែលជាប្រជាជនជំនាន់ថ្មី ព្រមទាំងលើឥទ្ធិពល និងសារៈសំខាន់របស់យុវជន ក្នុងដំណើរការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងនយោបាយនៅកម្ពុជា។

របាយការណ៍ផ្អែកលើអង្កេតនេះ បានយកទៅចែករំលែកយ៉ាងទូលំទូលាយដល់តួអង្គ និងស្ថាប័នពាក់ព័ន្ធសំខាន់ៗ ហើយវិទ្យាស្ថាន CDRI ក៏មានបោះពុម្ពផ្សាយនូវ អត្ថបទខ្លីៗបង្ហាញពីរបកគំហើញសំខាន់ៗ នៅក្នុង *ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* របស់ CDRI ដែរ។

ការសិក្សាស្រាវជ្រាវបន្តទៀតក្នុងគម្រោងពន្លក ផ្តោតលើប្រធានបទគន្លឹះថ្មីៗពាក់ព័ន្ធនឹងយុវជន រួមមាន៖ ១. ការវិភាគយេនឌ័រផ្អែកតាមទិន្នន័យអង្កេត ២. ការវិភាគពីគម្លាតរវាងជនបទនឹង ទីប្រជុំជន ៣. ការវិភាគស៊ីជម្រៅលើទំនុកចិត្តរវាងយុវជននឹងមនុស្សជំនាន់មុន និង ៤. ការវិភាគពីការចូលរួមរបស់យុវជនក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងមូលដ្ឋាន។ របាយការណ៍ពីការសិក្សាទាំងបួននេះ នឹងមានបោះពុម្ពផ្សាយនៅឆមាសទី២ ឆ្នាំ២០១៩។

## ទម្រង់របាយការណ៍

ក្នុងផ្នែកបន្ទាប់ពីនេះ មានការបង្ហាញដោយសង្ខេបពី របកគំហើញសំខាន់ៗនៃរបាយការណ៍ និងការពិចារណាពីផលពាក់ព័ន្ធសម្រាប់គោលនយោបាយ។ វិធីសាស្ត្រនៃអង្កេតនេះ មានរៀបរាប់ដោយសង្ខេបក្នុងផ្នែកទី៣។ បន្ទាប់មកទៀត របាយការណ៍មានរៀបរាប់ពី លទ្ធផលលំអិតនៃអង្កេត ដោយបែងចែកតាម ៩ប្រធានបទ គឺ៖

- ស្ថានភាពសេដ្ឋកិច្ចសង្គម
- ទំនាក់ទំនងរវាងមនុស្សជំនាន់មុន នឹងយុវជននៅក្នុងគ្រួសារ
- ឥរិយាបថចំពោះសមភាពយេនឌ័រ ការផ្សារភ្ជាប់ និងការគោរព
- ការជឿទុកចិត្ត
- ការយល់ដឹងផ្នែកនយោបាយ
- ការចូលរួមនៅកម្រិតមូលដ្ឋាន
- ការវាយតម្លៃស្ថាប័នថ្នាក់ជាតិ
- ការទទួលបាន និងការប្រើប្រាស់ព័ត៌មាននយោបាយ
- អាទិភាព និងការរំពឹងទៅអនាគត

# ២. របកគំហើញសំខាន់ៗ និងផ្តល់មតិផ្នែកគោលនយោបាយ

## របកគំហើញសំខាន់ៗ

- យុវជនមានស្ថានភាពសេដ្ឋកិច្ចសង្គមខុសប្លែកគ្នាពី មនុស្សជំនាន់មុន។ ការខុសប្លែកគ្នានេះជាប់ទាក់ទងជាសំខាន់ទៅនឹងការអប់រំ ការងារ ការទទួលបានព័ត៌មាន និងបច្ចេកវិទ្យាថ្មីៗ
    - យុវជនទទួលបានការអប់រំច្រើនជាងមនុស្សជំនាន់មុន
    - យុវជន ជាពិសេសអ្នករស់នៅជនបទមានភាពចល័តជាងមនុស្សជំនាន់មុន
    - ឱកាសការងាររបស់យុវជននៅជនបទមានការផ្លាស់ប្តូរយ៉ាងខ្លាំង ពីការងារកសិកម្មនៅតាមជនបទទៅជាការងារនៅទីប្រជុំជន និងការងារមានប្រាក់បៀវត្សរ៍ ចំណែកឯមនុស្សជំនាន់មុននៅបន្តប្រកបរបរកសិកម្ម។ យុវជនជាងពាក់កណ្តាលកំពុងបម្រើការងារក្រៅប្រព័ន្ធ ដូចជាការងារបម្រើឲ្យខ្លួនឯង និងការងារបម្រើឲ្យគ្រួសារ
- ពីរភាគបីនៃយុវជនមានទូរស័ព្ទដៃទំនើប និងប្រើប្រាស់អ៊ិនធើណិត ធៀបនឹងត្រឹមប្រមាណមួយភាគបីនៃមនុស្សជំនាន់មុន
- គម្លាតយេនឌ័រនៅមានទំហំធំ ជាពិសេសក្នុងចំណោមយុវជន
    - ចំនួនស្ត្រី បានបញ្ចប់ការអប់រំកម្រិតវិទ្យាល័យ និងកម្រិតឧត្តមសិក្សា មានតិចជាងបុរស
    - ចំនួនស្ត្រីបម្រើការងារក្រៅប្រព័ន្ធ មានច្រើនជាងបុរស ពិសេសក្នុងចំណោមអ្នកបម្រើការងារឲ្យគ្រួសារដោយពុំមានទទួលប្រាក់បៀវត្សរ៍
    - ចំនួនស្ត្រីមានទូរស័ព្ទដៃទំនើបមានតិចជាងបុរស។គម្លាតយេនឌ័រក៏មានកម្រិតខ្ពស់ដែរក្នុងការទទួលបានព័ត៌មាននយោបាយ និងក្នុងការប្រើប្រាស់អ៊ិនធើណិត
- ទំនាក់ទំនងក្នុងគ្រួសារ រវាងយុវជននឹងមនុស្សជំនាន់មុន មានការផ្លាស់ប្តូរៈ យុវជនមានសេរីភាពច្រើនក្នុងការធ្វើសេចក្តីសម្រេចចិត្ត។ ក្នុងនេះ ៖
    - មនុស្សជំនាន់មុន មានចំនួនច្រើនជាងយុវជន ដែលបានចាប់អារម្មណ៍ដឹងថា ជំនាន់ទាំងពីរមានការខុសប្លែកគ្នាច្រើន
    - យុវជន និងមនុស្សជំនាន់មុនមានទស្សនៈដូចគ្នាថា យុវជនគួរសម្រេចចិត្តដោយខ្លួនឯងលើបញ្ហាសំខាន់ៗ ដូចជាការបោះឆ្នោត ជម្រើសឱកាសការងារ និងការចំណាយថវិកា
    - យុវជន និងមនុស្សជំនាន់មុន យល់ឃើញដូចគ្នាថា យុវជនគួរធ្វើការសម្រេចចិត្តរួមគ្នាជាមួយមនុស្សជំនាន់មុនក្នុងបញ្ហា ការសិក្សា និងអាពាហ៍ពិពាហ៍
    - មនុស្សជំនាន់មុន មានចំនួនច្រើនជាងយុវជន ក្នុងការយល់ស្របថា យុវជនអាចជំទាស់នឹងគំនិតរបស់មនុស្សចាស់បាន
    - គ្រួសារមានតម្លៃ និងសារៈសំខាន់បំផុត (សំខាន់លេខ១) សម្រាប់ជីវិតរស់នៅ ទាំងតាមយោបល់របស់យុវជន និងរបស់មនុស្សជំនាន់មុន ហើយបន្ទាប់មកទៀត គឺ ការអប់រំ ការងារ និង សាសនា
    - នយោបាយនិងសហគមន៍ មិត្តភក្តិនិងការកម្សាន្ត ទទួលបានចំណាត់ថ្នាក់ទាបជាងគេ ទាំងសម្រាប់យុវជន និងមនុស្សជំនាន់មុន

- ទាំងមនុស្សជំនាន់មុន និងយុវជន តែងចំណាយពេលទំនេរចូលរួមក្នុងសកម្មភាពសាសនា ជាជាង ចូលរួមក្នុងសកម្មភាពសង្គមផ្សេងៗទៀត
  - យុវជន មានចំនួនតិចជាងមនុស្សជំនាន់មុន ក្នុងការចំណាយពេលទំនេរ ចូលរួមក្នុងសកម្មភាពនយោបាយ ការបណ្តុះបណ្តាល សកម្មភាពសមាគមនិងក្លឹប និងការងារស្ម័គ្រចិត្ត។
- យុវជន និងមនុស្សជំនាន់មុន ជាទូទៅតែងគាំទ្រសមភាពយេនឌ័រសម្រាប់ការអប់រំ និងភាពជាអ្នកដឹកនាំរបស់ស្ត្រី, តែងមានចិត្តជាប់ជំពាក់ជាមួយប្រទេសជាតិនិងសាសនា និងតែងគោរពមេឃុំ
  - សមភាពយេនឌ័រក្នុងការទទួលបានការអប់រំកម្រិតឧត្តមសិក្សា មានការគាំទ្រយ៉ាងទូលំទូលាយ
  - យុវជន មានចំនួនច្រើនជាងមនុស្សជំនាន់មុន ក្នុងការគាំទ្រឲ្យស្ត្រីមានឱកាសស្មើគ្នាដើម្បីទទួលបានការអប់រំកម្រិតឧត្តមសិក្សា
  - ទាំងមនុស្សជំនាន់មុន និងយុវជន នៅមានមន្ទិលសង្ស័យទៅលើស្ត្រីក្នុងតួនាទីជាអ្នកដឹកនាំ
  - មនុស្សជំនាន់មុនមានការផ្សារភ្ជាប់ជាមួយសាសនា សហគមន៍ និងប្រទេសជាតិ ច្រើនជាងយុវជន
  - យុវជន និងមនុស្សជំនាន់មុនគិតឃើញដូចគ្នា និងមានការគោរពខ្លាំងចំពោះមេឃុំ
- ការជឿទុកចិត្តលើស្ថាប័ននិងមនុស្សទូទៅ នៅមានកម្រិត ទាំងក្នុងចំណោមមនុស្សជំនាន់មុន និងយុវជន ប៉ុន្តែទំនុកចិត្តលើអង្គការសង្គមស៊ីវិលមានកម្រិតខ្ពស់
  - អ្នកឆ្លើយសម្ភាសន៍មានការជឿទុកចិត្តលើស្ថាប័នផ្តល់សេវាសង្គម (សាលារៀន និងមន្ទីរពេទ្យ) និងមេឃុំ ច្រើនជាងលើ ស្ថាប័នប៉ូលិស តុលាការ ប្រព័ន្ធផ្សព្វផ្សាយ និងអ្នកនយោបាយ
  - ទាំងយុវជន និងមនុស្សជំនាន់មុន យល់ថា ខ្លួនឯង "មានទំនុកចិត្តខ្លះៗ" ជាជាង "ទំនុកចិត្តខ្លាំង" ទៅលើទំនាក់ទំនងជាបុគ្គល។ មនុស្សទាំងពីរជំនាន់ មានទំនុកចិត្តលើអង្គការសង្គមស៊ីវិល ក្នុងកម្រិតប្រហាក់ប្រហែលគ្នានឹងទំនុកចិត្តលើសមាជិកក្នុងរង្វង់គ្រួសារខ្លួនដែរ។
- យុវជន និងមនុស្សជំនាន់មុន ភាគច្រើនធ្លាប់បានចូលរួមក្នុងសកម្មភាពនៅកម្រិតមូលដ្ឋាន ប៉ុន្តែយុវជន តែងចូលរួមក្នុងសកម្មភាពជាប់ទាក់ទងជាមួយសាលារៀន និងមណ្ឌលសុខភាព បានច្រើនជាង ក្នុងសកម្មភាពជាប់ទាក់ទងដល់ភូមិ និងឃុំ/សង្កាត់
  - យុវជន និងមនុស្សជំនាន់មុន ភាគច្រើនធ្លាប់បានចូលរួមក្នុងការប្រជុំជាប់ទាក់ទងនឹងការងារឃុំ/សង្កាត់។ ប៉ុន្តែយុវជនបានចូលរួមសកម្មភាពកម្រិតមូលដ្ឋាន តិចជាងមនុស្សជំនាន់មុន លើកលែងតែការប្រជុំនៅសាលារៀន និងនៅមណ្ឌលសុខភាព
  - យេនឌ័រសំខាន់ណាស់សម្រាប់ការយល់ដឹងពីគម្លាតក្នុងការចូលរួម ដោយក្នុងនោះ ស្ត្រីចូលរួមបានតិចជាងបុរសក្នុងការប្រជុំរបស់ក្រុមប្រឹក្សាឃុំ/សង្កាត់ និងក្នុងវេទិកាសាធារណៈ លើកលែងតែការប្រជុំនៅមណ្ឌលសុខភាពដែលស្ត្រីចូលរួមបានច្រើនជាងបុរស
  - ការបញ្ចេញមតិក្នុងពេលចូលរួមប្រជុំនៅតាមមូលដ្ឋាន មិនសូវមានញឹកញាប់ទេ ប៉ុន្តែយុវជនហាក់បានលើកសំណួរច្រើនជាងមនុស្សជំនាន់មុន
  - យុវជននិងមនុស្សជំនាន់មុនជាច្រើននាក់បដិសេធមិនឆ្លើយសំណួរថា តើពួកគេមានការបារម្ភឬទេក្នុងការបញ្ចេញមតិនៅពេលប្រជុំកម្រិតមូលដ្ឋាន? ការបដិសេធនេះ អាចបណ្តាលមកពីអ្នកឆ្លើយសម្ភាសន៍ជាទូទៅមិនសូវមានទំនុកចិត្តលើខ្លួនឯង និងមានការប្រុងប្រយ័ត្នក្នុងការបញ្ចេញមតិយោបល់នៅពេលប្រជុំសាធារណៈ

- ◦ ទាំងយុវជន និងមនុស្សជំនាន់មុន យល់ស្របថា ឃុំ/សង្កាត់គួរមានផ្តល់សេវាច្រើនថែមទៀត និងគួរប្រើប្រាស់មូលនិធិឃុំ/សង្កាត់ សម្រាប់ការអភិវឌ្ឍសហគមន៍បន្ថែមទៀត។ ការប្រើប្រាស់មូលនិធិនេះគួរផ្តោតលើ ការពង្រឹងហេដ្ឋារចនាសម្ព័ន្ធ ការផ្គត់ផ្គង់សេវាសង្គម និងកម្មវិធីសុខុមាលភាពគាំពារសង្គម។

- ទាំងយុវជន និងមនុស្សជំនាន់មុនមានការពេញចិត្តនឹង ទិសដៅជាទូទៅ ស្ថានភាពសេដ្ឋកិច្ច និងស្ថិរភាពនយោបាយរបស់ប្រទេសកម្ពុជា ប៉ុន្តែពួកគាត់មិនសូវពេញចិត្ត ចំពោះការគិតគូរជួយដល់ប្រជាជនក្រីក្រ និងបង្កើតឱកាសការងារសម្រាប់យុវជន
  - ◦ ទាំងយុវជននិងមនុស្សជំនាន់មុន ពេញចិត្តនឹង ទិសដៅជាទូទៅ និងកំណើនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ក្នុងនេះអ្នករស់នៅជនបទមានការពេញចិត្តច្រើនជាង អ្នករស់នៅតំបន់ទីប្រជុំជន
  - ◦ ប្រជាជនភាគច្រើនពេញចិត្តនឹង សមិទ្ធផលរបស់រាជរដ្ឋាភិបាលក្នុងការរក្សាស្ថិរភាពនយោបាយ ប៉ុន្តែពួកគាត់មានការរំពឹងទុក ខ្ពស់ជាងលទ្ធផលដែលរាជរដ្ឋាភិបាលសម្រេចបានកន្លងមក ក្នុងការជួយឧបត្ថម្ភគាំទ្រដល់ប្រជាជនក្រីក្រ និងបង្កើតឱកាសការងារសម្រាប់យុវជន
  - ◦ យុវជននិងមនុស្សជំនាន់មុនភាគច្រើនពេញចិត្តនឹងស្ថាប័នផ្តល់សេវាសង្គម (ការអប់រំ ការថែទាំសុខភាព និងហេដ្ឋារចនាសម្ព័ន្ធ) ជាជាង ស្ថាប័នពង្រឹងអនុវត្តច្បាប់ និងស្ថាប័នតំណាងប្រជាពលរដ្ឋ (រដ្ឋសភា)
- ព័ត៌មាននយោបាយទទួលបានជាសំខាន់ពីប្រភពក្នុងស្រុក ប៉ុន្តែយុវជនទទួលព័ត៌មាននយោបាយពីអ៊ិនធើណិតបានច្រើនជាងមនុស្សជំនាន់មុន
  - ◦ ព័ត៌មាននយោបាយនៅតែបន្តទទួលបានពីប្រភពក្នុងស្រុកជាសំខាន់ ជាពិសេស ទូរទស្សន៍ សមាជិកគ្រួសារ និងអ្នកជិតខាង។ ដោយឡែក យុវជនដែលមានលទ្ធភាពទទួលបានព័ត៌មាននយោបាយតាមអ៊ិនធើណិត មានចំនួនច្រើនជាង មនុស្សជំនាន់មុន
  - ◦ ជាបន្ថែមលើការកម្សាន្ត និងការធ្វើទំនាក់ទំនងជាមួយមិត្តភក្តិនិងគ្រួសារនោះ យុវជន និងមនុស្សជំនាន់មុនប្រើប្រាស់អ៊ិនធើណិតសម្រាប់ស្វែងរកនិងអានព័ត៌មានទូទៅ និងព័ត៌មាននយោបាយ
  - ◦ យុវជនបង្ហាញការបារម្ភខ្លាំងជាងមនុស្សជំនាន់មុន ក្នុងការស្វែងរកព័ត៌មាននយោបាយតាមអ៊ិនធើណិត និងក្នុងការចែករំលែក និងបញ្ចេញទស្សនៈនយោបាយតាមបណ្តាញសង្គម
  - ◦ ប្រហែលពាក់កណ្តាលនៃយុវជន និងមនុស្សជំនាន់មុន មានការបារម្ភក្នុងការចែករំលែកព័ត៌មាន និងពិភាក្សាពីបញ្ហានយោបាយ ក្នុងពេលជួបប្រស្រ័យគ្នាជាក់ស្តែង (ក្រៅបណ្តាញសង្គម)
  - ◦ យុវជន និងមនុស្សជំនាន់មុន ធ្វើការចែករំលែក និងពិភាក្សាពីបញ្ហានយោបាយផ្សេងៗ ភាគច្រើនតែជាមួយសមាជិកក្នុងគ្រួសារ និងអ្នកដែលគាត់មានទំនុកចិត្ត ដូចជា មិត្តភក្តិ និងអ្នកជិតខាង ជាដើម
  - ◦ ស្ត្រីមានការប្រុងប្រយ័ត្ននិងខ្លាចច្រើនជាងបុរស ក្នុងការស្វែងរក និងបញ្ចេញទស្សនៈនយោបាយទាំងនៅក្រៅបណ្តាញសង្គម និងក្នុងបណ្តាញសង្គម។
- យុវជន និងមនុស្សជំនាន់មុន មានទស្សនៈដូចគ្នាពាក់ព័ន្ធនឹងអាទិភាពរបស់ខ្លួនឯងផ្ទាល់ និងរបស់ប្រទេសជាតិ។ ប៉ុន្តែ យុវជនមានសុទិដ្ឋិនិយមច្រើនជាងមនុស្សជំនាន់មុន ចំពោះអនាគតរបស់ខ្លួនឯងផ្ទាល់ និងរបស់ប្រទេសជាតិ
  - ◦ យុវជន និងមនុស្សជំនាន់មុន មានអាទិភាពដូចគ្នាសម្រាប់ជីវិតរស់នៅ ប៉ុន្តែបានកំណត់ឲ្យ កាតព្វកិច្ចចំពោះគ្រួសារ មានអាទិភាពខ្ពស់ជាង ការស្វែងរកចំណូល និង ការបញ្ចប់ឧត្តមសិក្សា ទៅទៀត
  - ◦ យុវជន និងមនុស្សជំនាន់មុន ផ្តល់អាទិភាពដូចគ្នាដល់ការអភិវឌ្ឍជាតិ។ ដោយឡែក ពួកគេបានផ្តល់អាទិភាពដល់ ការបោះឆ្នោត ហេដ្ឋារចនាសម្ព័ន្ធ សេវាសង្គម ឱកាសការងារ និង បរិស្ថាន។ ចំណែកឯបញ្ហាចំណាកស្រុក វិសមភាពសង្គម និងភាពអយុត្តិធម៌ ទទួលបានអាទិភាពទាបជាងគេ

◦ ជាទូទៅអ្នកឆ្លើយសម្ភាសន៍មានសុទិដ្ឋិនិយមលើអនាគតរបស់ខ្លួនឯងផ្ទាល់ និងរបស់ប្រទេសជាតិ។ យុវជនមានសុទិដ្ឋិនិយម ច្រើនជាងមនុស្សជំនាន់មុនលើអនាគតរបស់ខ្លួនឯងផ្ទាល់ ប៉ុន្តែមនុស្សទាំងពីរជំនាន់មានសុទិដ្ឋិនិយមប្រហាក់ប្រហែលគ្នាលើអនាគតប្រទេសជាតិ។

## សេចក្តីសន្និដ្ឋាន

- រវាងយុវជន នឹងមនុស្សជំនាន់មុន មានការខុសប្លែកគ្នាច្រើនបែបយ៉ាង ពោលគឺ យុវជនមានការអប់រំខ្ពស់ជាង មានភាពចល័តជាង មានឱកាសការងារមានប្រាក់បៀវត្សរ៍ច្រើនជាង និងមានទូរស័ព្ទដៃទំនើបជាងសម្រាប់ការប្រើអ៊ិនធើណិត

- ភាពខុសគ្នារវាងយុវជន នឹងមនុស្សជំនាន់មុន មិនមែនសុទ្ធតែនាំឲ្យមានទំនាស់រវាងជំនាន់មនុស្សនោះទេ ប៉ុន្តែវានាំឲ្យមានទំនាក់ទំនងសាមគ្គីភាពស្អុគស្មាញផ្សេងៗរវាងជំនាន់ទាំងពីរ ដោយសារយុវជន និងមនុស្សជំនាន់មុនមានទស្សនៈសង្គម និងទស្សនៈនយោបាយប្រហាក់ប្រហែលគ្នា

- មនុស្សជំនាន់មុន និងយុវជន តែងចាត់ទុក គ្រួសារ និង អាពាហ៍ពិពាហ៍ ជាស្ថាប័នសង្គមសំខាន់បំផុត។ ប៉ុន្តែទំនាក់ទំនងក្នុងគ្រួសារហាក់ដូចកំពុងមានការផ្លាស់ប្តូរគួរកត់សម្គាល់។ មនុស្សជំនាន់មុនមានការគោរព ក្តីមេត្តា ការជឿជាក់លើយុវជន។ មនុស្សជំនាន់មុនច្រើនទទួលយកជម្រើស និងការសម្រេចចិត្តរបស់យុវជន និងទទួលយកយោបល់ត្រឡប់ពីសមាជិកក្មេងជាងខ្លួននៅក្នុងគ្រួសារ។ យុវជនទទួលបានសេរីភាព និងសិទ្ធិអំណាចច្រើនជាងមុននៅក្នុងគ្រួសារ ហើយក៏មានការលះបង់ខ្ពស់សម្រាប់គ្រួសារដែរ។ កាតព្វកិច្ចចំពោះគ្រួសារ គឺជាការរំពឹងឃើញសំខាន់ជាងគេរបស់យុវជន

- កំណើនយុវជននាំឲ្យមានការប្រែប្រួលដល់ការចូលរួមរបស់ប្រជាជនក្នុងនយោបាយ ប៉ុន្តែ ការប្រែប្រួលនេះមិននាំឲ្យមានការឃ្លាតចេញពីគ្នា រវាងមនុស្សជំនាន់មុននឹងយុវជននោះទេ។ មនុស្សទាំងពីរជំនាន់គោរពអាជ្ញាធរ និងមានការផ្សារភ្ជាប់ខ្លាំងទៅនឹងសាសនា។ ការចូលរួមប្រជុំនៅតាមមូលដ្ឋានបានកើនឡើងច្រើន ប៉ុន្តែការចូលរួមផុសផុលនៅមានកម្រិត។ យុវជនច្រើនចូលរួមក្នុងសកម្មភាពសាលារៀន ច្រើនជាងក្នុងការងារឃុំ/សង្កាត់ និងភូមិ ហើយចំណុចនេះបង្ហាញថា ការចូលរួមរបស់យុវជននៅមានកម្រិតសម្រាប់កិច្ចការនយោបាយនៅតាមមូលដ្ឋាន។ មនុស្សទាំងពីរជំនាន់យល់ស្របនឹងទិសដៅនៃការដឹកនាំប្រទេស ប៉ុន្តែនៅមិនសូវពេញចិត្តលើការឧបត្ថម្ភគាំទ្រដល់ប្រជាជនក្រីក្រ និងការផ្តល់ឱកាសការងារសមរម្យដល់យុវជន។ យុវជនមានសុទិដ្ឋិនិយមលើអនាគតរបស់ខ្លួនឯងផ្ទាល់ និងអនាគតរបស់ប្រទេសជាតិ ខ្លាំងជាងមនុស្សជំនាន់មុន ប៉ុន្តែការជឿទុកចិត្តលើស្ថាប័ន និងលើមនុស្សទូទៅនៅមានកម្រិត។ យុវជន និងមនុស្សជំនាន់មុន ចូលរួមបញ្ចេញទស្សនៈនយោបាយដោយប្រុងប្រយ័ត្នបំផុត ទាំងការបញ្ចេញមតិតាមប្រព័ន្ធអ៊ិនធើណិត ឬក្នុងការជួបប្រស្រ័យគ្នាជាក់ស្តែង ប៉ុន្តែយុវជនច្រើនហ៊ានជាងមនុស្សជំនាន់មុន ក្នុងការស្វែងរក និងចែករំលែកព័ត៌មាននយោបាយតាមរយៈបណ្តាញសង្គម

- រចនាសម្ព័ន្ធសង្គមថ្មី (រួមទាំង រដ្ឋ ទីផ្សារ និង សង្គមស៊ីវិល) មិនទាន់អាចមកជំនួស គ្រួសារ និងសាច់ញាតិបានទេ ដើម្បីជួយកំណត់អាទិភាពក្នុងជីវិតរបស់យុវជន និងមនុស្សជំនាន់មុន និងជួយជំរុញការចូលរួមក្នុងសង្គម និងនយោបាយ។ គ្រួសារនៅតែមានឥទ្ធិពលសំខាន់បំផុតលើឥរិយាបថក្នុងការបោះឆ្នោតរបស់យុវជន និងមនុស្សជំនាន់មុន រីឯការពិភាក្សាបញ្ហានយោបាយ ភាគច្រើនកើតមានតែក្នុងរង្វង់សមាជិកគ្រួសារប៉ុណ្ណោះ។

## បញ្ហាថ្មីៗផ្នែកគោលនយោបាយ

ទោះបីស្ថានភាពរបស់យុវជនបានល្អប្រសើរឡើងគួរឲ្យសំគាល់ បើធៀបនឹងជំនាន់ឪពុកម្តាយរបស់ពួកគេក្តី ក៏យុវជននៅតែបន្តពឹងផ្អែកខ្លាំងលើការគាំទ្រពីគ្រួសារ ដើម្បីអាចបន្តការសិក្សា ទទួលបានការងារ និងអាចទប់ទល់នឹងវិបត្តិផ្សេងៗ ព្រោះសេវាសាធារណៈ និងការផ្តល់សេវាគាំពារសង្គម នៅយឺតយ៉ាវក្នុងការឆ្លើយតបនឹងតម្រូវការចាំបាច់

របស់យុវជន។ យុវជនត្រូវប្រឈមមុខនឹងបញ្ហាធំៗមួយចំនួន រួមមាន៖

- យុវជនកាន់តែច្រើនឡើង បានផ្លាស់ប្តូរពីការងារកសិកម្ម ទៅបម្រើការងារនៅទីប្រជុំជន។ ប៉ុន្តែ ការងារយុវជននៅតែប្រមូលផ្តុំលើប្រភេទការងារសុវត្ថិភាព ជាពិសេស ការងារបម្រើឲ្យខ្លួនឯង និងការងារបម្រើឲ្យគ្រួសារ ដោយមានយុវជននៅជនបទ ច្រើនជាងយុវជននៅទីប្រជុំជន ដែលកំពុងបម្រើការងារប្រភេទនេះ
- គម្លាតរវាងអ្នករស់នៅជនបទ នឹងទីប្រជុំជន ហាក់ដូចកាន់តែឃើញច្បាស់ឡើង ដោយចំនួនយុវជននៅតាមជនបទដែលទទួលបានការអប់រំ បច្ចេកវិទ្យាទំនើប និងឱកាសបម្រើការងារក្នុងប្រព័ន្ធ នៅមានតិចជាខ្លាំងបើធៀបនឹងយុវជនរស់នៅទីប្រជុំជន ហើយគម្លាតបែបនេះ អាចនាំឲ្យមានវិសមភាពកាន់តែខ្លាំងក្នុងពេលឈានដល់ជីវិតជាមនុស្សពេញវ័យ។ ប្រសិនបើមិនមានការឧបត្ថម្ភគាំទ្រគ្រប់គ្រាន់ពីស្ថាប័នរដ្ឋនានា ដល់ការសិក្សាអប់រំ ការបណ្តុះបណ្តាល និងសេវាសេដ្ឋកិច្ចដ៏ចាំបាច់ៗនោះទេ យុវជននានា ជាពិសេស យុវជននៅតាមជនបទនៅតែបន្តពឹងផ្អែកខ្លាំងទៅលើធនធាន និងការផ្គត់ផ្គង់របស់គ្រួសារ
- ការចូលរួមរបស់យុវជនក្នុងដំណើរការធ្វើគោលនយោបាយ និងការសម្រេចចិត្ត នៅមានកម្រិត។ យុវជនមិនសូវចូលរួមសកម្មក្នុងការអភិវឌ្ឍសង្គម និងសកម្មភាពធំទូលាយក្នុងសង្គមឡើយ ក្រៅតែពីសកម្មភាពនៅសាលារៀន និងកន្លែងបម្រើការងារ
- យុវជនបានយល់ដឹងច្រើនពីការងាររបស់ក្រុមប្រឹក្សាឃុំ និងអង្គការសង្គមស៊ីវិល។ ការយល់ដឹង និងទំនាក់ទំនងដោយផ្ទាល់បែបនេះ បានបង្កើតទំនុកចិត្តរបស់យុវជនទៅលើឃុំ និងអង្គការសង្គមស៊ីវិល
- ចំណេះដឹង និងទំនុកចិត្តលើស្ថាប័នសាធារណៈថ្នាក់ជាតិ មានកម្រិតក្នុងចំណោមយុវជន
- ទោះបីមានការគាំទ្រយ៉ាងពេញលេញដល់សមភាពយេនឌ័រក្នុងផ្នែកអប់រំ និងភាពជាអ្នកដឹកនាំរបស់ស្ត្រីក្តី ក៏គម្លាតយេនឌ័រនៅតែមានច្រើនគួរឲ្យកត់សំគាល់ នៅក្នុងលទ្ធផលសេដ្ឋកិច្ចសង្គមសំខាន់ៗ។ ស្ត្រីជួបការលំបាកច្រើនជាងបុរសក្នុងការបន្តការសិក្សា ការចូលរួមបម្រើការងារក្នុងប្រព័ន្ធមានប្រាក់បៀវត្សរ៍ និងការទទួលបានបច្ចេកវិទ្យាទំនើប និងព័ត៌មានក្នុងសង្គម
- យុវជន និងមនុស្សពេញវ័យមានចំនួនច្រើនគួរសម ដែលមានទូរស័ព្ទដៃទំនើប និងមានប្រើអ៊ិនធើណិតសម្រាប់ស្វែងរកព័ត៌មាន និងចែកចាយព័ត៌មាននយោបាយ។

## ការផ្តល់មតិផ្នែកគោលនយោបាយ

ខាងក្រោមនេះជាការផ្តល់មតិផ្នែកគោលនយោបាយមួយចំនួន ដើម្បីជួយដោះស្រាយបញ្ហាប្រឈមផ្សេងៗរបស់យុវជន ដែលជាប់ពាក់ព័ន្ធនឹងការផ្តល់សិទ្ធិអំណាចដល់យុវជន ការបំពេញគម្លាតផ្នែកយេនឌ័រ ការពង្រឹងទំនុកចិត្តលើស្ថាប័នសាធារណៈ និងការដោះស្រាយគម្លាតរវាងជនបទ នឹងតំបន់ទីប្រជុំជន។

- យុវជនរំពឹង និងចង់ឃើញ ការងារមិនសូវមានសុវត្ថិភាព និងនៅក្រៅប្រព័ន្ធទាំងឡាយ គឺត្រូវមានច្បាប់រដ្ឋគ្រប់គ្រងល្អ ដើម្បីការពារផលប្រយោជន៍របស់យុវជន។ រាជរដ្ឋាភិបាលគួរពង្រីកបន្ថែមនូវ ដែនគ្របដណ្តប់នៃមូលនិធិជាតិគាំពារសង្គម ដើម្បីឲ្យមានរួមបញ្ចូលទាំងយុវជនដែលជា "អ្នកបម្រើកាងារក្រៅប្រព័ន្ធ" ផងដែរ
- រាជរដ្ឋាភិបាលគួរបង្កើតវេទិកាគោលនយោបាយជាក់លាក់មួយ និងផ្តល់ជំនួយគាំទ្របង្កើនសមត្ថភាព ដើម្បីពង្រឹងសិទ្ធិអំណាចរបស់យុវជនក្នុងការចូលរួមចំណែកយ៉ាងសកម្មលើការកំណត់ និងការអនុវត្តគោលនយោបាយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ អាទិភាពចម្បងៗរបស់យុវជន រួមមាន ការអប់រំ ការបណ្តុះបណ្តាលវិជ្ជាជីវៈ ឱកាសការងារ ការផ្តល់លំនៅដ្ឋាន សេវាថែទាំសុខភាព បរិស្ថាន ការបោះឆ្នោត និងបច្ចេកវិទ្យាទំនើប

- រាជរដ្ឋាភិបាលគួរធ្វើការយ៉ាងជិតស្និទ្ធជាមួយអង្គការសង្គមស៊ីវិល និងអង្គការយុវជននានា ដើម្បីបង្កលក្ខណៈឲ្យយុវជនបានចូលរួមចំណែកក្នុងការតាក់តែងរបៀបវារៈនៃការអភិវឌ្ឍជាតិ
- យុវជនចង់ឃើញរាជរដ្ឋាភិបាលបង្កើនការគាំទ្រដល់ប្រជាជនក្រីក្រ និងបង្កើតការងារមានស្តង់ដាសមរម្យសម្រាប់យុវជន។ ក្រសួងពាក់ព័ន្ធត្រូវធ្វើការងារខ្លាំងថែមទៀត ដើម្បីដោះស្រាយប្រកបដោយប្រសិទ្ធភាពនូវបញ្ហាទាំងឡាយដែលយុវជនត្រូវប្រឈមមុខ
- រាជរដ្ឋាភិបាល និងមន្ត្រីរាជការ គួរព្យាយាមកែលំអទំនុកចិត្តរបស់ប្រជាពលរដ្ឋ និងការចូលរួមប្រកបដោយប្រសិទ្ធភាពក្នុងការអនុវត្តគោលនយោបាយ និងកំណែទម្រង់ស្ថាប័នសាធារណៈ។ ក្រសួងពាក់ព័ន្ធត្រូវទាញយកឱកាសល្អពីការប្រើប្រាស់ប្រព័ន្ធអ៊ិនធើណិតដែលកំពុងពេញនិយមក្នុងចំណោមយុវជន ដើម្បីជួយគាំទ្រដល់ក្រសួងក្នុងការអនុវត្តការងារ និងការចូលរួមកាន់តែមានប្រសិទ្ធភាពខ្ពស់ ជាមួយប្រជាពលរដ្ឋ។
- រាជរដ្ឋាភិបាលគួរបង្កើតប្រព័ន្ធអ៊ិនធើណិត និងយុទ្ធសាស្ត្រនៃការចូលរួមក្នុងប្រព័ន្ធអ៊ិនធើណិត ដើម្បីផ្តល់ព័ត៌មានដល់សាធារណៈជនស្តីពីការងាររបស់ក្រសួងផង និងជួយឲ្យប្រជាពលរដ្ឋអាចផ្តល់យោបល់ត្រឡប់លើការអនុវត្តគោលនយោបាយ និងការអនុវត្តការងាររបស់មន្ត្រីរាជការផង
- រាជរដ្ឋាភិបាលការព្យាយាមបង្កើនទំនុកចិត្តរបស់សាធារណជនទៅលើ ស្ថាប័នរដ្ឋដែលជាប់ពាក់ព័ន្ធនឹងកំណែទម្រង់វិមជ្ឈការ ជាពិសេសនៅថ្នាក់ឃុំ។ រាជរដ្ឋាភិបាលគួរពង្រឹងសមត្ថភាពក្រុមប្រឹក្សាឃុំដែលជាស្ថាប័នទទួលបានទំនុកចិត្តខ្លាំង តាមការផ្តល់ឲ្យនូវធនធាន និងសិទ្ធិអំណាចសម្រាប់ការអនុវត្តគោលនយោបាយ ដើម្បីជំរុញឲ្យមានការចូលរួមប្រកបដោយប្រសិទ្ធភាព និងការឆ្លើយតបទៅនឹងតម្រូវការក្នុងមូលដ្ឋាន រួមទាំង ការរំពឹងទុករបស់យុវជនផងដែរ។
- ម្យ៉ាងទៀតដើម្បីដោះស្រាយគម្លាតយេនឌ័រ រាជរដ្ឋាភិបាលគួរបង្កើត និងអនុវត្តគោលនយោបាយជាក់លាក់មួយចំនួន សំដៅបង្កើតឲ្យមានឱកាសស្មើភាពគ្នាសម្រាប់ឲ្យយុវនារីទទួលបាន ការអប់រំ ការបណ្តុះបណ្តាលឱកាសការងារ ភាពជាអ្នកដឹកនាំ ការគាំពារសុខុមាលភាព និងសុវត្ថិភាពក្នុងការងារ។

# ៣. វិធីសាស្ត្រអង្កេត

របាយការណ៍នេះតំណាងឲ្យទូទាំងប្រទេស ព្រោះសំណាកគំរូអ្នកឆ្លើយសម្ភាសន៍ បានកំណត់យកមនុស្សអាយុ ១៦ឆ្នាំឡើងទៅ។ អង្កេតបានធ្វើឡើងចាប់ពីខែតុលា ២០១៧ ដល់មករា ២០១៨ តាមរយៈការធ្វើសម្ភាសន៍ទល់មុខផ្ទាល់រវាងអ្នកសួរសម្ភាសន៍ នឹងអ្នកឆ្លើយសម្ភាសន៍ នៅផ្ទះរបស់អ្នកឆ្លើយសម្ភាសន៍។ សំណាកគំរូបានជ្រើសរើសដោយប្រើវិធីសាស្ត្រសំណាកគំរូតាមដំណាក់កាល (stratified multistage sampling)។ វិធីសាស្ត្រនេះបានយកមកប្រើដើម្បីកាត់បន្ថយភាពលំអៀងដោយសាររបាយប្រជាជន និងការប្រើប្រាស់ព័ត៌មានតំបន់ភូមិសាស្ត្រ។

## ៣.១ វិធីសាស្ត្រសំណាកគំរូតាមដំណាក់កាល

ក្នុងដំណាក់កាលទី១ មានការកំណត់ឯកតាទីតាំងភូមិសាស្ត្រ ដើម្បីប្រើប្រាស់ជាឯកតាគំរូដំបូង (Primary Sampling Units-PSUs)

នៅពេលកំណត់ឯកតាគំរូដំបូង (PSUs) បានហើយ គេផ្តុំវាជាក្រុម (stratified) ទៅតាមលក្ខណៈ ជាក់លាក់មួយចំនួន (តំបន់រដ្ឋបាល តំបន់ភូមិសាស្ត្រ លក្ខណៈប្រជាសាស្ត្រ)។ ក្នុងក្រុមនីមួយៗ ឯកតាគំរូដំបូង PSUs ត្រូវបានជ្រើសរើសដោយចៃដន្យ។ ឯកតាគំរូដំបូង PSUs ជាបញ្ជីសម្រាប់ជ្រើសរើសឯកតាគំរូទី២ (Secondary Sampling Units-SSUs)។

- ក្របខ័ណ្ឌជ្រើសរើសសំណាកគំរូ គឺមានភូមិទាំងអស់ដែលមានកំណត់ក្នុងជំរឿនសង្គមប្រជាសាស្ត្រឆ្នាំ២០១៥ ។ តំបន់គោលដៅសម្រាប់ជ្រើសរើសសំណាកគំរូ មានសរុប ៦ខេត្ត គឺ បាត់ដំបង កំពត ស្ទឹងត្រែង ស្វាយរៀង និង កំពង់ចាម ហើយនិង រាជធានីភ្នំពេញ
- ស្របតាមចំណុចទី១ ក្របខ័ណ្ឌជ្រើសរើសសំណាកគំរូ មានសរុប ៣៩៩៤ភូមិ ដែលមានប្រជាជនសរុប ៥.៣៤៩.៥៨២នាក់ (៣៤% នៃប្រជាជនសរុប) ក្នុងនោះមាន ៣.៣៩៩.៧៥១នាក់ ឬ ៦៤% ជាប្រជាជនរស់នៅតាមភូមិក្នុងជនបទ។
- ភូមិសំណាកគំរូក្នុងខេត្តនីមួយៗ ត្រូវបានជ្រើសរើសយោងតាម បញ្ជីភូមិយកចេញពីខេត្តទាំង ៦ និងតាងដោយ p នៅក្នុងរូបមន្តដូចខាងក្រោម៖

$$\frac{\sqrt{ភូមិ_p}}{\Sigma\sqrt{ភូមិ_p x ១០០}}$$

- ដំណើរការជ្រើសរើសសំណាកគំរូ ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពតំណាងប្រហាក់ប្រហែលគ្នានូវតំបន់ដែលមានដង់ស៊ីតេប្រជាជនតិច។

រូបភាព១៖ ចំនួនភូមិសំណាកគំរូគិតខេត្ត ធៀបនឹងចំនួនភូមិនិងប្រជាជនសរុប



- បន្ទាប់មកទៀត ភូមិសំណាកគំរូនានាត្រូវបានបែងចែកជា ក្រុមភូមិនៅជនបទ និង ក្រុមភូមិនៅទីប្រជុំជន តាមការកំណត់ថា វាជាភូមិនៅជនបទ បើសិនភូមិនោះមានប្រជាជនលើសពី ២៥% ជាអ្នកធ្វើការងារកសិកម្ម។
- ក្នុងក្រុមនីមួយៗ ប្រូបាប៊ីលីតេដែលភូមិសំណាកគំរូណាមួយត្រូវបានជ្រើសយក ត្រូវសមាមាត្រទៅនឹងចំនួនប្រជាជនសរុបក្នុងភូមិនោះ។
- សរុបមក មាន ១០១ ភូមិត្រូវបានជ្រើសយកជាសំណាកគំរូសម្រាប់អង្កេតនេះ

តារាង១៖ ព័ត៌មានលើការជ្រើសរើសភូមិសំណាកគំរូ

| ខេត្ត | ប្រជាជន | ភូមិ | % ប្រជាជនក្នុងភូមិនៅជនបទ | ជនបទ | ទីប្រជុំជន | ភូមិសំណាកគំរូសរុប |
|---|---|---|---|---|---|---|
| បាត់ដំបង | 1,217,443 | 809 | 81 | 15 | 4 | 19 |
| កំពង់ចាម | 1,119,539 | 917 | 83 | 17 | 3 | 20 |
| កំពត | 664,797 | 488 | 94 | 14 | 1 | 15 |
| ភ្នំពេញ | 1,595,989 | 962 | 10 | 2 | 19 | 21 |
| ស្ទឹងត្រែង | 138,936 | 128 | 85 | 7 | 1 | 8 |
| ស្វាយរៀង | 612,878 | 690 | 93 | 17 | 1 | 18 |
| សរុប | 5,349,582 | 3,994 | 74 (មេដ្យាន) | 72 | 29 | 101 |

- ជាដំបូងក្រុមស្រាវជ្រាវសហការជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីរៀបចំបញ្ជីខ្នងផ្ទះសម្រាប់ភូមិនីមួយៗ។
- ផ្អែកលើបញ្ជីខ្នងផ្ទះនៃភូមិនីមួយៗ ២០ខ្នងផ្ទះត្រូវបានជ្រើសរើសដោយចៃដន្យ ដោយប្រើកម្មវិធីជ្រើសរើសដោយចៃដន្យស្វ័យប្រវត្តិ
- ក្រុមស្រាវជ្រាវធ្វើការជ្រើសរើសសំណាកគំរូឡើងវិញពី ១០ ទៅ ២០ខ្នងផ្ទះ ក្នុង ៦ភូមិ នៅរាជធានីភ្នំពេញ បាត់ដំបង កំពង់ចាម ដោយសារមានគ្រួសារខ្លះធ្វើចំណាកស្រុកចេញទាំងអស់គ្នា ឬផ្លាស់ប្តូរទីលំនៅ
- ក្រុមស្រាវជ្រាវបានចុះទៅដល់ ២.០២០ខ្នងផ្ទះ និងបានធ្វើសម្ភាសន៍ជាក់ស្តែង ១.៦១០ខ្នងផ្ទះ ដែលមានសមាជិកគ្រួសារយ៉ាងតិចម្នាក់នៅផ្ទះ នៅពេលក្រុមស្រាវជ្រាវចុះទៅដល់ផ្ទះនៅលើកទី១ ឬលើកទី២។ សម្រាប់ខ្នងផ្ទះនីមួយៗ សមាជិកម្នាក់គត់ត្រូវបានជ្រើសរើសដោយចៃដន្យតាមរយៈការចាប់ឆ្នោត ដើម្បីធ្វើជាអ្នកឆ្លើយសម្ភាសន៍
- ក្រុមស្រាវជ្រាវបានបញ្ចប់ការធ្វើសម្ភាសន៍ជាមួយអ្នកឆ្លើយសម្ភាសន៍ ១.៦០០នាក់ ដោយជោគជ័យ ។
- អង្កេតនេះត្រូវបានដំណើការដោយអ្នកសួរសម្ភាសន៍មានការបណ្តុះបណ្តាលត្រឹមត្រូវ តាមរយៈការធ្វើសម្ភាសន៍ដោយផ្ទាល់នៅផ្ទះអ្នកឆ្លើយសម្ភាសន៍
- សម្ភាសន៍បានធ្វើឡើងតាមរយៈ កម្មវិធីសម្រាប់ប្រមូលព័ត៌មាន ហៅថា QuickTapSurvey application។

តារាង២៖ ក្របខ័ណ្ឌសំណាកគំរូសម្រាប់ជ្រើសរើសអ្នកឆ្លើយសម្ភាសន៍ក្នុងអង្កេត

| ខេត្ត | ភូមិសំណាកគំរូ | អ្នកឆ្លើយសម្ភាសន៍ | អ្នកឆ្លើយសម្ភាសន៍ទីប្រជុំជន % | ស្ត្រីអ្នកតបសម្ភាសន៍ % | អ្នកឆ្លើយសម្ភាសន៍អាយុក្រោម ២៥ឆ្នាំ % |
|---|---|---|---|---|---|
| បាត់ដំបង | 19 | 299 | 19 | 64 | 14 |
| កំពង់ចាម | 20 | 313 | 15 | 60 | 10 |
| កំពត | 15 | 256 | 7 | 62 | 15 |
| ភ្នំពេញ | 21 | 300 | 89 | 55 | 9 |
| ស្ទឹងត្រែង | 8 | 134 | 13 | 60 | 18 |
| ស្វាយរៀង | 18 | 298 | 6 | 58 | 10 |

## ៣.២ ការត្រួតពិនិត្យទិន្នន័យ

អ្នកសួរសម្ភាសន៍ប្រើ tablet និង កម្មវិធីកុំព្យូទ័រ QuickTapSurvey ដើម្បីកត់ត្រាព័ត៌មានលើអ្នកឆ្លើយសម្ភាសន៍សរុបទាំងអស់ ១.៦១០ករណី។ ក្នុងដំណើរការកែតម្រូវទិន្នន័យពាក់ព័ន្ធ មានការលុបចេញវិញ ១០ករណី៖

១) ៥ករណី បានលុបចេញ ដោយសារក្នុងការធ្វើសម្ភាសន៍ មានករណីខ្លះបានកត់ត្រាត្រួតគ្នា ២ដង

២) ៣ករណី បានលុបចេញ ដោយសារមានវត្តមានអាជ្ញាធរក្នុងពេលសម្ភាសន៍(ការសម្រេចលុបចេញមានការយល់ស្របពីអ្នកសួរសម្ភាសន៍)

៣) ២ករណី បានលុបចេញ ដោយការធ្វើសម្ភាសន៍មិនបានធ្វើចប់សព្វគ្រប់

ក្រុមស្រាវជ្រាវក៏បានធ្វើការកែតម្រូវកំហុសបញ្ចូលទិន្នន័យមួយចំនួនទៀត៖

១) លេខកូដភូមិសម្រាប់ ១០ករណី

២) ប្រាក់បៀវត្សរ៍ប្រចាំខែសម្រាប់ ៥ករណី

៣) សមាជិកគ្រួសារសម្រាប់ ១ករណី

និយាម (coordinates) ទីតាំងភូមិសាស្ត្រមួយចំនួនត្រូវលុបចេញ ដោយសារវាកំណត់ទីតាំងធ្វើសម្ភាសន៍នៅឆ្ងាយពេកពីចំណុចកណ្តាលភូមិ។ បញ្ហានេះកើតមានឡើង ដោយសារសម្ភាសន៍បានធ្វើឡើងក្នុងផ្ទះ ឬក្នុងពេលមានពពកច្រើនធ្វើឲ្យកម្មវិធី GPS មិនអាចចាប់បានច្បាស់នូវ និយាមទីតាំងភូមិសាស្ត្រ។ ការកំណត់និយាមទីតាំងភូមិសាស្ត្រថ្មីបានធ្វើឡើងដោយចៃដន្យ (កំណត់យកត្រឹមចម្ងាយ ៤០០ម៉ែត្រពីចំណុចកណ្តាលភូមិ)។

## ៣.៣ ការដាក់ទម្ងន់ឲ្យសំណាកគំរូ

ក្រុមការស្រាវជ្រាវបានបង្កើត អថេរទម្ងន់មួយដើម្បីធ្វើការកែតម្រូវលើ ចំនួនច្រើនពេករបស់អ្នកឆ្លើយសម្ភាសន៍ដែលជាស្ត្រី និងជាមនុស្សជំនាន់មុន ធៀបទៅនឹងចំនួនប្រជាជនសរុប។ អថេរទម្ងន់ថ្មីនេះ ត្រូវបានបង្កើតឡើងដើម្បីបន្សីទៅនឹងសមភាគ (ហៅថា raking) បំណែងចែក (marginal distributions) នៃសំណាកគំរូអង្កេតតំណាងឲ្យប្រជាជនសរុប ដែលត្រូវបានកំណត់ឡើងដោយជំរឿនប្រជាសាស្ត្រឆ្នាំ២០១៥។

រូបភាព២៖ ភាពជាតំណាងផ្នែកយេនឌ័រ នៅក្នុងសំណាកគំរូប្រជាជនសរុបតាមអាយុ



# ៤. ការពិភាក្សាលើលទ្ធផលអង្កេត

## ៤.១. ស្ថានភាពសេដ្ឋកិច្ចសង្គម

### *របកគំហើញសំខាន់ៗ*

- យុវជនមានស្ថានភាពសេដ្ឋកិច្ចសង្គមខុសគ្នាពីមនុស្សជំនាន់មុន
- យុវជនបន្តការសិក្សានៅសាលា បានច្រើនជាងមនុស្សជំនាន់មុន។ បើគិតជាតួលេខ មនុស្សជំនាន់មុន ដែលបានបញ្ចប់ការអប់រំកត្រឹមតែម្រិតបឋមសិក្សា គឺមានរហូតជិតពាក់កណ្តាល ធៀបនឹងយុវជនដែលមានប្រមាណតែតែមួយភាគបី (១/៣)។ ជាបន្ថែមលើនេះទៀត មានយុវជន ២៣% បានបញ្ចប់ការអប់រំដល់ត្រឹមកម្រិតវិទ្យាល័យ ធៀបនឹងមនុស្សជំនាន់មុនដែលមានប្រមាណតែ ៧%។
- យុវជនងាយធ្វើចំណាកស្រុក ច្រើនជាងមនុស្សជំនាន់មុន។ មានយុវជននៅជនបទ (៣៧%) ធ្វើចំណាកស្រុកច្រើនជាង យុវជននៅទីប្រជុំជន (១៥%)។
- មានយុវជន (២៤%) ច្រើនជាងមនុស្សជំនាន់មុន (៩%) ដែលធ្វើការក្នុងប្រភេទការងារ ទទួលប្រាក់បៀវត្សរ៍។ ប៉ុន្តែទាំងយុវជន និងមនុស្សជំនាន់មុន ភាគច្រើននៅបន្តធ្វើការក្រៅប្រព័ន្ធ ក្នុងនេះមានជាអាទិ៖ កសិករ (មនុស្សជំនាន់មុន ៤០% យុវជន ២៥%) អ្នកបម្រើការងារអោយខ្លួនឯង (មនុស្សជំនាន់មុន ២៨% និង យុវជន ១៥%) និងអ្នកបម្រើការងារក្នុងគ្រួសារគ្មានប្រាក់បៀវត្សរ៍ (មនុស្សជំនាន់មុន ១៨% និងយុវជន ១៣%)។
- យុវជនពីរភាគបី (៦៣%) មានទូរស័ព្ទទំនើបប្រើប្រាស់ ធៀបនឹងមនុស្សជំនាន់មុន ៣៦%។
- អ្នកឆ្លើយសម្ភាសន៍មួយភាគបី (៦៥%) ប្រើប្រាស់អ៊ិនធើណិត ក្នុងនោះមាន ៦១% នៃយុវជន និង មនុស្សជំនាន់មុនមានតែ ២៦%។
- បុរសបានបញ្ចប់ការអប់រំកម្រិតវិទ្យាល័យ និងឧត្តមសិក្សាមានចំនួនច្រើនជាងស្ត្រី។ ប៉ុន្តែ ស្ត្រីដែលបម្រើការងារក្នុងគ្រួសារគ្មានប្រាក់បៀវត្សរ៍មានចំនួនច្រើនជាងបុរស។ បុរស និងស្ត្រី មានទូរស័ព្ទដៃប្រើប្រាស់ប្រហាក់ប្រហែលគ្នា។ បុរសដែលមានទូរស័ព្ទដៃទំនើប មានចំនួនច្រើនជាងស្ត្រីដែលមានទូរស័ព្ទបែបនេះ។ បុរសដែលប្រើប្រាស់អ៊ិនធើណិតមានចំនួនច្រើនជាងស្ត្រី។

តារាង៣៖ ស្ថានភាពសេដ្ឋកិច្ចសង្គមអ្នកឆ្លើយសម្ភាសន៍ (%) (*N=១៥៨៧; ក្រៅពីនេះ N=១៦០០)

| | | | | |
|---|---|---|---|---|
| **ភេទ** | | | **តំបន់** | |
| បុរស | 40.2 | | ទីប្រជុំជន | 26.5 |
| ស្ត្រី | 59.8 | | ជនបទ | 73.5 |
| **ក្រុមអាយុ** | | | **ស្ថានភាពគ្រួសារ *** | |
| យុវជន (16–30 ឆ្នាំ) | 24.9 | | នៅលីវ | 12.5 |
| មនុស្សជំនាន់មុន (>30 ឆ្នាំ) | 75.1 | | មានប្តី/ប្រពន្ធ | 73.5 |
| **កម្រិតអប់រំ** | | | មេម៉ាយ/ពោះម៉ាយ | 11.5 |
| មិនបានចូលរៀន | 9.4 | | លែងលះ | 2.5 |
| បឋមសិក្សា | 45.7 | | **មុខរបរ *** | |
| អនុវិទ្យាល័យ | 26.0 | | កសិករ | 36.1 |
| វិទ្យាល័យ | 11.3 | | មន្ត្រីរាជការ | 5.5 |
| បណ្តុះបណ្តាលវិជ្ជាជីវៈ | 0.4 | | បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល | 0.3 |
| ឧត្តមសិក្សា | 5.9 | | ការងារមានប្រាក់បៀវត្សរ៍ | 12.7 |
| ផ្សេងៗ | 1.4 | | ការងារបម្រើឲ្យខ្លួនឯងប្រកបរបរផ្ទាល់ខ្លួន | 24.4 |
| **ព័ត៌មានផ្សេងៗ** | | | ការងារបម្រើឲ្យគ្រួសារគ្មានប្រាក់បៀវត្សរ៍ | 14.4 |
| អ្នករស់នៅជាមួយគ្រួសារ | 97.7 | | សិស្ស | 3.6 |
| ចំណាកស្រុក | 26.5 | | គ្មានការងារធ្វើ | 3.0 |
| ការប្រើប្រាស់អ៊ិនធើណិត | 34.6 | | | |

### ៤.១.១ អាយុ និងភេទ

នៅកម្ពុជា យុវជន(អាយុពី ១៥ ដល់ ៣០ឆ្នាំ)មានច្រើនណាស់ រហូតដល់ ៣៣% នៃប្រជាជនសរុប ហើយ កុមារ (អាយុក្រោម ១៥ឆ្នាំ) មានដល់ ៣០% ។ អាយុមេដ្យានរបស់អ្នកឆ្លើយសម្ភាសន៍ មានកម្រិត ២៤,៥ឆ្នាំ ក្នុងនេះ ស្ត្រីមានកម្រិត ២៥,៦ឆ្នាំ និង បុរស ២៣,៤ឆ្នាំ[៦]។ នៅក្នុងប្រជាជនសរុប ស្ត្រី (៥១,៥%) មានច្រើនជាង បុរស (៤៨.៥%) ។

អ្នកចូលរួមក្នុងអង្កេតនេះមានសរុប ១៦០០នាក់ ក្នុងនោះ យុវជន (អាយុពី ១៦ ដល់ ៣០ឆ្នាំ) មាន ២៤,៩% និង មនុស្សជំនាន់មុន (អាយុលើសពី ៣០ឆ្នាំ) មាន ៧៥,១% ហើយ ស្ត្រីមាន ៥៩,៨% និងបុរសមាន ៤០,២% ។

### ៤.១.២ ការអប់រំ

យុវជន និងមនុស្សជំនាន់មុន ខុសប្លែកគ្នាខ្លាំងក្នុងការទទួលបានការអប់រំ។ យុវជនទទួលបានការអប់រំ និង បន្តការសិក្សា បានច្រើនជាងជំនាន់ឳពុកម្តាយគាត់៖ យុវជន ៩៨% និង មនុស្សជំនាន់មុន ៨៨% ធ្លាប់បានចូលរៀន ក្នុងសាលា។ មនុស្សជំនាន់មុនជិតពាក់កណ្តាល (៤៩%) បានរៀនចប់ត្រឹមបឋមសិក្សា, ២៦% បានរៀនចប់ត្រឹម អនុវិទ្យាល័យ និង ៧% រៀនចប់ត្រឹមវិទ្យាល័យ។ ក្នុងចំណោមយុវជន មាន ៣៦% បានរៀនចប់ត្រឹមបឋមសិក្សា ២៥% បានរៀនចប់ត្រឹមអនុវិទ្យាល័យ និង ២៣% បានរៀនចប់ត្រឹមវិទ្យាល័យ។ មានអ្នកឆ្លើយសម្ភាសន៍នៅជនបទ តិចនាក់ណាស់ (២%) ដែលបានបញ្ចប់ការអប់រំកម្រិតឧត្តមសិក្សា រីឯអ្នកឆ្លើយសម្ភាសន៍នៅទីប្រជុំជនមានដល់ ១៧% ។ មានស្ត្រី ៥០% បានរៀនចប់ត្រឹមបឋមសិក្សា រីឯបុរសមាន ៣៩% ។ ប៉ុន្តែ ស្ត្រីមានតិចជាងវិញក្នុងការបញ្ចប់ត្រឹម អនុវិទ្យាល័យ (២២%) និងត្រឹមវិទ្យាល័យ (៨%) ធៀបនឹងបុរសដែលមានដល់ ៣១% សម្រាប់អនុវិទ្យាល័យ និង ១៦% សម្រាប់វិទ្យាល័យ។ គម្លាតយេនឌ័របន្តកើតមានក្នុងការបញ្ចប់កម្រិតឧត្តមសិក្សា ដោយបុរសមានដល់ ៨% គឺច្រើនជាងស្ត្រី (៤ %) ដល់ទៅពីរដង។

តារាង៤៖ កម្រិតសិក្សាបានបញ្ចប់ (N=១៦០០)

| កម្រិតការសិក្សា | សរុប | ក្រុមអាយុ | | ភេទ | | តំបន់ | |
|---|---|---|---|---|---|---|---|
| | | យុវជន | មនុស្សជំនាន់មុន | បុរស | ស្ត្រី | ជនបទ | ទីប្រជុំជន |
| មិនបានចូលរៀន | 9 | 2 | 12 | 5 | 13 | 11 | 5 |
| បឋមសិក្សា | 46 | 36 | 49 | 39 | 50 | 52 | 27 |
| អនុវិទ្យាល័យ | 26 | 25 | 26 | 31 | 22 | 24 | 30 |
| វិទ្យាល័យ | 11 | 23 | 7 | 16 | 8 | 9 | 18 |
| បណ្តុះបណ្តាលវិជ្ជាជីវៈ | 0 | 0 | 1 | 1 | 0 | 0 | 1 |
| ឧត្តមសិក្សា | 6 | 14 | 3 | 8 | 4 | 2 | 17 |
| ផ្សេងៗ | 1 | 0 | 2 | 1 | 2 | 1 | 1 |

### ៤.១.៣ អាពាហ៍ពិពាហ៍ និងគ្រួសារ

អ្នកឆ្លើយសម្ភាសន៍ភាគច្រើនមានចំណងអាពាហ៍ពិពាហ៍ និងបន្តរស់នៅជុំគ្នាក្រោមដំបូលផ្ទះតែមួយ។ យោងតាម អង្កេតនេះ ក្នុងចំណោមយុវជន ស្ត្រីបានរៀបអាពាហ៍ពិពាហ៍ច្រើនជាងបុរស។ យុវបុរសតែងនៅលីវ យូរជាងយុវនារី៖ យុវបុរសនៅលីវមានដល់ ៥២% ធៀបនឹងយុវនារីនៅលីវមានត្រឹម ៣៣% ។ ក្នុងចំណោមមនុស្សជំនាន់មុនស្ត្រីស្ថិតក្នុង ស្ថានភាពមេម៉ាយ និងលែងលះគ្នា មានច្រើនជាងបុរស (ស្ត្រីមាន ២១% ធៀបនឹងបុរសត្រឹម ៦%) ហើយបញ្ហានេះ អាចបណ្តាលមកពី សង្គ្រាមក្នុងអតីតកាល និងការរំពឹងសង្ឃឹមផ្សេងៗផ្នែកវប្បធម៌។

[៦] អង្កេតជំរឿនប្រជាសាស្ត្រប្រជាជនកម្ពុជាឆ្នាំ២០១៣។

គ្រួសារនៅកម្ពុជានៅមានសមាជិកច្រើន ជាមធ្យម ដល់ ៥នាក់ក្នុងមួយគ្រួសារ រួមទាំងអ្នករៀបអាពាហ៍ពិពាហ៍រួច ដែលរស់នៅក្រោមដំបូលផ្ទះតែមួយ ទាំងនៅជនបទ និងទីប្រជុំជន។

រូបភាព៣៖ ស្ថានភាពគ្រួសារ (N=១៥៨៧)




រូបភាព៤៖ ភាគរយអ្នកឆ្លើយសម្ភាសន៍រស់នៅជាមួយសមាជិកគ្រួសារ (N=១៦០០)




## ៤.១.៤ ចំណាកស្រុក

សមាជិកគ្រួសារសព្វថ្ងៃកាន់តែបែកខ្ញែកគ្នាឡើង ជាពិសេស ដោយសារយុវជនកាន់តែធ្វើចំណាកស្រុកច្រើន ពីជនបទទៅទីប្រជុំជន។ យុវជននៅជនបទ (៣៧%) មានច្រើនជាងយុវជននៅទីប្រជុំជន (១៥%) ដល់ទៅពីរដង ដែលធ្វើចំណាកស្រុកស្វែងរកឱកាសការងារ ហើយមនុស្សជំនាន់មុននៅជនបទ (២៨%) ក៏ធ្វើចំណាកស្រុកច្រើនជាង មនុស្សជំនាន់មុននៅទីប្រជុំជន (១៧%) ដែរ។

រូបភាព៥៖ តើអ្នកធ្លាប់ធ្វើចំណាកស្រុកដើម្បីស្វែងរកការងារដែរឬទេ? (N=១៦០០)




## ៤.១.៥ ការងារ និងប្រាក់ចំណូល

ការងារ និងរបៀបចិញ្ចឹមជីវិតមានការផ្លាស់ប្តូរដោយសារ ការងារទទួលបានប្រាក់បៀវត្សរ៍ក្នុងទីប្រជុំជនបាន កើនឡើង នៅពេលដែលរចនាសម្ព័ន្ធសេដ្ឋកិច្ចមានការផ្លាស់ប្តូរខ្លាំង។ ក្នុងអង្កេតនេះ សម្រាប់ការងារមានប្រាក់បៀវត្សរ៍ បុរសមានច្រើននាក់ជាងស្ត្រី ប៉ុន្តែសម្រាប់ការងារបម្រើឲ្យគ្រួសារគ្មានប្រាក់បៀវត្សរ៍ ស្ត្រី (២២%) មានច្រើនជាងបុរស (៣%) ។ សម្រាប់ការងារក្រៅប្រព័ន្ធ ដូចជា ការងារបម្រើឲ្យខ្លួនឯង (ស្ត្រី ២៦% បុរស ២២%) ជាដើម ស្ត្រីមាន ច្រើនជាងបុរស។ ផ្ទុយទៅវិញ បុរសមានច្រើនជាងស្ត្រី នៅក្នុងការងារក្នុងប្រព័ន្ធ ដូចជា ការងារមានប្រាក់បៀវត្សរ៍ (បុរស ១៧% ស្ត្រី ១០%) និង ការងារជាមន្ត្រីរាជការ (បុរស ១០% ស្ត្រី ៣%) ជាដើម។

អ្នកនៅជនបទ មានចំនួនច្រើនជាងអ្នកនៅទីប្រជុំជន នៅក្នុងការងារក្រៅប្រព័ន្ធ។ ក្នុងចំណោមអ្នករស់នៅជនបទ មានជិតពាក់កណ្តាលជាកសិករ ១៩% ជាអ្នកបម្រើការងារឲ្យខ្លួនឯង និង ១៣% ជាអ្នកបម្រើការងារគ្រួសារគ្មានប្រាក់បៀវត្សរ៍។ នៅទីប្រជុំជន អ្នកបម្រើការងារឲ្យខ្លួនឯង មាន ៤០% ហើយ អ្នកបម្រើការងារគ្រួសារគ្មានប្រាក់បៀវត្សរ៍ មាន ១៨% ។ សម្រាប់ការងារមានប្រាក់បៀវត្សរ៍ អ្នករស់នៅទីប្រជុំជន (១៤%) មានចំនួនច្រើនជាង អ្នករស់នៅជនបទ (១២) គឺដូចគ្នានឹងការងារជាមន្ត្រីរាជការ (អ្នករស់នៅទីប្រជុំជន ១២% អ្នករស់នៅជនបទ ៣%) ដែរ។

យុវជនភាគច្រើនមានការងារធ្វើ។ យុវជន (២៥%) មានតិចជាង មនុស្សជំនាន់មុន (៤០%) ដែលប្រកបរបរជាកសិករ។ ក្នុងការងារមានប្រាក់បៀវត្សរ៍ យុវជន (២៤%) មានច្រើនជាង មនុស្សជំនាន់មុន (៩%) ។ យុវជន និង មនុស្សជំនាន់មុន ជាច្រើននាក់ ជាអ្នកបម្រើការងារឲ្យខ្លួនឯង (យុវជន ១៥% មនុស្សជំនាន់មុន ២៨%) និង ជាអ្នកបម្រើការងារគ្រួសារគ្មានប្រាក់បៀវត្សរ៍ (យុវជន ១៨% មនុស្សជំនាន់មុន ១៣%)។ ស្ថានភាពការងាររបស់យុវជនបានផ្លាស់ប្តូរពីមុខរបរជាកសិករ មកចាប់យក ការងារមានប្រាក់បៀវត្សរ៍ ឬការងារបម្រើឲ្យខ្លួនឯង ជាពិសេស យុវជនរស់នៅទីប្រជុំជន។ ទោះបីយុវជនច្រើននាក់បានចូលបម្រើការងារមានប្រាក់បៀវត្សរ៍ និងការងារក្នុងប្រព័ន្ធក្តី ក៏នៅមានយុវជនម្នាក់ក្នុងចំណោមពីរនាក់ (៥៨%) នៅបន្តបម្រើការងារក្រៅប្រព័ន្ធដោយគ្មានកិច្ចសន្យាការងារ គ្មានទទួលបានការគាំពារផ្លូវច្បាប់ និងគ្មានសេវាសុខុមាលភាពសង្គម។

តារាង៥៖ ប្រភេទមុខរបរ (%) (N=១៥៨៧)

| | សរុប | ក្រុមអាយុ | | ភេទ | | តំបន់ | |
|---|---|---|---|---|---|---|---|
| | | យុវជន | មនុស្សជំនាន់មុន | បុរស | ស្ត្រី | ជនបទ | ទីប្រជុំជន |
| កសិករ | 36 | 25 | 40 | 40 | 34 | 46 | 8 |
| មន្ត្រីរាជការ | 6 | 2 | 7 | 10 | 3 | 3 | 12 |
| បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល | 0 | 0 | 0 | 0 | 0 | 0 | 1 |
| ការងារមានប្រាក់បៀវត្សរ៍ | 13 | 24 | 9 | 17 | 10 | 12 | 14 |
| ការងារបម្រើឲ្យខ្លួនឯង | 24 | 15 | 28 | 22 | 26 | 19 | 40 |
| ការងារបម្រើគ្រួសារគ្មានប្រាក់បៀវត្សរ៍ | 14 | 18 | 13 | 3 | 22 | 13 | 18 |
| សិស្ស | 4 | 14 | 0 | 4 | 3 | 4 | 3 |
| គ្មានការងារធ្វើ | 3 | 2 | 3 | 4 | 2 | 3 | 4 |

### ៤.១.៦ ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន

អ្នកឆ្លើយសម្ភាសន៍ភាគច្រើនមានទូរទស្សន៍ ទូរស័ព្ទដៃ និងទូរស័ព្ទទំនើប។ ជាក់ស្តែង អ្នករស់នៅទីប្រជុំជន ៦៧% និង អ្នករស់នៅជនបទ ៣៤% ប្រើប្រាស់ទូរស័ព្ទទំនើប។ ក្នុងការប្រើទូរស័ព្ទទំនើប យុវជន (៦៣%) មានច្រើនជាង មនុស្សជំនាន់មុន (៣៦%) ដល់ទៅពីរដង។

អ្នកឆ្លើយសម្ភាសន៍ម្នាក់ក្នុងចំណោមបីនាក់ប្រើប្រាស់អ៊ិនធើណិត ហើយភាគច្រើនជា យុវជនរស់នៅទីប្រជុំជន និង យុវជនមានការអប់រំកម្រិតឧត្តមសិក្សា។ ក្នុងការប្រើប្រាស់អ៊ិនធើណិតនេះ យុវជននៅទីប្រជុំជនមានដល់ ៩៣% ចំណែកឯយុវជននៅជនបទមានត្រឹម ៥១% ហើយបើសរុបទាំងទីប្រជុំជន និងជនបទ យុវជន មាន ៦១% រីឯ មនុស្សជំនាន់មុន មាន ២៦% ។ មនុស្សជំនាន់មុនដែលប្រើប្រាស់អ៊ិនធើណិតមានកាន់តែមានតិចនាក់ទៀត ពោលគឺ មនុស្សជំនាន់មុននៅទីប្រជុំជន មាន ៤៦% ហើយមនុស្សជំនាន់មុននៅជនបទ មាន ១៨% ។

តារាង៦៖ តើអ្នកមានឧបករណ៍ប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានទាំងនេះឬទេ? (%) (N=១៦០០)

| | ទូរស័ព្ទដៃ | ទូរស័ព្ទទំនើប | កុំព្យូទ័រ | ទូរទស្សន៍ | វិទ្យុ | មិនមានរបស់ទាំងនេះទេ |
|---|---|---|---|---|---|---|
| សរុប | 75 | 42 | 8 | 77 | 33 | 2 |
| ក្រុមអាយុ | | | | | | |
| យុវជន | 64 | 63 | 13 | 74 | 31 | 4 |
| មនុស្សជំនាន់មុន | 78 | 36 | 6 | 78 | 33 | 4 |
| ភេទ | | | | | | |
| បុរស | 74 | 51 | 10 | 80 | 37 | 3 |
| ស្ត្រី | 75 | 36 | 6 | 75 | 30 | 5 |
| តំបន់ | | | | | | |
| ជនបទ | 76 | 34 | 2 | 72 | 33 | 5 |
| ទីប្រជុំជន | 71 | 67 | 22 | 91 | 33 | 1 |

រូបភាព៦៖ តើអ្នកមានប្រើប្រាស់អ៊ិនធើណិតដែរឬទេ? (N=១៦០០)






## ៤.២. ទំនាក់ទំនងរវាងមនុស្សជំនាន់មុនជាមួយនឹងយុវជន នៅក្នុងគ្រួសារ

### របកគំហើញសំខាន់ៗ

- មនុស្សជំនាន់មុនភាគច្រើន (៨១%) និយាយថាយុវជនមានការខុសប្លែកគ្នាខ្លាំងពីមនុស្សជំនាន់មុន។ ប៉ុន្តែមានយុវជនតែ ៦៦% ប៉ុណ្ណោះដែលយល់ដូច្នេះ។
- យុវជន និងមនុស្សជំនាន់មុន មានការយល់ឃើញដូចគ្នា លើការសម្រេចចិត្តរបស់យុវជន។ មនុស្សទាំងពីរជំនាន់យល់ស្របគ្នាទាំងអស់ថា យុវជនគួរមានការសម្រេចចិត្តដោយខ្លួនឯងលើបញ្ហាសំខាន់ៗ ដូចជា ការបោះឆ្នោត ឱកាសការងារ និងការទិញទូរស័ព្ទ។ ពាក់ព័ន្ធនឹងការសម្រេចចិត្តលើការអប់រំ និងអាពាហ៍ពិពាហ៍ ទាំងយុវជន និងមនុស្សជំនាន់មុនគិតថា បញ្ហានេះគួរធ្វើការសម្រេចចិត្តរួមគ្នាជាលក្ខណៈគ្រួសារ។
- មនុស្សជំនាន់មុន (៦០%) មានច្រើនជាង យុវជន (៥៥%) ដែលយល់ថាយុវជនអាចជំទាស់នឹងគំនិតឪពុកម្តាយបាន។ ការយល់ឃើញបែបនេះមានស្រដៀងគ្នាដែរក្នុងចំណោម អ្នកនៅទីប្រជុំជន (៦៧%) និងអ្នកនៅជនបទ (៥៦%)។
- យុវជន និងមនុស្សជំនាន់មុន តែងចាត់ទុកគ្រួសារថាមានសារៈសំខាន់ និងមានតម្លៃខ្ពស់បំផុតក្នុងជីវិត ហើយបន្ទាប់មកគឺ ការអប់រំ ការងារ និងសាសនា។ រីឯ នយោបាយនិងសហគមន៍ មិត្តភក្តិ និងការកម្សាន្ត ទទួលបានចំណាត់ថ្នាក់ទាបជាងគេ។
- មនុស្សជំនាន់មុនសកម្មខ្លាំងជាងយុវជន ក្នុងការចូលរួមក្នុងសកម្មភាពសហគមន៍ ប៉ុន្តែមនុស្សទាំងពីរជំនាន់ចំណាយពេលទំនេរភាគច្រើនដូចគ្នា ដើម្បីចូលរួមក្នុងសកម្មភាពសាសនា។ មានយុវជនតិចជាង មនុស្សជំនាន់មុនដែលចំណាយពេលទំនេរចូលរួមក្នុងសកម្មភាពនយោបាយ ការបណ្តុះបណ្តាល ក្លឹប និងសមាគម និង ការងារស្ម័គ្រចិត្ត។

### ៤.២.១ ភាពខុសគ្នារវាងមនុស្សជំនាន់មុន នឹងយុវជន

ផ្នែកនេះ ធ្វើការស្វែងយល់ពីឥរិយាបថរបស់អ្នកឆ្លើយសម្ភាសន៍ចំពោះភាពខុសគ្នារវាង មនុស្សជំនាន់មុន នឹងយុវជន តាមរយៈ កម្រងសំណួរមួយដែលមានតាំងពី មតិយោបល់ទូទៅ រហូតដល់ ការសម្រេចចិត្តក្នុងគ្រួសារ។

រូបភាព៧៖ តើមនុស្សជំនាន់អ្នក ខុសប្លែកពីមនុស្សជំនាន់មុនដែរឬទេ? (N=១៦០០)



រូបភាព៧ បង្ហាញនូវការយល់ឃើញពីភាពខុសគ្នារវាងយុវជននឹងមនុស្សជំនាន់មុន។ ជារួម អ្នកឆ្លើយសម្ភាសន៍ ៧៧% យល់ឃើញថា មនុស្សជំនាន់មុនខុសគ្នាខ្លាំងពីយុវជន។ យុវជន និងមនុស្សជំនាន់មុន យល់ស្របគ្នាពីភាពខុសគ្នាខ្លាំងរវាងជំនាន់ទាំងពីរ។ មនុស្សជំនាន់មុន ៨១% យល់ស្របថា មានភាពខុសគ្នាខ្លាំងរវាងជំនាន់របស់គាត់ជាមួយនឹងជំនាន់យុវជន ហើយការយល់ឃើញបែបនេះអាចមកពីបទពិសោធន៍ជីវិតខុសគ្នា និងបរិបទផ្សេងៗដែលអ្នកទាំងនោះបានឆ្លងកាត់។ យុវជន ៦៦% គិតថា ជំនាន់ទាំងពីរមានភាពខុសគ្នាខ្លាំង ហើយ យុវជន ៣១% គិតថា ជំនាន់ទាំងពីរខុសគ្នាតែបន្តិចបន្តួច។

### *៤.២.២ ការសម្រេចចិត្តរបស់យុវជន*

អង្កេតនេះ បានសាកសួរអ្នកឆ្លើយសម្ភាសន៍ពី ការសម្រេចចិត្តនៅក្នុងគ្រួសារទាក់ទងនឹងបញ្ហាសំខាន់ៗដែលប៉ះពាល់ដល់យុវជន និងមតិរបស់គាត់អំពី នរណាគួរមានសិទ្ធិសម្រេចអារកាត់លើបញ្ហាទាំងនោះ។ ក្រុមស្រាវជ្រាវចង់ស្វែងយល់ថា តើយុវជន និងមនុស្សជំនាន់មុន មានការពិភាក្សា ឬពិចារណាជាមួយគ្នាឬទេ លើសេចក្ដីសម្រេចចិត្តសំខាន់ៗក្នុងគ្រួសារ។

តារាង៧ បង្ហាញថា មនុស្សជំនាន់មុនផ្ដល់សិទ្ធិអំណាចច្រើនដល់យុវជនក្នុងការសម្រេចអារកាត់ពាក់ព័ន្ធនឹងយុវជនខ្លួនឯងផ្ទាល់។ ទាំងយុវជន និងមនុស្សជំនាន់មុន គាំទ្រឲ្យយុវជនសម្រេចចិត្តខ្លួនឯងទាក់ទងនឹង ការបោះឆ្នោត ការងារ និងការទិញទូរស័ព្ទ។ យុវជន ៩៥% និងមនុស្សជំនាន់មុន ៩៣% និយាយថា យុវជនគួរសម្រេចចិត្តខ្លួនឯងទាក់ទងនឹងការបោះឆ្នោត។ ស្រដៀងគ្នាដែរ យុវជន ៨៥% និងមនុស្សជំនាន់មុន ៨២% និយាយថា យុវជនគួរសម្រេចចិត្តខ្លួនឯងពី របៀបចាយវាយលើការទិញទូរស័ព្ទ ហើយ យុវជន ៧៧% និងមនុស្សជំនាន់មុន ៧៣% គាំទ្រឲ្យយុវជនធ្វើការសម្រេចចិត្តជ្រើសរើសការងារដោយខ្លួនឯង។

ពាក់ព័ន្ធការសម្រេចចិត្តលើការអប់រំ និងអាពាហ៍ពិពាហ៍ ទាំងយុវជន និងមនុស្សជំនាន់មុន គិតថាបញ្ហានេះគួរធ្វើការសម្រេចចិត្តរួមគ្នាជាលក្ខណៈគ្រួសារ។ យុវជននិងមនុស្សជំនាន់មុន ជាង ៥០% យល់ថា យុវជនខ្លួនឯង និងមនុស្សជំនាន់មុន គួរធ្វើការសម្រេចចិត្តរួមគ្នាលើការអប់រំ និងអាពាហ៍ពិពាហ៍របស់យុវជន។ ជាទូទៅ ទាំងពីរជំនាន់យល់ឃើញថា ការអប់រំ និងអាពាហ៍ពិពាហ៍គឺជាការសម្រេចចិត្តរួមគ្នាក្នុងគ្រួសារ រីឯ របោះឆ្នោត ការងារ និងការចាយវាយទិញទូរស័ព្ទ គួរជាការសម្រេចចិត្តរបស់បុគ្គល។

តារាង៧៖ តើអ្នកណាខ្លះគួរមានសិទ្ធិសម្រេចអារកាត់លើបញ្ហារបស់យុវជន? (%) (N=១៦០០)

| អ្នកឆ្លើយសម្ភាសន៍ / អ្នកសម្រេចចិត្ត | ការសិក្សា | | ការងារ | | អាពាហ៍ពិពាហ៍ | | ទិញទូរស័ព្ទដៃ | | ការបោះឆ្នោត | |
|---|---|---|---|---|---|---|---|---|---|---|
| | យុវជន | មនុស្សជំនាន់មុន | យុវជន | មនុស្សជំនាន់មុន | យុវជន | មនុស្សជំនាន់មុន | យុវជន | មនុស្សជំនាន់មុន | យុវជន | មនុស្សជំនាន់មុន |
| យុវជន | 57 | 53 | 77 | 73 | 57 | 63 | 85 | 82 | 95 | 93 |
| ឪម្ដាយ | 41 | 45 | 19 | 24 | 42 | 36 | 15 | 17 | 3 | 5 |
| សាច់ញាតិ | 1 | 0 | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| មិត្តភក្តិ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| អាជ្ញាធរ | 1 | 1 | 2 | 0 | 0 | 0 | 0 | 0 | 2 | 1 |
| ចាស់ទុំ និងព្រះសង្ឃ | 1 | 1 | 1 | 0 | 1 | 0 | 0 | 0 | 0 | 0 |

សិទ្ធិមានទស្សនៈនយោបាយផ្ទាល់ខ្លួន មានការគាំទ្រខ្លាំងទាំងពីយុវជន និងមនុស្សជំនាន់មុន។ មនុស្សជំនាន់មុនមិនបានដាក់គំនាបឲ្យ យុវជនធ្វើតាមទស្សនៈនយោបាយរបស់គាត់ទេ។ ផ្ទុយទៅវិញ មនុស្សជំនាន់មុនគាំទ្រឲ្យយុវជនមានទស្សនៈនយោបាយរបស់ខ្លួនផ្ទាល់។ មនុស្សជំនាន់មុន ៩៤% និងយុវជន ៩៣% ជឿជាក់ថា យុវជនគួរមានអត្តសញ្ញាណនយោបាយរបស់ខ្លួនផ្ទាល់។

រូបភាព៨៖ តើអ្នកយល់ស្របដែរថា ការមានទស្សនៈនយោបាយរបស់ខ្លួនផ្ទាល់ជាការសំខាន់? (N=១៦០០)




ស្រដៀងគ្នាដែរ មនុស្សជំនាន់មុនយល់ថា យុវជនជាសាច់ញាតិគាត់ អាចមានទស្សនៈខុសគ្នាពីគាត់ (រូបភាព៩)។ មនុស្សជំនាន់មុនជិតពីរភាគបី (២/៣) យល់ថា យុវជនមិនមែនត្រូវតែធ្វើតាមមនុស្សជំនាន់មុន ហើយយុវជនអាចជំទាស់ជាមួយឪពុកម្តាយបាន។ ផ្ទុយទៅវិញ មានយុវជនតែ ៥៥% ប៉ុណ្ណោះដែលនិយាយថា វាជាការសំខាន់ដែលយុវជនអាចជំទាស់ជាមួយឪពុកម្តាយបាន រីឯ ៤៥% ទៀតយល់ថា យុវជនមិនគួរជំទាស់ជាមួយឪពុកម្តាយទេ។ អ្នករស់នៅទីប្រជុំជន មានចិត្តអំណត់ក្នុងការទទួលយកមតិយោបល់ ជាងអ្នករស់នៅជនបទ ហើយស្ត្រីមានចិត្តអំណត់ច្រើនជាងបុរស។ ទាំងអស់នេះបង្ហាញថា មនុស្សជំនាន់មុនមានការយោគយល់ច្រើនដល់ការខ្វែងមតិផ្សេងៗជាមួយគាត់ពីសំណាក់យុវជនដែលជាសាច់ញាតិគាត់។

រូបភាព៩៖ តើអ្នកយល់ស្របដែរថា យុវជនអាចជំទាស់ជាមួយឪពុកម្តាយបាន? (N=១៦០០)



ការទទួលខុសត្រូវក្នុងគ្រួសារ មានអាទិភាពខ្លាំងជាងគេក្នុងជីវិត ចំណែកឯអាទិភាពដទៃទៀត មានជាអាទិ៍ការអប់រំនិងការងារ នយោបាយនិងសហគមន៍ មិត្តភក្តិនិងការកម្សាន្ត។ អាទិភាព ៣ ដែលសំខាន់ជាងគេសម្រាប់យុវជន គឺមាន ទី១ គ្រួសារ (៧៨%) ទី២ ការអប់រំ និងការងារ (៤៥%) និង ទី៣ សាសនា (៣៣%) ។ ចំណែកឯ អាទិភាព ៣ សំខាន់ជាងគេសម្រាប់មនុស្សជំនាន់មុន គឺ ទី១ គ្រួសារ (៦៥%) ទី២ សាសនា (៣១%) និង ទី៣ ការអប់រំនិងការងារ (២៨%) ។ អាទិភាពទាបជាងគេ ៣ ដែល យុវជន និងមនុស្សជំនាន់មុន បានកំណត់ គឺមាន នយោបាយនិងសហគមន៍ មិត្តភក្តិ និង ការកម្សាន្ត។ មនុស្សជំនាន់មុន និងយុវជន មានជម្រើសអាទិភាពក្នុងជីវិតខុសគ្នាបន្តិចបន្តួច ហើយមនុស្សទាំងពីរជំនាន់មានការតាំងចិត្តខ្ពស់ចំពោះ គ្រួសារ ការអប់រំនិងការងារ និង សាសនា។

តារាង៨៖ ចំណាត់ថ្នាក់អាទិភាពជីវិតរបស់យុវជន (%) (N=៣៩៨)

| | ចំណាត់ថ្នាក់ទី1 | ចំណាត់ថ្នាក់ទី2 | ចំណាត់ថ្នាក់ទី3 | ចំណាត់ថ្នាក់ទី4 | ចំណាត់ថ្នាក់ទី5 | ចំណាត់ថ្នាក់ទី6 |
|---|---|---|---|---|---|---|
| មិត្តភក្តិ | 0 | 9 | 12 | 21 | 41 | 15 |
| ការកម្សាន្ត | 0 | 2 | 7 | 11 | 22 | 56 |
| គ្រួសារ | 78 | 14 | 5 | 2 | 1 | 0 |
| នយោបាយ/សហគមន៍ | 3 | 13 | 21 | 29 | 17 | 18 |
| ការអប់រំ និងការងារ | 17 | 45 | 22 | 13 | 4 | 0 |
| សាសនា | 2 | 18 | 33 | 23 | 15 | 10 |

តារាង៩: ចំណាត់ថ្នាក់អាទិភាពជីវិតរបស់មនុស្សជំនាន់មុន (%) (N=១២០២)

| | ចំណាត់ថ្នាក់ទី1 | ចំណាត់ថ្នាក់ទី2 | ចំណាត់ថ្នាក់ទី3 | ចំណាត់ថ្នាក់ទី4 | ចំណាត់ថ្នាក់ទី5 | ចំណាត់ថ្នាក់ទី6 |
|---|---|---|---|---|---|---|
| មិត្តភក្តិ | 1 | 6 | 10 | 18 | 38 | 21 |
| ការកម្សាន្ត | 0 | 2 | 6 | 11 | 26 | 54 |
| គ្រួសារ | 65 | 21 | 10 | 4 | 1 | 0 |
| នយោបាយ/សហគមន៍ | 6 | 11 | 19 | 28 | 20 | 17 |
| ការអប់រំ និងការងារ | 16 | 28 | 28 | 21 | 7 | 1 |
| សាសនា | 12 | 31 | 28 | 17 | 9 | 7 |

តារាង១០៖ ក្នុង ១ខែកន្លងទៅនេះ តើអ្នកធ្លាប់ចូលរួមសកម្មភាពណាខ្លះ (%)? (N=១៦០០)

| ប្រភេទសកម្មភាព | សរុប | ក្រុមអាយុ | |
|---|---|---|---|
| | | យុវជន | មនុស្សជំនាន់មុន |
| សិល្បៈ និងវប្បធម៌ | 9 | 9 | 8 |
| កីឡា | 14 | 19 | 13 |
| បណ្តុះបណ្តាល/ហាត់ការ | 5 | 5 | 5 |
| ការងារស្ម័គ្រចិត្ត | 10 | 8 | 11 |
| ក្លឹប និងសមាគម | 5 | 4 | 5 |
| សកម្មភាពសាសនា | 80 | 66 | 84 |
| សកម្មភាពនយោបាយ | 17 | 7 | 20 |
| មិនធ្លាប់ចូលរួមមួយណាទេ | 15 | 24 | 12 |

អ្នកឆ្លើយសម្ភាសន៍ភាគច្រើនប្រើពេលទំនេរសម្រាប់សកម្មភាពសាសនា ច្រើនជាងសកម្មភាពសង្គម និងកម្សាន្ត។ អ្នកឆ្លើយសម្ភាសន៍ ៨០% (មនុស្សជំនាន់មុន ៨៤% យុវជន ៦៦%) រាយការណ៍ថាគាត់បានចូលរួមក្នុងសកម្មភាពសាសនា។ មនុស្សជំនាន់មុនមានចូលរួមក្នុងនយោបាយ សមាគម និងការងារស្ម័គ្រចិត្ត ច្រើនជាងយុវជន។ ជាក់ស្តែងមានមនុស្សជំនាន់មុន ២០% ចំណាយពេលលើសកម្មភាពនយោបាយ រីឯយុវជនមានត្រឹម ៧% ។ ស្រដៀងគ្នាដែរ មានមនុស្សជំនាន់មុន ច្រើនជាងយុវជន ដែលចំណាយពេលសម្រាប់ ការងារស្ម័គ្រចិត្ត (មនុស្សជំនាន់មុន ១១% យុវជន ៨%) និងចូលរួមក្នុងសកម្មភាពក្លឹបនិងសមាគម (មនុស្សជំនាន់មុន ៥% យុវជន ៤%) ។ អ្នកឆ្លើយសម្ភាសន៍ ១៥% (មនុស្សជំនាន់មុន ១២% និង យុវជន ២៤%) មិនបានចូលរួមក្នុងសកម្មភាពទាំងអស់នេះទេ។

## ៤.៣. ឥរិយាបថចំពោះសមភាពយេនឌ័រ ការផ្សារភ្ជាប់ និងការគោរព

### *របកគំហើញសំខាន់ៗ*

- អ្នកឆ្លើយសម្ភាសន៍ភាគច្រើន (៧៥%) គាំទ្រឲ្យមានឱកាសស្មើភាពគ្នាសម្រាប់ស្ត្រី និងបុរស ក្នុងការទទួលបានការអប់រំកម្រិតឧត្តមសិក្សា។ មានយុវជនច្រើនជាងមនុស្សជំនាន់មុន ដែលគាំទ្រការផ្តល់ឱកាសស្មើភាពគ្នាដល់ស្ត្រីក្នុងការទទួលបានការអប់រំកម្រិតឧត្តមសិក្សា។ ជាក់ស្តែង មានយុវជន ៨២% គាំទ្រ និង ១៨% មិនគាំទ្រ ចំណែកឯមនុស្សជំនាន់មុនមាន ៧៣% គាំទ្រ និង ២៧% មិនគាំទ្រ។
- ការគាំទ្រដល់ភាពជាអ្នកដឹកនាំរបស់ស្ត្រី មានលក្ខណៈវិជ្ជមានគួរឲ្យពេញចិត្ត (៥៨%) ទោះបីជាមានអ្នកមិនគាំទ្ររហូតដល់ ៤២% ក្តី។ រវាងមនុស្សជំនាន់មុននឹងយុវជន មិនមានមតិខុសប្លែកគ្នាទេទាក់ទងនឹងឥរិយាបថចំពោះការដឹកនាំរបស់ស្ត្រី ក្នុងនេះមាន បុរស ៦៣% និងអ្នករស់នៅទីប្រជុំជន ៦៦% ដែលគាំទ្រដល់ភាពជាអ្នកដឹកនាំរបស់ស្ត្រី គឺច្រើនជាង ស្ត្រី (៥៥%) និង អ្នករស់នៅជនបទ (៥៥%) ។
- អ្នកឆ្លើយសម្ភាសន៍មានការផ្សារភ្ជាប់ខ្លាំងជាមួយនឹង សាសនា (៨៧%) សហគមន៍ (៧០%) និងប្រទេសជាតិ (៥៩%) ។ ជារួម មនុស្សជំនាន់មុនមានការផ្សារភ្ជាប់ជាមួយទិដ្ឋភាពទាំងបីខាងលើ ខ្លាំងជាងយុវជន។
- អ្នកឆ្លើយសម្ភាសន៍ភាគច្រើន (៨៦%) គោរពមេឃុំ។ ការគោរពនេះមានលក្ខណៈប្រហាក់ប្រហែលគ្នាទាំងសម្រាប់យុវជន (៨៥%) មនុស្សជំនាន់មុន (៨៦%) ស្ត្រី (៨៨%) និង បុរស (៨៣%) ។

### *៤.៣.១ សមភាពយេនឌ័រ*

អង្កេតនេះព្យាយាមស្វែងយល់ពីផលប៉ះពាល់នៃការផ្លាស់ប្តូរសេដ្ឋកិច្ចសង្គម និងតំបន់ភូមិសាស្ត្រទៅលើឥរិយាបថក្នុងបញ្ហា យេនឌ័រ សាសនា ប្រទេសជាតិ ការគោរពអាជ្ញាធរ និងពីទស្សនៈរបស់ប្រជាជនលើភាពដឹកនាំរបស់ស្ត្រី។

តបនឹងសំណួរថា តើបុរស និងស្ត្រី គួរទទួលបានឱកាសស្មើភាពគ្នាឬទេ សម្រាប់ការអប់រំកម្រិតឧត្តមសិក្សាដែរ? អ្នកឆ្លើយសម្ភាសន៍ភាគច្រើន (៧៥%) យល់ថា ស្ត្រី និងបុរស គួរទទួលបានឱកាសដូចគ្នាសម្រាប់ការអប់រំកម្រិតឧត្តមសិក្សា។ ការយល់ឃើញបែបនេះ មានច្រើនដូចគ្នាក្នុងចំណោម យុវជន មនុស្សជំនាន់មុន អ្នករស់នៅជនបទ អ្នករស់នៅទីប្រជុំជន និងទាំងបុរស និងស្ត្រី។ យុវជន ៨២% និង មនុស្សជំនាន់មុន ៧៣% មិនយល់ស្របទេថា "បុរសមានលក្ខណៈប្រសើរជាងស្ត្រី ដើម្បីទទួលបានការអប់រំកម្រិតមឧត្តមសិក្សា"។ ការគាំទ្រឲ្យមានឱកាសអប់រំស្មើភាពគ្នា ក៏មានច្រើនណាស់ដែរទាំងក្នុងចំណោមអ្នករស់នៅជនបទ និងនៅទីប្រជុំជន ដោយអ្នករស់នៅទីប្រជុំជនផ្តល់ការគាំទ្រ ១០% ច្រើនជាងអ្នករស់នៅជនបទ។

រូបភាព១០៖ តើអ្នកយល់ស្របដែរថា បុរសមានលក្ខណៈប្រសើរជាងស្ត្រី ដើម្បីទៅសិក្សានៅសាកលវិទ្យាល័យ? (N=១៦០០)




តបនឹងការលើកឡើងថា យេនឌ័រជាឧបសគ្គរារាំងជោគជ័យ អ្នកឆ្លើយសម្ភាសន៍ភាគច្រើន (៧១%) មិនយល់ស្របទេ ហើយក្នុងនោះមាន ៧៧% នៃយុវជន និង ៦៩% នៃមនុស្សជំនាន់មុន។ រវាងអ្នករស់នៅជនបទនឹងអ្នករស់នៅទីប្រជុំជន និង រវាងបុរសនឹងស្ត្រី មានការយល់ឃើញខុសគ្នាច្រើន។ អ្នករស់នៅទីប្រជុំជន (៨១%) និង អ្នករស់នៅជនបទ (៦៧%) មិនយល់ស្របទេថា យេនឌ័រជាឧបសគ្គរារាំងជោគជ័យ។ ប៉ុន្តែមានស្ត្រី ៣៤% និង បុរស ២២% យល់ថា ពិតជាមានឧបសគ្គជាក់លាក់ផ្នែកយេនឌ័រដែលរារាំងដល់ជោគជ័យរបស់ខ្លួន។

រូបភាព១១៖ តើអ្នកយល់ស្របដែរថា យេនឌ័រជាឧបសគ្គរារាំងជោគជ័យរបស់អ្នកទេ? (N=១៦០០)




អ្នកឆ្លើយសម្ភាសន៍ក៏បានទទួលសំណួរអំពីទស្សនៈរបស់ខ្លួនចំពោះ ភាពជាអ្នកដឹកនាំរបស់ស្ត្រីដែរ។ អ្នកឆ្លើយសម្ភាសន៍ ៥៨% គាំទ្រស្ត្រីក្នុងតួនាទីជាអ្នកដឹកនាំ ទោះបីនៅមានការរារែកច្រើននៅពេលឆ្លើយសំណួរនេះក្តី។ យុវជន ៥៧% និង មនុស្សជំនាន់មុន ៥៨% គាំទ្រដល់អ្នកដឹកនាំជាស្ត្រី រីឯ យុវជន ៤៣% និង មនុស្សជំនាន់មុន ៤២% មិនគាំទ្រទេ។ ការគាំទ្រដល់ស្ត្រីក្នុងតួនាទីជាអ្នកធ្វើការសម្រេចចិត្ត ឃើញមានច្រើនជាងក្នុងចំណោម អ្នកនៅទីប្រជុំជន ស្ត្រី និង អ្នកបានទទួលការអប់រំ បើធៀបនឹង អ្នករស់នៅជនបទ បុរស និងអ្នកមានការអប់រំទាប ក្នុងនោះមានអ្នករស់នៅទីប្រជុំជន ៦៦% ផ្តល់ការគាំទ្រ ធៀបនឹង អ្នករស់នៅជនបទ ត្រឹម ៥៥% ។

រូបភាព១២៖ តើអ្នកយល់ស្របដែរថា បុរសធ្វើជាអ្នកដឹកនាំបានល្អជាងស្ត្រី? (N=១៦០០)




មានអ្នកឆ្លើយសម្ភាសន៍តិចនាក់ណាស់ (១៤%) ដែលយល់ស្របឲ្យ បុរស និងនារីមានទំនាក់ទំនងស្នេហាមុនរៀបអាពាហ៍ពិពាហ៍។ រូបភាព១៣ បង្ហាញថា អ្នកឆ្លើយសម្ភាសន៍ភាគច្រើន (៨៦%) មិនយល់ស្របឲ្យមានទំនាក់ទំនងស្នេហាមុនរៀបអាពាហ៍ពិពាហ៍ទេ។ យុវជន ៨៧% និង មនុស្សជំនាន់មុន ៨៥% មិនយល់ស្របទេនឹងការលើកឡើងថា "ដៃគូស្នេហាអាចរួមរស់ជាមួយគ្នាបានមុនរៀបអាពាហ៍ពិពាហ៍" ។ ស្ត្រី (៨៧%) មានច្រើនជាងបុរស (៨៣%) ដែលមិនយល់ស្របនឹងទំនាក់ទំនងដៃគូស្នេហាមុនពេលរៀបអាពាហ៍ពិពាហ៍។

រូបភាព១៣៖ តើអ្នកយល់ស្របដែរថា ដៃគូស្នេហាអាចរួមរស់មួយគ្នាបានមុនរៀបអាពាហ៍ពិពាហ៍? (N=១៦០០)



## ៤.៣.២ ការផ្សារភ្ជាប់នឹងសហគមន៍ ប្រទេសជាតិ និងសាសនា

ក្នុងការស្វែងយល់ពីចំណងផ្សារភ្ជាប់ជាមួយសហគមន៍ ប្រទេសជាតិ និងសាសនា អង្កេតនេះរកឃើញថា អ្នកឆ្លើយសម្ភាសន៍មានចំណងទាក់ទងជាមួយសាសនា ខ្លាំងជាងជាមួយ សហគមន៍ និងប្រទេសជាតិ។

រូបភាព១៤ បង្ហាញថា អ្នកឆ្លើយសម្ភាសន៍ ៥៩% មានចិត្តផ្សារភ្ជាប់ខ្លាំងជាមួយប្រទេសជាតិ ប៉ុន្តែទឹកចិត្តនេះ ចុះខ្សោយបន្តិចក្នុងចំណោមយុវជន បើធៀបនឹងមនុស្សជំនាន់មុន។ មនុស្សជំនាន់មុន ៦២% និងយុវជន ៥០% និយាយថា គាត់យកចិត្តទុកដាក់ខ្លាំងជាមួយប្រទេសជាតិ។ ម្យ៉ាងទៀត យុវជន ៤៣% និងមនុស្សជំនាន់មុន ៣១% ប្រាប់ថា គាត់យកចិត្តទុកដាក់តិចតួចនឹងបញ្ហាប្រទេសជាតិ។ អ្នករស់នៅជនបទ ៥៩% យកចិត្តទុកដាក់ខ្លាំងនឹង ប្រទេសជាតិ ធៀបនឹងអ្នករស់នៅទីប្រជុំជន ត្រឹម ៥៧% ។ តួលេខទាំងនេះ ខុសគ្នាតិចតួចទេ បើគិតតាមភេទ និងកម្រិត អប់រំរបស់អ្នកឆ្លើយសម្ភាសន៍។

រូបភាព១៤៖ តើអ្នកគិតគូរពីប្រទេសជាតិដល់កម្រិតណា? (N=១៦០០)




រូបភាព១៥៖ តើអ្នកមានការផ្សារភ្ជាប់នឹងសាសនាជិតស្និទ្ធប៉ុណ្ណា? (N=១៦០០)



អ្នកឆ្លើយសម្ភាសន៍ភាគច្រើនមានការផ្សារភ្ជាប់ខ្លាំងជាមួយ សាសនា (៨៧%) និង សហគមន៍ (៧០%) (រូបភាព ១៥ និង ១៦) ។ មនុស្សជំនាន់មុនមានការផ្សារភ្ជាប់ជាមួយសាសនា ខ្លាំងជាងជាមួយសហគមន៍។ មនុស្សជំនាន់មុន ៨៩% និង យុវជន ៨២% និយាយថា គាត់មានការផ្សារភ្ជាប់ជិតស្និទ្ធជាមួយសាសនា។ មនុស្សជំនាន់មុន ៧៣% និង យុវជន ៦២% និយាយថា គាត់មានការផ្សារភ្ជាប់ជិតស្និទ្ធជាមួយសហគមន៍។ ទស្សនៈខាងលើនេះ មិនសូវខុសគ្នាច្រើនទេ រវាងអ្នករស់នៅជនបទនឹងអ្នករស់នៅទីប្រជុំជន និង រវាងស្ត្រីនឹងបុរស។

រូបភាព១៦៖ តើអ្នកមានការផ្សារភ្ជាប់នឹងសហគមន៍ជិតស្និទ្ធប៉ុណ្ណា? (N=១៦០០)




### *៤.៣.៣ ការគោរពអាជ្ញាធរមូលដ្ឋាន*

អង្កេតបង្ហាញថា អ្នកឆ្លើយសម្ភាសន៍ភាគច្រើន (៨៦%) គោរពមេឃុំ/ចៅសង្កាត់។ ឥរិយាបថនេះមានលក្ខណៈប្រហាក់ប្រហែលគ្នាសម្រាប់ យុវជននិងមនុស្សជំនាន់មុន ជនបទនិងទីប្រជុំជន ស្ត្រីនិងបុរស។ យុវជន ៨៥% និង មនុស្សជំនាន់មុន ៨៦% និយាយថា គាត់គោរពមេឃុំ/ចៅសង្កាត់ ហើយ យុវជន ១៤% និង មនុស្សជំនាន់មុន ១៣% និយាយថា គាត់គោរពមេឃុំ/ចៅសង្កាត់តិចតួច។ ការគោរពមេឃុំ/ចៅសង្កាត់ ក្នុងចំណោមអ្នករស់នៅជនបទ និង ទីប្រជុំជន ក៏មានកម្រិតខ្ពស់ដែរ (អ្នករស់នៅជនបទ ៨៦% អ្នករស់នៅទីប្រជុំជន ៨៤%) ។ មានបុរស តិចជាងស្ត្រី ដែលនិយាយថា គាត់គោរពមេឃុំ/ចៅសង្កាត់។ ក្រៅពីនេះ មានការខុសគ្នាតែបន្តិចបន្តួចក្នុងចំណោមអ្នកឆ្លើយសម្ភាសន៍ បើគិតតាម អាយុ តំបន់ភូមិសាស្ត្រ ឬ កម្រិតអប់រំ។ ជាទូទៅ ឥរិយាបថគោរពមេឃុំ/ចៅសង្កាត់ មានកម្រិតខ្ពស់។

រូបភាព១៧៖ តើអ្នកគោរពមេឃុំរបស់អ្នកដែរឬទេ? (N=១៦០០)




## ៤.៤. ការជឿទុកចិត្ត

### *របកគំហើញសំខាន់ៗ*

- យុវជន និងមនុស្សជំនាន់ មានការខុសប្លែកគ្នាតែបន្តិចបន្តួច ទាក់ទងនឹងកម្រិតទំនុកចិត្តទៅលើស្ថាប័នសាធារណៈ។ ក្នុងចំណោមជម្រើសទាំងប្រាំសម្រាប់បង្ហាញពីកម្រិតទំនុកចិត្តលើស្ថាប័នសាធារណៈ អង្កេតបានរកឃើញថា អ្នកផ្តល់សេវាសង្គម (សាលារៀន និងមន្ទីរពេទ្យ) ទទួលបានទំនុកចិត្តលំដាប់ទី១ រីឯអាជ្ញាធរមូលដ្ឋានស្ថិតនៅលំដាប់ទី២ ប៉ូលីស និងតុលាការស្ថិតនៅលំដាប់ទី៣ ប្រព័ន្ធផ្សព្វផ្សាយស្ថិតនៅលំដាប់ទី៤ និងអ្នកនយោបាយស្ថិតនៅលំដាប់ទី៥។
- យុវជន និងមនុស្សជំនាន់មុន មានទស្សនៈប្រហាក់ប្រហែលគ្នាទាក់ទងនឹងទំនុកចិត្តទៅលើបុគ្គល។ ទំនុកចិត្តរវាងបុគ្គលនឹងបុគ្គលនៅមានកម្រិតទាប ដោយសារចម្លើយស្តីពីទំនុកចិត្តទៅលើបុគ្គលបានបង្ហាញថា "ទុកចិត្តខ្លះ" វាមានច្រើនជាង "ទុកចិត្តខ្លាំង"។
- ទាំងយុវជន និងមនុស្សជំនាន់មុន មានទស្សនៈវិជ្ជមានទៅលើអង្គការសង្គមស៊ីវិល ដោយបង្ហាញនូវទំនុកចិត្តប្រហាក់ប្រហែលគ្នានឹងទំនុកចិត្តទៅលើគ្រួសារនិងសាច់ញាតិ។ ទស្សនៈជឿជាក់នេះមិនមានការខុសប្លែកគ្នាទេ បើសិនធ្វើការវិភាគតាម តំបន់ភូមិសាស្ត្រ និង យេនឌ័រ។

### *៤.៤.១ ការជឿទុកចិត្តលើស្ថាប័នសាធារណៈ*

អ្នកឆ្លើយសម្ភាសន៍មានការលំបាកក្នុងការឆ្លើយសំណួរទាក់ទងនឹង ការដាក់ចំណាត់ថ្នាក់ទំនុកចិត្តលើស្ថាប័នសាធារណៈ ដែលមានតាំងពីលំដាប់ ទី១ ដល់ ទី៥ (ទី១ គឺ ជឿទុកចិត្តខ្លាំង, ទី៥ គឺ ជឿទុកចិត្តតិចតួច)។ ទំនុកចិត្តលើស្ថាប័នសាធារណៈនៅមានកម្រិតទាប (តារាង១០) គឺដូចគ្នានឹងលទ្ធផលការសិក្សាពីមុនៗដែរ[២]។ សាលារៀននិងមន្ទីរពេទ្យ ជាស្ថាប័នសាធារណៈ ស្ថិតនៅលំដាប់ទី១ ដោយបានអ្នកឆ្លើយសម្ភាសន៍ ៣៦% "ទុកចិត្តខ្លាំង" បន្ទាប់មកអាជ្ញាធរមូលដ្ឋានឃុំស្ថិតនៅលំដាប់ទី២ (បាន ៣០%), ប៉ូលីសនិងតុលាការ ស្ថិតនៅលំដាប់ទី៣, ប្រព័ន្ធផ្សព្វផ្សាយនៅលំដាប់ទី៤ ហើយ អ្នកនយោបាយនៅលំដាប់ទី៥ ។ គួរកត់សម្គាល់ជាពិសេសថា អ្នកឆ្លើយសម្ភាសន៍ផ្តល់ទំនុកចិត្ត

[២] See Ninh, Kim and Roger Henke. 2005. Commune Councils in Cambodia: A National Survey on their Functions and Performance, with a Special Focus on Conflict Resolution. San Francisco: The Asia Foundation in collaboration with Center for Advanced Study.

ដល់ប៉ូលីសនិងតុលាការ ច្រើនជាង ប្រព័ន្ធផ្សព្វផ្សាយ និង អ្នកនយោបាយ។ ដោយឡែក មានអ្នកឆ្លើយសម្ភាសន៍ ៣% មិនផ្តល់ទំនុកចិត្តដល់ស្ថាប័នទាំងប្រាំនេះទេ។ ការផ្តល់ទំនុកចិត្តលើស្ថាប័នសាធារណៈរបស់យុវជន មានការខុសគ្នាតែបន្តិចបន្តួចពី មនុស្សជំនាន់មុន (តារាង១១)។ សាលារៀននិងមន្ទីរពេទ្យ (លំដាប់ទី១) ទទួលបានទំនុកចិត្តពីយុវជន ៣៨% និងមនុស្សជំនាន់មុន ៣៦%, អាជ្ញាធរមូលដ្ឋាន (លំដាប់ទី២) ទទួលបាន ២៩% និង ៣០% រៀងគ្នា រីឯ ប៉ូលីសនិងតុលាការ(លំដាប់ទី៣) ទទួលបាន ២៥% ស្មើគ្នាពីយុវជន និងមនុស្សជំនាន់មុន។

តារាង១១៖ តើបុគ្គល/ស្ថាប័នណា អ្នកជឿទុកចិត្តខ្លាំងជាងគេ? (N=១៦០០)

| | ចំណាត់ថ្នាក់ទី1 | ចំណាត់ថ្នាក់ទី2 | ចំណាត់ថ្នាក់ទី3 | ចំណាត់ថ្នាក់ទី4 | ចំណាត់ថ្នាក់ទី5 |
|---|---|---|---|---|---|
| ប្រព័ន្ធផ្សព្វផ្សាយ | 12 | 15 | 20 | 29 | 24 |
| អាជ្ញាធរមូលដ្ឋាន | 31 | 30 | 23 | 13 | 4 |
| ប៉ូលីស និងតុលាការ | 12 | 22 | 25 | 24 | 13 |
| សាលារៀន/មន្ទីរពេទ្យ | 36 | 26 | 23 | 13 | 5 |
| អ្នកនយោបាយ | 6 | 7 | 10 | 21 | 54 |
| មិនទុកចិត្តទាំងអស់ | 3 | 0 | 0 | 0 | 0 |

តារាង១២៖ តើបុគ្គល/ស្ថាប័នណា អ្នកជឿទុកចិត្តខ្លាំងជាងគេ? (N=១៦០០)

| | ចំណាត់ថ្នាក់ទី1 | | ចំណាត់ថ្នាក់ទី2 | | ចំណាត់ថ្នាក់ទី3 | | ចំណាត់ថ្នាក់ទី4 | | ចំណាត់ថ្នាក់ទី5 | |
|---|---|---|---|---|---|---|---|---|---|---|
| | យុវជន | មនុស្សជំនាន់មុន | យុវជន | មនុស្សជំនាន់មុន | យុវជន | មនុស្សជំនាន់មុន | យុវជន | មនុស្សជំនាន់មុន | យុវជន | មនុស្សជំនាន់មុន |
| ប្រព័ន្ធផ្សព្វផ្សាយ | 10 | 12 | 14 | 15 | 21 | 20 | 30 | 29 | 26 | 23 |
| អាជ្ញាធរមូលដ្ឋាន | 28 | 33 | 29 | 30 | 24 | 22 | 13 | 12 | 5 | 3 |
| ប៉ូលីស និងតុលាការ | 15 | 11 | 28 | 20 | 25 | 25 | 19 | 25 | 9 | 14 |
| សាលារៀន/មន្ទីរពេទ្យ | 38 | 36 | 23 | 28 | 20 | 24 | 13 | 13 | 8 | 4 |
| អ្នកនយោបាយ | 7 | 5 | 6 | 7 | 10 | 10 | 24 | 20 | 52 | 56 |
| មិនទុកចិត្តទាំងអស់ | 3 | 3 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |

### ៤.៤.២ ការជឿទុកចិត្តលើបុគ្គល

សម្រាប់ទំនុកចិត្តលើបុគ្គល អ្នកឆ្លើយសម្ភាសន៍ភាគច្រើនឲ្យចំណាត់ថ្នាក់ ជឿទុកចិត្តខ្លះ ជាជាង ទុកចិត្ត ឬ ទុកចិត្តខ្លាំង។ អ្នកឆ្លើយសម្ភាសន៍ប្រមាណ ៥០% ឲ្យចំណាត់ថ្នាក់ ទុកចិត្តខ្លះ ទៅលើ មិត្តភក្តិ អ្នករួមការងារ អ្នកជិតខាង និង សមាជិកគ្រួសារ។ តាមនេះ អ្នកឆ្លើយសម្ភាសន៍មិនសូវផ្តល់ទំនុកចិត្តពេញលេញទៅលើបុគ្គលដែលគាត់កំពុងមានទំនាក់ទំនងជាមួយនោះទេ។ អ្នកឆ្លើយសម្ភាសន៍មានគំនិតវិជ្ជមានលើអ្នកធ្វើការងារអភិវឌ្ឍន៍ ដោយផ្តល់ទំនុកចិត្តស្មើគ្នានឹង គ្រួសារនិងសាច់ញាតិដែរ។ អ្នកឆ្លើយសម្ភាសន៍ ៣១% ប្រាប់ថា គាត់ទុកចិត្ត ហើយ ១៧% ទៀតនិយាយថា គាត់ទុកចិត្តខ្លាំង លើអ្នកធ្វើការងារអភិវឌ្ឍន៍។ អ្នកឆ្លើយសម្ភាសន៍ទុកចិត្តលើ អ្នកនយោបាយ (២២%) ច្រើនជាង មិត្តភក្តិ (១១%) និង អ្នករួមការងារ (១៩%) ។ មនុស្សទាំងពីរជំនាន់ ខុសប្លែកគ្នាតែបន្តិចបន្តួចក្នុងការផ្តល់ទំនុកចិត្តដល់បុគ្គល ដោយយុវជននិងមនុស្សជំនាន់មុនភាគច្រើន មានត្រឹម ការទុកចិត្តខ្លះ ទៅលើ គ្រួសារ មិត្តភក្តិ អ្នកធ្វើការងារអភិវឌ្ឍន៍ និង អ្នកនយោបាយ។ កម្រិតអប់រំរបស់អ្នកឆ្លើយសម្ភាសន៍ មិនមានឥទ្ធិពលគួរឲ្យកត់សំគាល់ទេទៅលើការជឿទុកចិត្តលើបុគ្គល។

តារាង១៣៖ តើអ្នកទុកចិត្តប៉ុណ្ណាលើបុគ្គលទាំងនេះ? (%) (N=១៦០០)

| | មិនទុកចិត្តខ្លាំង | មិនទុកចិត្ត | ទុកចិត្តខ្លះ | ទុកចិត្ត | ទុកចិត្តខ្លាំង |
|---|---|---|---|---|---|
| សាច់ញាតិ | 3 | 5 | 50 | 20 | 22 |
| មិត្តភក្តិ | 9 | 18 | 59 | 11 | 3 |
| អ្នករួមការងារ | 7 | 15 | 54 | 19 | 6 |
| អ្នកជិតខាង | 5 | 13 | 52 | 22 | 8 |
| អ្នកធ្វើការងារអភិវឌ្ឍន៍ | 3 | 6 | 43 | 31 | 17 |
| អ្នកនយោបាយ | 6 | 12 | 47 | 22 | 13 |
| អ្នកមិនស្គាល់ | 73 | 22 | 5 | 0 | 0 |

តារាង១៤៖ តើអ្នកទុកចិត្តប៉ុណ្ណាលើបុគ្គលទាំងនេះ?(%) (N=១៥៩២)

| | មិនទុកចិត្តខ្លាំង | | មិនទុកចិត្ត | | ទុកចិត្តខ្លះ | | ទុកចិត្ត | | ទុកចិត្តខ្លាំង | |
|---|---|---|---|---|---|---|---|---|---|---|
| | យុវជន | មនុស្សជំនាន់មុន | យុវជន | មនុស្សជំនាន់មុន | យុវជន | មនុស្សជំនាន់មុន | យុវជន | មនុស្សជំនាន់មុន | យុវជន | មនុស្សជំនាន់មុន |
| សាច់ញាតិ | 2 | 3 | 4 | 5 | 52 | 50 | 23 | 19 | 20 | 23 |
| មិត្តភក្តិ | 8 | 10 | 15 | 19 | 65 | 56 | 10 | 11 | 2 | 3 |
| អ្នករួមការងារ | 6 | 7 | 13 | 16 | 58 | 5 | 17 | 19 | 5 | 6 |
| អ្នកជិតខាង | 6 | 4 | 18 | 11 | 53 | 52 | 18 | 23 | 5 | 9 |
| អ្នកធ្វើការងារអភិវឌ្ឍន៍ | 3 | 3 | 6 | 7 | 46 | 4 | 32 | 30 | 14 | 18 |
| អ្នកនយោបាយ | 5 | 6 | 11 | 12 | 52 | 46 | 22 | 22 | 10 | 15 |
| អ្នកមិនស្គាល់ | 65 | 76 | 29 | 20 | 6 | 4 | 0 | 0 | 0 | 0 |

## ៤.៥.ការយល់ដឹងផ្នែកនយោបាយ

### *របកគំហើញសំខាន់ៗ*

- អ្នកឆ្លើយសម្ភាសន៍ភាគច្រើន (៦៧%) ធ្លាប់ស្គាល់អ្នកនយោបាយថ្នាក់ជាតិ ក្នុងនោះ តួលេខយុវជន និងមនុស្សជំនាន់មុន មិនសូវមានការខុសប្លែកគ្នាខ្លាំងទេ ប៉ុន្តែ ស្ត្រី (៥៨%) ស្គាល់អ្នកនយោបាយថ្នាក់ជាតិ បានតិចជាង បុរស (៨០%)។
- អ្នកឆ្លើយសម្ភាសន៍ភាគច្រើន (៧៦%) មិនសូវស្គាល់ទេនូវស្ថាប័នកំពូលទាំងបី គឺមាន តុលាការ នីតិប្រតិបត្តិ និង នីតិបញ្ញត្តិ។ យុវជនស្គាល់ស្ថាប័នទាំងនេះ ប្រសើរជាងមនុស្សជំនាន់មុន។ ជាក់ស្តែង យុវជន ៦៨% និងមនុស្សជំនាន់មុន ៧៨% មិនស្គាល់ស្ថាប័នអំណាចកំពូលទាំងបីឡើយ។ មានស្ត្រី (៨៦%) ច្រើនជាងបុរស (៦១%) ដែលមិនស្គាល់ស្ថាប័នកំពូលទាំងបី។
- អ្នកឆ្លើយសម្ភាសន៍ច្រើនលើសលប់ (៩៩%) យល់ថា ការបោះឆ្នោតគឺជាកាតព្វកិច្ចរបស់ពលរដ្ឋ និងមានពួកគាត់ ៩៨% យល់ស្របខ្លាំងថា សន្លឹកឆ្នោតមានឥទ្ធិពលខ្លាំងទៅលើទិសដៅនៃការដឹកនាំប្រទេស។ យុវជន និងមនុស្សជំនាន់មុន មានទស្សនៈស្ទើរតែដូចគ្នាទាក់ទងនឹងការបោះឆ្នោត និងទិសដៅនៃការដឹកនាំប្រទេស។
- អ្នកឆ្លើយសម្ភាសន៍ គិតថា គ្រួសារមានឥទ្ធិពលសំខាន់ណាស់ទាក់ទងនឹងទស្សនៈនយោបាយរបស់គាត់ ហើយអ្នកនយោបាយ និងប្រព័ន្ធផ្សព្វផ្សាយមានឥទ្ធិពលសំខាន់បន្ទាប់។ យុវជន និងមនុស្សជំនាន់មុន មានទស្សនៈប្រហាក់ប្រហែលគ្នាក្នុងចំណុចនេះ។

### *៤.៥.១ ការយល់ដឹងពីអ្នកនយោបាយ និងស្ថាប័នកំពូល*

ក្នុងផ្នែកនេះ មានការស្វែងយល់ពី ឥរិយាបថទាក់ទងនឹងការបោះឆ្នោត និងចំណេះដឹងពីស្ថាប័នកំពូល។ រូបភាព១៨ បង្ហាញថា អ្នកឆ្លើយសម្ភាសន៍ពីរនាក់ក្នុងចំណោមបីនាក់ (៦៧%) ស្គាល់អ្នកនយោបាយថ្នាក់ជាតិ។

ការស្គាល់នេះមានកម្រិតប្រហាក់ប្រហែលគ្នាក្នុងចំណោមយុវជន និងមនុស្សជំនាន់មុន។ ប្រមាណ ១៨% នៃមនុស្សជំនាន់មុននិងយុវជន ស្គាល់អ្នកនយោបាយយ៉ាងហោចណាស់ម្នាក់ឬពីរនាក់ ហើយ ១៥% ទៀតមិនស្គាល់អ្នកនយោបាយណាទេ។ មានអ្នករស់នៅទីប្រជុំជន (៧៦%) ច្រើនជាង អ្នករស់នៅជនបទ (៦៤%) ដែលស្គាល់អ្នកនយោបាយថ្នាក់ជាតិដល់ទៅបីនាក់។ ភាពខុសគ្នាទាំងនេះក៏អាចឃើញច្បាស់បើគិតតាមយេនឌ័រដែរ ព្រោះមាន បុរស (៨០%) ច្រើនជាង ស្ត្រី (៥៨%) ដែលស្គាល់អ្នកនយោបាយថ្នាក់ជាតិ។ ការស្គាល់នេះ ក៏អាស្រ័យលើកម្រិតអប់រំរបស់អ្នកឆ្លើយសម្ភាសន៍ ដោយក្នុងនោះ អ្នកមានការអប់រំច្រើន ស្គាល់អ្នកនយោបាយថ្នាក់ជាតិបានច្រើនជាង អ្នកមានការអប់រំតិច។

អ្នកឆ្លើយសម្ភាសន៍មានចំណេះដឹងកម្រិតខ្ពស់លើអ្នកនយោបាយក៏ពិតមែន ប៉ុន្តែមនុស្សភាគច្រើន (៧៦%) មិនស្គាល់ពីស្ថាប័នកំពូលទាំងបីទេ ព្រោះមានអ្នកឆ្លើយសម្ភាសន៍ត្រឹម ១៤% ដែលអាចប្រាប់ឈ្មោះស្ថាប័នកំពូលទាំងបីបាន ហើយ ១០% ទៀត ស្គាល់ឈ្មោះស្ថាប័នតែមួយ ឬពីរប៉ុណ្ណោះ។ មានយុវជន ច្រើនជាង មនុស្សជំនាន់មុន ដែលស្គាល់ស្ថាប័នកំពូលទាំងបី។ ជាក់ស្តែង យុវជន ២០% និង មនុស្សជំនាន់មុន ១២% អាចប្រាប់ពីស្ថាប័នកំពូលទាំងបីបានយ៉ាងត្រឹមត្រូវ។ មនុស្សជំនាន់មុន ៧៨% និងយុវជន ៦៨% មិនស្គាល់ស្ថាប័នកំពូលទាំងបីទេ។ រវាងអ្នករស់នៅជនបទ នឹងអ្នករស់នៅទីប្រជុំជន ក៏មានគម្លាតគ្នាខ្លាំងដែរ ព្រោះអ្នករស់នៅជនបទ ៨២% មិនស្គាល់ពីស្ថាប័នកំពូលទាំងបីទេ ធៀបនឹងអ្នករស់នៅទីប្រជុំជនត្រឹម ៥៩% ។ ស្ត្រី (៨៦%) មានច្រើនជាង បុរស (៦១ភាគរយ) ដែលមិនស្គាល់ស្ថាប័នទាំងបី។

រូបភាព១៨៖ តើអ្នកអាចរៀបរាប់ឈ្មោះអ្នកនយោបាយបីនាក់បានឬទេ (ដោយមិនរួមបញ្ចូលនាយករដ្ឋមន្ត្រី)? (N=១៦០០)




រូបភាព១៩៖ តើស្ថាប័នកំពូលទាំងបីមានអ្វីខ្លះ? (N=១៦០០)



### ៤.៥.២ ការបោះឆ្នោត

អង្កេតបានសាកសួរថា តើអ្នកឆ្លើយសម្ភាសន៍ឲ្យតម្លៃ និងជឿទុកចិត្តលើការបោះឆ្នោតឬទេ។ ក្នុងនេះ ស្ទើរគ្រប់គ្នា (៩៩%) យល់ថា ការបោះឆ្នោតជាកាតព្វកិច្ចរបស់ពលរដ្ឋ។ ៩៩% នៃយុវជននិងមនុស្សជំនាន់មុន យល់ស្របនឹងការលើកឡើងថា "ខ្ញុំមានកាតព្វកិច្ចទៅបោះឆ្នោត" ។ ទស្សនៈនេះមិនប្រែប្រួលខុសគ្នាច្រើនទេ បើសិនគិតតាម យេនឌ័រ និងទីតាំងភូមិសាស្ត្ររស់នៅ ។

ម្យ៉ាងទៀត អ្នកឆ្លើយសម្ភាសន៍ស្ទើរគ្រប់គ្នា (៩៨%) ជឿជាក់ថា សន្លឹកឆ្នោតរបស់គាត់មានឥទ្ធិពលសំខាន់ណាស់សម្រាប់អនាគតប្រទេសជាតិ។ ទស្សនៈបែបនេះឃើញមានដូចគ្នា ទាំងក្នុងចំណោមយុវជន និងមនុស្សជំនាន់មុន ហើយក៏ប្រែប្រួលខុសគ្នាច្រើនដែរ បើសិនធ្វើវិភាគតាមយេនឌ័រ និងទីតាំងភូមិសាស្ត្ររស់នៅ។

រូបភាព២០៖ តើអ្នកយល់ស្របឬទេនឹងការលើកឡើងថា ខ្ញុំមានកាតព្វកិច្ចទៅបោះឆ្នោត? (N=១៦០០)




រូបភាព២១៖ តើអ្នកយល់ស្របឬទេនឹងការលើកឡើងថា សន្លឹកឆ្នោតរបស់ខ្ញុំអាចមានឥទ្ធិពលដល់អនាគតប្រទេសជាតិខ្ញុំ? (N=១៦០០)



### ៤.៥.៣ ឥទ្ធិពលនយោបាយ

ដោយមានការស្នើឲ្យ អ្នកឆ្លើយសម្ភាសន៍ធ្វើការកំណត់មនុស្សដែលមានឥទ្ធិពលខ្លាំងជាងគេទៅលើទស្សនៈនយោបាយរបស់ខ្លួននោះ អង្កេតបានរកឃើញថា គ្រួសារ និងអ្នកនយោបាយ មានឥទ្ធិពលខ្លាំងជាងគេទៅលើទស្សនៈនយោបាយរបស់យុវជន និងមនុស្សជំនាន់មុន បន្ទាប់មក ប្រព័ន្ធផ្សព្វផ្សាយស្ថិតនៅលំដាប់ទី៣ គ្រូបង្រៀនស្ថិតនៅលំដាប់ទី៤ សាសនានៅលំដាប់ទី៥ ហើយ អ្នករួមការងារនៅលំដាប់ទី៦។ រវាងមនុស្សជំនាន់មុន នឹងយុវជន មានការខុសគ្នាបន្តិចបន្តួចក្នុងការកំណត់ អ្នកមានឥទ្ធិពលនយោបាយនេះ។ សម្រាប់យុវជន គ្រួសារស្ថិតនៅលំដាប់ទី១ អ្នកនយោបាយនៅលំដាប់ទី២ ហើយប្រព័ន្ធផ្សព្វផ្សាយនៅលំដាប់ទី៣។ មនុស្សជំនាន់មុន តែងចាត់ទុកគ្រួសារ និងអ្នកនយោបាយ ជាប្រភពមានឥទ្ធិពលខ្លាំងជាងគេទៅលើការសម្រេចចិត្តផ្នែកនយោបាយរបស់គាត់។ រីឯ សាសនា អ្នករួមការងារ និង គ្រូបង្រៀន មិនសូវមានឥទ្ធិពលទៅលើទស្សនៈនយោបាយរបស់ យុវជន និងមនុស្សជំនាន់មុនទេ។

តារាង១៥៖ តើនរណាមានឥទ្ធិពលខ្លាំងជាងគេទៅលើទស្សនៈនយោបាយរបស់អ្នក?(%)(N=១៤៣៣)

| | ចំណាត់ថ្នាក់ទី1 | | ចំណាត់ថ្នាក់ទី2 | | ចំណាត់ថ្នាក់ទី3 | | ចំណាត់ថ្នាក់ទី4 | | ចំណាត់ថ្នាក់ទី5 | | ចំណាត់ថ្នាក់ទី6 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | យុវជន | មនុស្សជំនាន់មុន | យុវជន | មនុស្សជំនាន់មុន | យុវជន | មនុស្សជំនាន់មុន | យុវជន | មនុស្សជំនាន់មុន | យុវជន | មនុស្សជំនាន់មុន | យុវជន | មនុស្សជំនាន់មុន |
| គ្រួសារ | 32 | 28 | 18 | 19 | 17 | 19 | 19 | 20 | 15 | 18 | 8 | 12 |
| អ្នកនយោបាយ | 31 | 28 | 32 | 31 | 19 | 20 | 12 | 12 | 6 | 11 | 0 | 0 |
| ប្រព័ន្ធផ្សព្វផ្សាយ | 22 | 25 | 18 | 18 | 19 | 14 | 13 | 16 | 16 | 18 | 17 | 15 |
| គ្រូបង្រៀន/អប់រំ | 10 | 10 | 17 | 15 | 19 | 17 | 20 | 19 | 20 | 16 | 7 | 9 |
| សាសនា | 3 | 7 | 9 | 11 | 10 | 15 | 17 | 13 | 17 | 15 | 41 | 28 |
| អ្នកធ្វើការជាមួយគ្នា/មិត្តភក្តិ | 3 | 2 | 6 | 6 | 16 | 14 | 20 | 21 | 27 | 21 | 28 | 36 |

## ៤.៦. ការចូលរួមនៅកម្រិតមូលដ្ឋាន

### របកគំហើញសំខាន់ៗ

- អ្នកឆ្លើយសម្ភាសន៍ (៧៣%) ធ្លាប់ចូលរួមប្រជុំនៅកម្រិតមូលដ្ឋាន។ យុវជនមិនសូវសកម្មដូចមនុស្សជំនាន់មុនទេ ក្នុងការចូលរួមក្នុងកិច្ចការអភិវឌ្ឍន៍នៅកម្រិតមូលដ្ឋាន ដូចជាតាមដានគម្រោងអភិវឌ្ឍន៍ឃុំសង្កាត់ និងវេទិកាសាធារណៈ ជាដើម ប៉ុន្តែយុវជនសកម្មជាងក្នុងការចូលរួមប្រជុំនៅសាលារៀន និងមណ្ឌលសុខភាព។
- ស្ត្រីមិនសូវចូលរួមការប្រជុំនៅកម្រិតមូលដ្ឋានទេ លើកលែងតែ ការប្រជុំនៅមណ្ឌលសុខភាព ដែរមានស្ត្រីដល់ ៤៦% ចូលរួមប្រជុំនៅមណ្ឌលសុខភាព ធៀបនឹងបុរសត្រឹម ៣៨%។ ស្ត្រីមានត្រឹម ៣៣% ដែលចូលរួមប្រជុំនៅថ្នាក់ឃុំ ធៀបនឹងបុរសដែលដល់ ៤៤%។
- អ្នកឆ្លើយសម្ភាសន៍ម្នាក់ក្នុងចំណោមបីនាក់បានរាយការណ៍ថា ពួកគាត់ធ្លាប់ចូលរួមបញ្ចេញមតិយោបល់ក្នុងពេលប្រជុំនៅថ្នាក់មូលដ្ឋាន។ មានយុវជន (៣៣%) ច្រើនជាង មនុស្សជំនាន់មុន (៣១%) ដែលធ្លាប់ចូលរួមបញ្ចេញមតិយោបល់នៅពេលប្រជុំថ្នាក់មូលដ្ឋាន។
- យុវជន ៦៧% និងមនុស្សជំនាន់មុន ៦៩% មិនឆ្លើយសំណួរទេនៅពេលគេសាកសួរថា តើគាត់មានការបារម្ភឬទេ ក្នុងការសួរសំណួរនៅពេលប្រជុំកម្រិតមូលដ្ឋាន?។ ការមិនឆ្លើយបែបនេះបង្ហាញថា ប្រជាជនកម្ពុជាជាទូទៅមានភាពស្ទាក់ស្ទើរក្នុងការបញ្ចេញយោបល់ និងចូលរួមក្នុងការពិភាក្សាជាសាធារណៈ។
- អ្នកឆ្លើយសម្ភាសន៍ (យុវជន ៨៩% និង មនុស្សជំនាន់មុន ៨៨%) ចង់ឲ្យឃុំ/សង្កាត់ផ្តល់ច្រើនថែមទៀតនូវសេវាសាធារណៈ និងគម្រោងអភិវឌ្ឍន៍កម្រិតមូលដ្ឋាន ដោយប្រើប្រាស់មូលនិធិឃុំ/សង្កាត់។ សេវាសាធារណៈ រួមមាន ការកែលំអនូវហេដ្ឋារចនាសម្ព័ន្ធនៅតាមមូលដ្ឋាន សេវាសង្គម និងកម្មវិធីគាំពារសង្គម។

### ៤.៦.១ ការប្រជុំនៅកម្រិតមូលដ្ឋាន

របៀបនៃការកែទម្រង់វិមជ្ឈការ មានសារៈសំខាន់សម្រាប់ការពិភាក្សាផ្នែកគោលនយោបាយ ព្រោះអាចជួយសម្រួលប្រជាជនកម្ពុជាក្នុងការធ្វើទំនាក់ទំនងជាមួយមន្ត្រីរាជការ និងអាចមានឥទ្ធិពលទៅលើការសម្រេចចិត្តនៅកម្រិតមូលដ្ឋាន ។ ក្នុងអង្កេតនេះ មានសំណួរជាច្រើនដល់អ្នកឆ្លើយសម្ភាសន៍ ពីបទពិសោធន៍របស់គាត់ក្នុងការចូលរួមប្រជុំនៅកម្រិតមូលដ្ឋាន។

អ្នកឆ្លើយសម្ភាសន៍ភាគច្រើន (៧៣%) ធ្លាប់មានបទពិសោធន៍ចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់នៅកម្រិតមូលដ្ឋាន។ យុវជន (៦៣%) មានការចូលរួមប្រជុំនៅកម្រិតមូលដ្ឋាន តិចជាងមនុស្សជំនាន់មុន (៧៦%) ។ បុរស (៧៦%) សកម្មជាង ស្ត្រី (៧១%) ក្នុងការចូលរួមប្រជុំនៅកម្រិតមូលដ្ឋាន។ អ្នកចូលរួមប្រជុំនៅកម្រិតមូលដ្ឋាននេះ មានចំនួនខុសគ្នាច្រើន រវាងអ្នករស់នៅជនបទ (៧៧%) នឹងអ្នករស់នៅទីប្រជុំជន (៦៣%) ។ តួលេខនេះមានកម្រិតខ្ពស់ក៏ពិតមែន ប៉ុន្តែនៅមានម្នាក់ក្នុងចំណោមបួននាក់ (២៧%) ដែលមិនបានចូលរួមក្នុងការប្រជុំនៅកម្រិតមូលដ្ឋាន។

រូបភាព២២៖ តើអ្នកធ្លាប់ចូលរួមសកម្មភាព ឬការប្រជុំនៅថ្នាក់មូលដ្ឋានឬទេ? (N=១៦០០)




តបនឹងសំណួរលំអិតពីប្រភេទនៃការប្រជុំកម្រិតមូលដ្ឋាន អ្នកឆ្លើយសម្ភាសន៍ប្រាប់ថា ភាគច្រើនធ្លាប់ចូលរួមក្នុងសកម្មភាពកម្រិតមូលដ្ឋាននៅថ្នាក់ភូមិ និងមានតិចនាក់ដែលធ្លាប់ចូលរួមនៅថ្នាក់ឃុំ ពោលគឺ មាន ៥៨% ធ្លាប់ចូលរួមប្រជុំកម្រិតមូលដ្ឋានថ្នាក់ភូមិ ៣៧% ធ្លាប់ចូលរួមប្រជុំថ្នាក់ឃុំ និង ២១% ធ្លាប់ចូលរួមតាមដានគម្រោងអភិវឌ្ឍន៍ឃុំសង្កាត់។ ម្យ៉ាងទៀត មាន ១៧% ធ្លាប់បានចូលរួមប្រជុំក្នុងវេទិកាសាធារណៈ។ ការចូលរួមមានកម្រិតខ្ពស់រហូតដល់ ៣១% សម្រាប់ការប្រជុំនៅសាលារៀន និងដល់ ៤៣% សម្រាប់ការប្រជុំនៅមណ្ឌលសុខភាព។

យុវជនដែលបានចូលរួមក្នុងការប្រជុំកម្រិតមូលដ្ឋាន មានតិចជាងមនុស្សជំនាន់មុន លើកលែងតែការប្រជុំនៅសាលារៀន។ ជាក់ស្តែង ក្នុងការប្រជុំថ្នាក់ឃុំ មានយុវជនម្នាក់ក្នុងចំណោមបីនាក់បានចូលរួម ហើយក្នុងការប្រជុំកម្រិតមូលដ្ឋានថ្នាក់ភូមិ មានយុវជន (៣៧%) តិចជាងមនុស្សជំនាន់មុន (៦៥%) ដែលទៅចូលរួម។ ការសិក្សាបានរកឃើញនូវ គម្លាតគ្នាយ៉ាងធំរវាងយុវជននឹងមនុស្សជំនាន់មុន ក្នុងការចូលរួមប្រជុំថ្នាក់ឃុំ ពោលគឺ យុវជនមានត្រឹម ១៩% ធៀបនឹង មនុស្សជំនាន់មុនមានដល់ ៤៣% ។ យុវជន ក៏ចូលរួមតិចជាងមនុស្សជំនាន់មុនដែរ ក្នុងការប្រជុំតាមដានគម្រោងអភិវឌ្ឍន៍ឃុំសង្កាត់ និងក្នុងវេទិកាសាធារណៈ។ ប៉ុន្តែយុវជនបានចូលរួមប្រជុំច្រើននៅសាលារៀន និងមណ្ឌលសុខភាព។ ក្នុងនេះ យុវជន ៣៧% និង មនុស្សជំនាន់មុន ៣០% បានចូលរួមប្រជុំនៅសាលារៀន ហើយយុវជន ៣៧% និងមនុស្សជំនាន់មុន ៤៥% បានចូលរួមប្រជុំនៅមណ្ឌលសុខភាព។

ការចូលរួមប្រជុំនៅកម្រិតមូលដ្ឋាន ប្រែប្រួលខុសគ្នាច្រើនបើគិតតាមយេនឌ័រ។ ក្នុងការប្រជុំកម្រិតមូលដ្ឋានថ្នាក់ភូមិ មានស្ត្រី ៥៧% និង បុរស ៦០% ចូលរួម ហើយក្នុងការប្រជុំនៅសាលារៀន មានស្ត្រី ៣១% និង បុរស ៣២% ចូលរួម។ ក្នុងការប្រជុំនៅកម្រិតមូលដ្ឋានថ្នាក់ឃុំ ស្ត្រីមានការចូលរួមតិចជាងបុរស។ ក្នុងនេះ បុរសតែងទៅប្រជុំថ្នាក់ឃុំ ដើម្បីតាមដានគម្រោងអភិវឌ្ឍន៍ឃុំសង្កាត់ និងចូលរួមក្នុងវេទិកាសាធារណៈ បានច្រើនជាងស្ត្រី។ ជាក់ស្តែង មានស្ត្រី ៣៣% បានចូលរួមប្រជុំកម្រិតមូលដ្ឋានថ្នាក់ឃុំ ធៀបនឹងបុរសដល់ ៤៤% ប៉ុន្តែ ស្ត្រី (៤៦%) មានច្រើនជាង បុរស (៣៣%) វិញ ដែលទៅចូលរួមប្រជុំនៅមណ្ឌលសុខភាព ។

អ្នករស់នៅទីប្រជុំជន តែងទៅចូលរួមប្រជុំកម្រិតមូលដ្ឋាន និងវេទិកាសាធារណៈ បានតិចជាងអ្នករស់នៅជនបទ ដោយសារហេតុផលជាច្រើន ដូចជា នៅទីប្រជុំជនមានការរៀបចំប្រជុំតិចជាងនៅតំបន់ជនបទ ពេលវេលានៃការប្រជុំវាប៉ះពាល់ជាមួយការងារ ជាដើម ទោះបីជាអ្នករស់នៅទីប្រជុំជនបានទទួលការអញ្ជើញឲ្យទៅចូលរួមប្រជុំកម្រិតមូលដ្ឋានក្តី។

តារាង១៦៖ តើអ្នកធ្លាប់ចូលរួមក្នុងសកម្មភាពនៅថ្នាក់មូលដ្ឋានអ្វីខ្លះ? (%) (N=១៦០០)

| | សរុប | ក្រុមអាយុ | | ភេទ | | តំបន់ | |
|---|---|---|---|---|---|---|---|
| | | យុវជន | មនុស្សជំនាន់មុន | បុរស | ស្ត្រី | ជនបទ | ទីប្រជុំជន |
| ប្រជុំភូមិ | 58 | 37 | 65 | 60 | 57 | 63 | 46 |
| ប្រជុំឃុំ/សង្កាត់ | 37 | 19 | 43 | 44 | 33 | 37 | 38 |
| តាមដានគម្រោងអភិវឌ្ឍន៍ឃុំសង្កាត់ | 21 | 13 | 23 | 27 | 16 | 22 | 18 |
| ប្រជុំនៅសាលារៀន | 31 | 37 | 30 | 32 | 31 | 34 | 25 |
| ប្រជុំមណ្ឌល | 43 | 37 | 45 | 38 | 46 | 48 | 28 |
| វេទិកាសាធារណៈ | 17 | 10 | 20 | 23 | 13 | 18 | 15 |

ការចូលរួមមតិយោបល់ និងការលើកសំណួរក្នុងពេលប្រជុំកម្រិតមូលដ្ឋាន មិនសូវមានច្រើនទេ។ អ្នកឆ្លើយសម្ភាសន៍ម្នាក់ក្នុងចំណោមបីនាក់ ធ្លាប់លើកសំណួរក្នុងពេលចូលរួមប្រជុំនៅកម្រិតមូលដ្ឋាន ហើយ ៦៩% ទៀត ធ្លាប់បានចូលរួមប្រជុំប៉ុន្តែមិនបានបញ្ចេញមតិយោបល់ទេ។ ម្យ៉ាងទៀត យុវបុរស និងអ្នកនៅទីប្រជុំជន តែងហ៊ានសួរសំណួរក្នុងពេលប្រជុំ ច្រើនជាង មនុស្សជំនាន់មុន ស្ត្រី និង អ្នករស់នៅតំបន់ជនបទ។

រូបភាព២៣៖ បើធ្លាប់ចូលរួម តើអ្នកធ្លាប់បញ្ចេញយោបល់ក្នុងពេលប្រជុំ? (N=១១៧១)



ហេតុផលមួយដែលអ្នកភូមិទៅចូលរួមក្នុងការប្រជុំកម្រិតមូលដ្ឋាន ប៉ុន្តែមិនសូវហ៊ានលើកសំណួរ អាចមកពីគាត់មានការបារម្ភក្នុងការនិយាយស្តី។ គួរកត់សំគាល់ថា អ្នកឆ្លើយសម្ភាសន៍ ៦៩% បានជ្រើសរើសមិនតបនឹងសំណួរថា តើគាត់មានការបារម្ភក្នុងការសាកសួរសំណួរក្នុងពេលប្រជុំឬទេ? ការមិនឆ្លើយនេះបង្ហាញថា ប្រជាជនកម្ពុជានៅមានការស្ទាក់ស្ទើរក្នុងការចូលរួមពិភាក្សាជាសាធារណៈ និងក្នុងការបញ្ចេញមតិយោបល់ នៅពេលមានវត្តមានអាជ្ញាធរមូលដ្ឋាន/មេឃុំ ក្នុងកិច្ចប្រជុំ។ អ្នកឆ្លើយសម្ភាសន៍ ២៤% និយាយថា គាត់មិនមានការបារម្ភក្នុងការសាកសួរសំណួរទេ និងមាន ៧% ដែលប្រាប់ថា គាត់មានការបារម្ភ។ មតិយោបល់បែបនេះ ឃើញមានជាទូទៅសម្រាប់ មនុស្សទាំងពីរជំនាន់ មនុស្សទាំងពីរភេទ និងគ្រប់តំបន់ភូមិសាស្ត្រ។

រូបភាព២៤៖ តើអ្នកមានការបារម្ភដែរឬទេនៅពេលបញ្ចេញមតិក្នុងសកម្មភាពឬ ប្រជុំ? (N=១១៧១)




## ៤.៦.២ ទំនួលខុសត្រូវរបស់ឃុំ

ប្រជាជនកម្ពុជាសង្ឃឹមថា ក្រុមប្រឹក្សាឃុំអាចធ្វើការបានច្រើនជាងកាលពីពេលមុន ក្នុងការផ្តល់សេវាសង្គម និងធ្វើសកម្មភាពអភិវឌ្ឍន៍ នៅក្នុងឃុំ។ យុវជន ៨៩% និង មនុស្សជំនាន់មុន ៨៨% និយាយថា គាត់ចង់ឲ្យឃុំផ្តល់ច្រើនថែមទៀតនូវ សេវា និងគម្រោងអភិវឌ្ឍន៍ ដែលឃុំ/សង្កាត់កំពុងអភិវឌ្ឍសព្វថ្ងៃ។ ទស្សនៈនេះឃើញមានប្រហាក់ប្រហែលគ្នា បើគិតតាមយេនឌ័រ ដោយមានបុរស ៩៣% និង ស្ត្រី ៨៥% និយាយថា ឃុំគួរប្រើប្រាស់មូលនិធិឃុំ/សង្កាត់ សម្រាប់អនុវត្តគម្រោងអភិវឌ្ឍន៍សហគមន៍របស់ខ្លួន។

រូបភាព២៥៖ តើមានសេវាឬគម្រោងអភិវឌ្ឍន៍អ្វីទេ ដែលឃុំមិនទាន់បានធ្វើ ប៉ុន្តែគួរធ្វើ? (N=១៤១៥)




សេវាសាធារណៈ និងគម្រោងអភិវឌ្ឍន៍ផ្សេងៗដែលប្រជាជន (យុវជន ៨៥% មនុស្សជំនាន់មុន ៨៩%) រំពឹងថា ក្រុមប្រឹក្សាឃុំត្រូវផ្ដល់ឲ្យ មានបីប្រភេទធំៗ គឺ ១) ហេដ្ឋារចនាសម្ព័ន្ធ ដូចជា ផ្លូវថ្នល់ ស្ពាន ប្រព័ន្ធស្រោចស្រព អគ្គិសនី ការផ្គត់ផ្គង់ទឹកស្អាត និង អនាម័យ ២) សេវាកម្មសង្គម ដូចជា សាលារៀន និងមណ្ឌលសុខភាព និង៣) សេវាសន្តិសុខសង្គមសម្រាប់ប្រជាជនក្រីក្រ មនុស្សចាស់ជរា និងការគាំពារក្មេងកំព្រា។

រូបភាព២៦៖ តើឃុំ/សង្កាត់គួរផ្ដល់គម្រោងអភិវឌ្ឍន៍អ្វីខ្លះ? (N=១៤១៥)



## ៤.៧. ការវាយតម្លៃស្ថាប័នថ្នាក់ជាតិ

### *របកគំហើញសំខាន់ៗ*

- យុវជន ៧០% និងមនុស្សជំនាន់មុន ៧២% យល់ស្របថា កម្ពុជាកំពុងដើរលើផ្លូវត្រឹមត្រូវ។ មានអ្នករស់នៅជនបទ ៧៤% ច្រើនជាង អ្នករស់នៅទីប្រជុំជន ៦៤% ដែលយល់ស្របថា កម្ពុជាដើរលើផ្លូវត្រឹមត្រូវ។
- មានយុវជន (៩០%) ច្រើនជាងមនុស្សជំនាន់មុន (៨៦% ) ដែលយល់ស្របថា នាពេលបច្ចុប្បន្ន ប្រជាជនកម្ពុជា មានស្ថានភាពសេដ្ឋកិច្ចល្អប្រសើរជាងកាលពី ៥ ឆ្នាំមុន។
- មានអ្នកឆ្លើយសម្ភាសន៍ ច្រើនជាងពាក់កណ្តាល (៥៩%) ដែលពេញចិត្តលើរាជរដ្ឋាភិបាលកម្ពុជា ក្នុងការរក្សាស្ថិរភាពនយោបាយ។ យុវជន (៥៧%) និងមនុស្សជំនាន់មុន (៥៩%) មានទស្សនៈប្រហាក់ប្រហែលគ្នាលើការលើកឡើងខាងលើនេះ។
- មានអ្នកឆ្លើយសម្ភាសន៍ ៣០% គិតថា រាជរដ្ឋាភិបាលកម្ពុជាបានជួយប្រជាជនក្រីក្រគ្រប់គ្រាន់ល្អ និងមានត្រឹម ៣៩% ដែលយល់ឃើញថា រាជរដ្ឋាភិបាលបានបង្កើតឱកាសការងារគ្រប់គ្រាន់សម្រាប់យុវជន។ យុវជន និង មនុស្សជំនាន់មុន មានការវាយតម្លៃប្រហាក់ប្រហែលគ្នាក្នុងបញ្ហាទាំងពីរនេះ។
- អ្នកឆ្លើយសម្ភាសន៍ភាគច្រើន បញ្ជាក់ការពេញចិត្តចំពោះការអនុវត្តការងាររបស់ស្ថាប័នថ្នាក់ជាតិលើផ្នែកអប់រំ សុខាភិបាល និងហេដ្ឋារចនាសម្ព័ន្ធ។ ទាំងយុវជន និងមនុស្សជំនាន់មុន ភាគច្រើនពេញចិត្តនឹងស្ថាប័នផ្តល់សេវាសង្គម ច្រើនជាងស្ថាប័នអនុវត្តច្បាប់ និងស្ថាប័នតំណាងឲ្យប្រជាពលរដ្ឋ ដូចជា រដ្ឋសភា ជាដើម។

### *៤.៧.១ ការវាយតម្លៃទូទៅ*

ផ្នែកនេះពិភាក្សាពី ឥរិយាបថទូទៅនៃអ្នកឆ្លើយសម្ភាសន៍ចំពោះការដឹកនាំប្រទេសជាតិ និងការអនុវត្តការងាររបស់ស្ថាប័នថ្នាក់ជាតិ។ រូបភាព២៧ បង្ហាញថា អ្នកឆ្លើយសម្ភាសន៍ ៧១% មានការពេញចិត្តជារួមនឹងការដឹកនាំប្រទេសជាតិ។ យោបល់នេះឃើញមានសឹងតែដូចគ្នាក្នុងចំណោមយុវជន និងមនុស្សជំនាន់មុន ព្រោះមាន យុវជន ៧០% និង មនុស្សជំនាន់មុន ៧២% យល់ស្របថា ប្រទេសជាតិកំពុងដើរលើផ្លូវត្រឹមត្រូវ។ មានអ្នករស់នៅជនបទ (៧៤%) ច្រើនជាង អ្នករស់នៅទីប្រជុំជន (៦៤%) ដែលពេញចិត្តនឹងទិសដៅរបស់ប្រទេសជាតិ។

រូបភាព២៧៖ តើអ្នកយល់ស្របដែរថា ប្រទេសកម្ពុជាដើរលើផ្លូវត្រឹមត្រូវ? (%) (N=១៦០០)




កំណត់ចំណាំៈ ទិន្នន័យសរុបមិនស្មើ ១០០%ទេ ដោយសារមិនមានបង្ហាញទិន្នន័យអ្នកបដិសេធ

រូបភាព២៨៖ តើអ្នកយល់ស្របដែរថា ស្ថានភាពសេដ្ឋកិច្ចប្រជាជនកម្ពុជានាបច្ចុប្បន្នល្អប្រសើរជាង កាលពី ៥ឆ្នាំមុន? (%) (N=១៦០០)




អ្នកឆ្លើយសម្ភាសន៍ភាគច្រើន (៨៧%) យល់ថា ស្ថានភាពសេដ្ឋកិច្ចប្រជាជនកម្ពុជានាបច្ចុប្បន្នល្អប្រសើរជាងកាលពី ៥ឆ្នាំមុន។ មតិយោបល់នេះ ឃើញមានប្រហាក់ប្រហែលគ្នា ក្នុងចំណោម យុវជននិងមនុស្សជំនាន់មុន បុរសនិងស្ត្រី និង អ្នករស់នៅជនបទនិងអ្នករស់នៅទីប្រជុំជន។ យុវជន ៩០% មនុស្សជំនាន់មុន ៨៦% បុរស ៨៦% ស្ត្រី ៨៨% អ្នករស់នៅជនបទ ៨៩% និង អ្នករស់នៅទីប្រជុំជន ៨២% យល់ឃើញថាស្ថានភាពសេដ្ឋកិច្ចប្រជាជនកម្ពុជានាបច្ចុប្បន្នល្អប្រសើរជាងកាលពី ៥ឆ្នាំមុន (រូបភាព២៨)។

### ៤.៧.២ ការវាយតម្លៃលើស្ថាប័នជាតិ

អង្កេតនេះព្យាយាមស្វែងយល់ពីទស្សនៈរបស់អ្នកឆ្លើយសម្ភាសន៍លើស្ថាប័នថ្នាក់ជាតិ និងលើការអនុវត្តការងាររបស់រាជរដ្ឋាភិបាលក្នុងផ្នែកសំខាន់ៗមួយចំនួន។ រូបភាព២៩ បង្ហាញចម្លើយលើសំណួរថា តើអ្នកយល់ស្របដែរថា រាជរដ្ឋាភិបាលបានជួយប្រជាជនក្រីក្រ បង្កើតឱកាសការងារសម្រាប់យុវជន និងរក្សាស្ថិរភាពនយោបាយបានល្អគ្រប់គ្រាន់? អ្នកឆ្លើយបសម្ភាសន៍ ៥៩% យល់ស្របថា រាជរដ្ឋាភិបាលបានរក្សាស្ថិរភាពនយោបាយ ប៉ុន្តែមាន ៧០% មិនពេញចិត្តនឹងការជួយប្រជាជនក្រីក្រ និង ៦១% មិនពេញចិត្តនឹងការបង្កើតឱកាសការងារសម្រាប់យុវជន។ អ្នកឆ្លើយសម្ភាសន៍ ៣០% ពេញចិត្តលើរាជរដ្ឋាភិបាលក្នុងការជួយប្រជាជនក្រីក្របានគ្រប់គ្រាន់ ហើយ ៣៩% ពេញចិត្តនឹងការបង្កើតឱកាសការងារសមាប្រ់យុវជន។ ជារួម យុវជន និងមនុស្សជំនាន់មុន មានយោបល់ខុសគ្នាតែបន្តិចបន្តួច។ ក្នុងនេះ មនុស្សជំនាន់មុន ៥៩% និង យុវជន ៥៧% យល់ស្របថា រាជរដ្ឋាភិបាលរក្សាស្ថិរភាពនយោបាយបានពេញលេញ។

អ្នកឆ្លើយសម្ភាសន៍ពេញចិត្តច្រើនលើ ការអនុវត្តការងាររបស់ស្ថាប័នថ្នាក់ជាតិដែលផ្តល់សេវាសង្គម ជាជាងលើស្ថាប័នអនុវត្តច្បាប់ (ប៉ូលីស និងតុលាការ) និង ស្ថាប័នតំណាងជាតិ (រដ្ឋសភា)។ ស្ថាប័នបីដែលទទួលបានការពេញចិត្តខ្ពស់ជាងគេ គឺខាង អប់រំ សុខាភិបាល និង ហេដ្ឋារចនាសម្ព័ន្ធ។ អ្នកឆ្លើយសម្ភាសន៍ពេញចិត្តលើប៉ូលីសជាជាង តុលាការ និង រដ្ឋសភា ដោយ ប៉ូលីសស្ថិតនៅលំដាប់ទី៤ តុលាការនៅលំដាប់ទី៥ និង រដ្ឋសភានៅលំដាប់ទី៦ (តារាង១៧)។ ទាំងមនុស្សជំនាន់មុន និងយុវជន មានទស្សនៈប្រហាក់ប្រហែលគ្នា ក្នុងការពេញចិត្តខ្លាំងជាងគេលើស្ថាប័នខាងអប់រំ និងសុខាភិបាល។ ចំណែកឯ តុលាការ និងរដ្ឋសភា ទទួលបានលំដាប់ក្រោមគេក្នុងចំណោមស្ថាប័នទាំងប្រាំមួយ (តារាង១៨) ដែលអាចមកពីប្រជាជនមិនមានព័ត៌មានគ្រប់គ្រាន់ពីការងាររបស់ស្ថាប័នទាំងពីរនេះ ឬក៏អាចមកពីការមិនសូវពេញចិត្តនឹងការអនុវត្តការងារជាក់ស្តែងរបស់តុលាការ និងរដ្ឋសភា។

រូបភាព២៩៖ តើអ្នកយល់ស្របដែរថា រាជរដ្ឋាភិបាលបានជួយក្នុងបញ្ហាទាំងនេះ បានល្អគ្រប់គ្រាន់? (%) (N=១៦០០)




តារាង១៧៖ តើអ្នកពេញចិត្តនឹងការអនុវត្តការងាររបស់ស្ថាប័នរដ្ឋណាជាងគេ? (%) (N=១៥៤៩)

| | ចំណាត់ថ្នាក់ទី1 | ចំណាត់ថ្នាក់ទី2 | ចំណាត់ថ្នាក់ទី3 | ចំណាត់ថ្នាក់ទី4 | ចំណាត់ថ្នាក់ទី5 | ចំណាត់ថ្នាក់ទី6 |
|---|---|---|---|---|---|---|
| អប់រំ | 46 | 26 | 15 | 8 | 7 | 4 |
| សុខាភិបាល | 24 | 41 | 20 | 8 | 6 | 4 |
| ហេដ្ឋារចនាសម្ព័ន្ធ | 16 | 17 | 33 | 19 | 11 | 11 |
| ប៉ូលីស | 4 | 8 | 22 | 39 | 17 | 14 |
| តុលាការ | 3 | 4 | 5 | 13 | 36 | 30 |
| រដ្ឋសភា | 6 | 4 | 5 | 12 | 23 | 37 |

តារាង១៨៖ តើអ្នកពេញចិត្តជាងគេនឹងការអនុវត្តការងារស្ថាប័នរដ្ឋណាខ្លះ (%)? (N=១៥៧១)

| | ចំណាត់ថ្នាក់ទី1 | | ចំណាត់ថ្នាក់ទី2 | | ចំណាត់ថ្នាក់ទី3 | | ចំណាត់ថ្នាក់ទី4 | | ចំណាត់ថ្នាក់ទី5 | | ចំណាត់ថ្នាក់ទី6 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | យុវជន | មនុស្សជំនាន់មុន | យុវជន | មនុស្សជំនាន់មុន | យុវជន | មនុស្សជំនាន់មុន | យុវជន | មនុស្សជំនាន់មុន | យុវជន | មនុស្សជំនាន់មុន | យុវជន | មនុស្សជំនាន់មុន |
| អប់រំ | 49 | 46 | 26 | 27 | 12 | 16 | 7 | 9 | 8 | 7 | 5 | 4 |
| សុខាភិបាល | 20 | 26 | 39 | 42 | 23 | 20 | 10 | 8 | 7 | 6 | 7 | 3 |
| ហេដ្ឋារចនាសម្ព័ន្ធ | 14 | 17 | 16 | 17 | 26 | 35 | 21 | 18 | 13 | 10 | 14 | 9 |
| ប៉ូលីស | 6 | 4 | 9 | 8 | 29 | 19 | 33 | 41 | 12 | 19 | 13 | 14 |
| តុលាការ | 5 | 3 | 4 | 3 | 5 | 5 | 18 | 11 | 28 | 39 | 35 | 28 |
| រដ្ឋសភា | 6 | 5 | 6 | 3 | 5 | 5 | 10 | 13 | 32 | 20 | 26 | 42 |

## ៤.៨. ការទទួលបាននិងការប្រើប្រាស់ព័ត៌មាននយោបាយ

### *របកគំហើញសំខាន់ៗ*

- អ្នកឆ្លើយសម្ភាសន៍ទទួលបានព័ត៌មាននយោបាយភាគច្រើន ពីប្រភពក្នុងស្រុក មានដូចជា៖ ទូរទស្សន៍ (៧១%) សមាជិកគ្រួសារ (៥៩%) និង អ្នកជិតខាង (៥១%)។ មានយុវជនច្រើននាក់ ដែលទទួលព័ត៌មាននយោបាយពីអ៊ិនធើណិត បើធៀបនឹងមនុស្សជំនាន់មុន ពោលគឺ មានយុវជន ៥៨% និងមនុស្សជំនាន់មុនត្រឹមតែ ២៥% ដែលប្រើប្រាស់អ៊ិនធើណិតសម្រាប់ស្វែងរកព័ត៌មាននយោបាយ។

- យុវជន និងមនុស្សជំនាន់មុន ក៏ប្រើប្រាស់អ៊ិនធើណិតសម្រាប់ការកម្សាន្ត និង រក្សាទំនាក់ទំនងជាមួយមិត្តភក្តិ និង គ្រួសារដែរ។ យុវជនមិនសូវប្រើអ៊ិនធើណិត ដើម្បីធ្វើការសិក្សាស្រាវជ្រាវបង្កើនសមត្ថភាពខ្លួនឯងទេ។
- មានយុវជន (៣៥%) ច្រើនជាងមនុស្សជំនាន់មុន (២៩%) ដែលមានការបារម្ភក្នុងការស្វែងរកព័ត៌មាននយោបាយតាមអ៊ិនធើណិត ហើយមនុស្សទាំងពីរជំនាន់ មានការប្រុងប្រយ័ត្នដូចគ្នាក្នុងការបញ្ចេញទស្សនៈ និងការចែករំលែកព័ត៌មាននយោបាយតាមអ៊ិនធើណិត។
- អ្នកឆ្លើយសម្ភាសន៍ប្រមាណជាងពាក់កណ្តាលនិយាយថា មានការបារម្ភក្នុងការចែករំលែកព័ត៌មាន និងចូលរួមបញ្ចេញទស្សនៈនយោបាយក្នុងពេលជួបប្រស្រ័យគ្នាជាក់ស្តែង និងតាមអ៊ិនធើណិត។ ដូចគ្នាដែរ យុវជន និង មនុស្សជំនាន់មុន មានទំនុកចិត្តធ្វើការចែករំលែក និងបញ្ចេញទស្សនៈនយោបាយ តែក្នុងរង្វង់គ្រួសារ មិត្តភក្តិ និង អ្នកជិតខាងដែលជិតស្និទ្ធគ្នាបំផុតប៉ុណ្ណោះ។
- មានបុរសច្រើនជាងស្ត្រី ដែលមានទំនុកចិត្តក្នុងការចូលរួមបញ្ចេញទស្សនៈនយោបាយក្នុងពេលជួបប្រស្រ័យគ្នាជាក់ស្តែង និងតាមអ៊ិនធើណិត។ ចំណុចនេះបញ្ជាក់ថា ផ្នែកនយោបាយនៅតែជាកិច្ចការដែលទទួលបានការចាប់អារម្មណ៍ភាគច្រើនពីបុរស។

### ៤.៨.១ ប្រភពព័ត៌មាននយោបាយ

អង្កេតព្យាយាមស្វែងយល់ពីផលប៉ះពាល់នៃការផ្លាស់ប្តូរប្រភពព័ត៌មាន និងការជ្រាបចូលបច្ចេកវិទ្យាព័ត៌មានទៅលើការទទួលបានព័ត៌មាននយោបាយ ក្នុងចំណោមយុវជន និងមនុស្សជំនាន់មុន។ តារាង១៩ បង្ហាញនូវចម្លើយស្តីពី ប្រភពព័ត៌មាននយោបាយ។ អ្នកឆ្លើយសម្ភាសន៍ទទួលបានព័ត៌មាននយោបាយពីប្រភពជាច្រើន ប៉ុន្តែភាគច្រើនបានមកពីប្រភពក្នុងស្រុក មានជាអាទិ ទូរទស្សន៍ សមាជិកគ្រួសារ អ្នកជិតខាង និង អាជ្ញាធរមូលដ្ឋាន (ឃុំ ភូមិ)។ ប្រភពសំខាន់ៗ រួមមាន គ្រួសារ (៥៩%) អ្នកជិតខាង (៥១%) មិត្តភក្តិ (៤១%) និង អាជ្ញាធរមូលដ្ឋាន (៤២%)។ អ្នកឆ្លើយសម្ភាសន៍ទទួលបានព័ត៌មាននយោបាយតាមរយៈ វិទ្យុ (៣៥%) អ៊ិនធើណិត (៣៣%) សារព័ត៌មាន (៨%) និង បុគ្គលិកអង្គការសង្គមស៊ីវិល (៨%) ។

ប្រភពព័ត៌មាននយោបាយមានភាពខុសគ្នាខ្លះ រវាងយុវជននឹងមនុស្សជំនាន់មុន និង រវាងអ្នករស់នៅជនបទនឹងអ្នករស់នៅទីប្រជុំជន។ យុវជន ៧៣% និង មនុស្សជំនាន់មុន ៧១% ទទួលបានព័ត៌មាននយោបាយតាមរយៈទូរទស្សន៍។ គ្រួសារជាប្រភពព័ត៌មាននយោបាយសំខាន់ទី២ សម្រាប់ យុវជន (៦១%) និង មនុស្សជំនាន់មុន (៥៨%)។ អ្នកជិតខាងជាប្រភពទី៣ (យុវជន ៤៨% មនុស្សជំនាន់មុន ៥១%)។ អាជ្ញាធរមូលដ្ឋាន ក៏ជាប្រភពព័ត៌មានសំខាន់ដែរ (មនុស្សជំនាន់មុន ៤៤% យុវជន ៣៥%)។ អ៊ិនធើណិតជាប្រភពសំខាន់ថ្មីមួយសម្រាប់ប្រជាជនកម្ពុជា ដើម្បីទទួលបានព័ត៌មាននយោបាយ ដោយ យុវជន ៥៨% និង មនុស្សជំនាន់មុន ២៥% ទទួលវាបានពីប្រភពនេះ។ សារព័ត៌មានក៏សំខាន់ដែរសម្រាប់យុវជន (១១%) និង មនុស្សជំនាន់មុន (៧%) ។

បុរស និងស្ត្រី ខុសប្លែកគ្នាខ្លះក្នុងការទទួលបានព័ត៌មាននយោបាយ។ លទ្ធផលអង្កេតបង្ហាញថាស្ត្រីនៅពឹងពាក់ខ្លាំងលើសមាជិកគ្រួសារ និងទូរទស្សន៍ ដើម្បីទទួលបានព័ត៌មាននយោបាយ និងពឹងពាក់តិចតួចលើអ៊ិនធើណិត និងអ្នករួមការងារ។ ជាក់ស្តែង ស្ត្រី ៦២% និង បុរស ៥៤% ទទួលបានព័ត៌មាននយោបាយពីគ្រួសារ ប៉ុន្តែមានស្ត្រីតែ ២៥% ធៀបនឹងបុរស រហូតដល់ ៤៤% ដែលប្រើប្រាស់អ៊ិនធើណិតសម្រាប់ព័ត៌មាននេះ។

អ្នករស់នៅជនបទ មានការខុសប្លែកគួរឲ្យកត់សំគាល់ពីអ្នករស់នៅទីប្រជុំជន ដោយគាត់ត្រូវពឹងផ្អែកច្រើនលើប្រភពបែបប្រពៃណី (ទូរទស្សន៍ វិទ្យុ) និងលើទំនាក់ទំនងបុគ្គល ដើម្បីទទួលបានព័ត៌មាននយោបាយ។ អ្នករស់នៅជនបទ ៥៣% និង នៅទីប្រជុំជន ៤៦% ទទួលបានព័ត៌មាននយោបាយពីអ្នកជិតខាង ។ ផ្ទុយទៅវិញ អ្នករស់នៅទីប្រជុំជន ៥៥% និង អ្នកនៅជនបទ ២៥% ប្រើប្រាស់អ៊ិនធើណិតដើម្បីស្វែងរកព័ត៌មាននយោបាយ។

តារាង១៩៖ តើអ្នកទទួលព័ត៌មាននយោបាយពីប្រភពណាខ្លះ? (%) (N=១៦០០)

| | សរុប | ក្រុមអាយុ | | ភេទ | | តំបន់ | |
|---|---|---|---|---|---|---|---|
| | | យុវជន | មនុស្សជំនាន់មុន | បុរស | ស្ត្រី | ជនបទ | ទីប្រជុំជន |
| ទូរទស្សន៍ | 71 | 73 | 71 | 77 | 67 | 70 | 79 |
| គ្រួសារ/សាច់ញាតិ | 59 | 61 | 58 | 54 | 62 | 59 | 60 |
| អ្នកជិតខាង | 51 | 48 | 51 | 51 | 50 | 53 | 46 |
| អាជ្ញាធរ | 42 | 35 | 44 | 45 | 39 | 44 | 36 |
| មិត្តភក្តិ | 41 | 45 | 39 | 52 | 33 | 38 | 49 |
| វិទ្យុ | 35 | 40 | 34 | 44 | 30 | 38 | 30 |
| អ៊ិនធើណិត | 33 | 58 | 25 | 44 | 25 | 25 | 55 |
| អ្នករួមការងារ | 29 | 33 | 27 | 37 | 23 | 28 | 33 |
| សារព័ត៌មាន | 8 | 11 | 7 | 13 | 5 | 5 | 16 |
| អង្គការសហគមន៍/អង្គការសង្គមស៊ីវិល | 8 | 12 | 6 | 10 | 6 | 8 | 9 |
| មិនបានទទួលព័ត៌មាននយោបាយទេ | 6 | 5 | 6 | 2 | 8 | 6 | 2 |

អ្នកឆ្លើយសម្ភាសន៍ប្រើប្រាស់អ៊ិនធើណិតជាសំខាន់ ដើម្បីស្វែងរកព័ត៌មាននយោបាយតាមរយៈបណ្តាញសង្គម។ ក្នុងចំណោមអ្នកប្រើប្រាស់អ៊ិនធើណិត មាន ៩១% ដែលប្រើវាដើម្បីស្វែងរកព័ត៌មានទូទៅនិងព័ត៌មាននយោបាយ, ៧៩% ប្រើវាសម្រាប់ការកម្សាន្ត, ៧២% សម្រាប់រក្សាទំនាក់ទំនងជាមួយគ្រួសារ និង ៦៤% សម្រាប់ទាក់ទងមិត្តភក្តិ។ គោលបំណងសំខាន់ទាំងបីក្នុងការប្រើប្រាស់អ៊ិនធើណិត មិនសូវខុសគ្នាទេ រវាងយុវជននឹងមនុស្សជំនាន់មុន និង រវាងអ្នករស់នៅជនបទនឹងនៅទីប្រជុំជន។ ការប្រើប្រាស់អ៊ិនធើណិតដើម្បីបានព័ត៌មានទូទៅនិងព័ត៌មាននយោបាយ ជាហេតុផលសំខាន់របស់យុវជន ៨៩% និងមនុស្សជំនាន់មុន ៩២% ។ ហេតុផលទី២ គឺការកម្សាន្ត សម្រាប់ យុវជន ៩០% និង មនុស្សជំនាន់មុន ៧០% ។ ហេតុផលទី៣ គឺការរក្សាទំនាក់ទំនងជាមួយគ្រួសារ និងសាច់ញាតិ សម្រាប់ យុវជន ៧៧% និង មនុស្សជំនាន់មុន ៦៧% ។ យុវជនប្រមាណ ៣៦% និង មនុស្សជំនាន់មុន ១៤% ប្រើប្រាស់អ៊ិនធើណិតសម្រាប់ការសិក្សា។

តារាង២០៖ តើអ្នកប្រើប្រាស់អ៊ិនធើណិតសម្រាប់គោលបំណងអ្វីខ្លះ? (%) (N=៥៥៣)

| | សរុប | យុវជន | មនុស្សជំនាន់មុន | ជនបទ | ទីប្រជុំជន |
|---|---|---|---|---|---|
| ទំនាក់ទំនងក្នុងគ្រួសារ/សាច់ញាតិ | 72 | 77 | 67 | 69 | 75 |
| ទំនាក់ទំនងជាមួយមិត្តភក្តិ | 64 | 79 | 53 | 61 | 69 |
| ស្តាប់ភ្លេង និងមើលទូរទស្សន៍ | 79 | 90 | 70 | 83 | 73 |
| អានព័ត៌មានទូទៅ និងព័ត៌មាននយោបាយ | 91 | 89 | 92 | 91 | 90 |
| រកឯកសារសិក្សា | 24 | 36 | 14 | 21 | 28 |
| ស្វែងរកព័ត៌មានទាក់ទងនឹងជំនាញថ្មីៗ | 29 | 39 | 21 | 25 | 35 |
| ការងារ/អាជីវកម្ម | 25 | 29 | 22 | 16 | 37 |

### ៤.៨.២ ទស្សនៈលើសេរីភាពនយោបាយ

អ្នកឆ្លើយសម្ភាសន៍ភាគច្រើន (៦៨%) មិនមានការបារម្ភក្នុងការស្វែងរកព័ត៌មាននយោបាយតាមអ៊ិនធើណិតទេ ប៉ុន្តែ ៣២% មានការបារម្ភ។ មនុស្សជំនាន់មុន ៧១% និងយុវជន ៦៥% មិនមានការបារម្ភក្នុងការស្វែងរកព័ត៌មាននយោបាយតាមអ៊ិនធើណិតទេ។ អ្នករស់នៅជនបទ ៣៨% និង អ្នករស់នៅទីប្រជុំជន ២៤% មានការបារម្ភក្នុងការស្វែងរកព័ត៌មាននយោបាយតាមអ៊ិនធើណិត។ ស្ត្រី ៤១% និង បុរស ២៤% ក៏មានការបារម្ភនេះដែរ។

រូបភាព៣០៖ តើអ្នកមានការបារម្ភឬទេ ក្នុងការស្វែងរកព័ត៌មាននយោបាយតាមអ៊ិនធើណិត? (%) (N=៥៥៣)




អង្កេតនេះរកឃើញថា ប្រជាជនកម្ពុជាមានអារម្មណ៍ខុសគ្នាទាក់ទងនឹង សេរីភាពក្នុងការបញ្ចេញមតិ និងការចូលរួមពិភាក្សាបញ្ហានយោបាយដោយចំហ។ អ្នកឆ្លើយសម្ភាសន៍ ៥៥% មានការបារម្ភក្នុងការបញ្ចេញទស្សនៈនយោបាយក្នុងពេលជួបប្រស្រ័យគ្នាជាក់ស្តែង ហើយ ៤៥% ទៀតមិនមានការបារម្ភនឹងបញ្ចេញទស្សនៈនយោបាយរបស់ខ្លួនទេ។ យុវជន ៥៤% មនុស្សជំនាន់មុន ៥៥% អ្នករស់នៅជនបទ ៥៦% និង អ្នករស់នៅទីប្រជុំជន ៥០% និយាយថា គាត់មានការបារម្ភក្នុងការពិភាក្សាបញ្ហានយោបាយជាចំហនៅក្រៅប្រព័ន្ធអ៊ិនធើណិត។ ប៉ុន្តែ បុរស ៥៣% និង ស្ត្រី ៤០% មិនមានការបារម្ភក្នុងការបញ្ចេញទស្សនៈនយោបាយរបស់ខ្លួនទេ។

រូបភាព៣១៖ តើអ្នកយល់ស្របដែរថា អ្នកមានការបារម្ភក្នុងការបញ្ចេញទស្សនៈនយោបាយនៅក្រៅប្រព័ន្ធអ៊ិនធើណិត? (%) (N=១៦០០)




ស្រដៀងគ្នានឹងឥរិយាបថទាក់ទងនឹង ការពិភាក្សាបញ្ហានយោបាយនៅក្រៅប្រព័ន្ធអ៊ិនធើណិតដែរ អ្នកឆ្លើយសម្ភាសន៍ជាងពាក់កណ្តាល មានការបារម្ភ ហើយជិតពាក់កណ្តាលទៀតមិនមានការបារម្ភទេ ក្នុងការចែករំលែកព័ត៌មាននយោបាយ និងបញ្ចេញមតិលើបញ្ហាយោបាយតាមប្រព័ន្ធអ៊ិនធើណិត។ ជាក់ស្តែង យុវជន ៥៥% និង មនុស្សជំនាន់មុន ៥៥% មានការបារម្ភក្នុងការចែករំលែកព័ត៌មាននយោបាយ និងបញ្ចេញមតិលើបញ្ហានយោបាយតាមប្រព័ន្ធអ៊ិនធើណិត

ហើយ យុវជន ៤១% និង មនុស្សជំនាន់មុន ៤១% មិនមានការបារម្ភទេ។ ក្នុងបញ្ហានេះដែរ អ្នករស់នៅទីប្រជុំជន ៥២% និង អ្នករស់នៅជនបទ ៥៨% មានការបារម្ភ ហើយ ស្ត្រី ៦១% និង បុរស ៥១% ក៏មានការបារម្ភដែរ។

លើការចែករំលែកព័ត៌មាននយោបាយ អង្កេតបានរកឃើញថា ប្រជាជនកម្ពុជាមានការប្រុងប្រយ័ត្នខ្ពស់ក្នុងការចែករំលែកព័ត៌មាននយោបាយ ដោយធ្វើការចែករំលែកភាគច្រើនតែក្នុងចំណោមបុគ្គលទុកចិត្តគ្នា ដូចជា សមាជិកគ្រួសារ អ្នកជិតខាង និងមិត្តភក្តិ។ អ្នកឆ្លើយសម្ភាសន៍ ៥៨% ចែករំលែកព័ត៌មាននយោបាយតែជាមួយសមាជិកគ្រួសារ, ៣៨% មានចែករំលែកជាមួយអ្នកជិតខាង និង ៣៧% មានចែករំលែកជាមួយមិត្តភក្តិ។ ឥរិយាបថនេះពុំមានការខុសគ្នាច្រើនទេ រវាងយុវជននឹងមនុស្សជំនាន់មុន រវាងអ្នករស់នៅជនបទនឹងនៅទីប្រជុំជន និង រវាងបុរសនឹងស្ត្រី។ យុវជន ៦១% មនុស្សជំនាន់មុន ៥៨% អ្នករស់នៅទីប្រជុំជន ៦១% អ្នករស់នៅជនបទ ៥៧% ស្ត្រី ៥៧% និង បុរស ៦១% ចែករំលែកព័ត៌មាននយោបាយតែជាមួយសមាជិកគ្រួសារ។

អង្កេតរកឃើញថា ការចែករំលែកខ្លឹមសារទាក់ទងនឹងនយោបាយតាមប្រព័ន្ធអ៊ិធើណិត ជាមួយ បុគ្គលស្គាល់គ្នា (៧%) និងបុគ្គលមិនស្គាល់គ្នា (៥%) មានកម្រិតទាបបំផុត។

អ្នកឆ្លើយសម្ភាសន៍ ៣៥% មិនចែករំលែកខ្លឹមសារនយោបាយដល់នរណាទេ ទាំងក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធអ៊ិនធើណិត។ ឥរិយាបថនេះឃើញមានប្រហាក់ប្រហែលគ្នា ក្នុងចំណោមយុវជន និងមនុស្សជំនាន់មុន។ គម្លាតយេនឌ័រមានទំហំធំ ដោយមាន បុរសតែ ២៨% ដែលនិយាយថា គាត់មិនចែករំលែកព័ត៌មាននយោបាយទេ រីឯស្ត្រីមានដល់ ៤០% ។ អ្នករស់នៅទីប្រជុំជន ចែករំលែកព័ត៌មាននយោបាយតិចជាង អ្នករស់នៅជនបទ។

រូបភាព៣២៖ តើអ្នកយល់ស្របដែរថា អ្នកមានការបារម្ភក្នុងការចែករំលែកព័ត៌មាននយោបាយ និងការបញ្ចេញមតិលើបញ្ហានយោបាយតាមប្រព័ន្ធអ៊ិនធើណិត? (%) (N=១៦០០)



តារាង២១៖ តើអ្នកចែករំលែកព័ត៌មាននយោបាយតាមរបៀបណា និងជាមួយនរណាខ្លះ? (%) (N=១៦០០)

| | សរុប | ក្រុមអាយុ | | ភេទ | | តំបន់ | |
|---|---|---|---|---|---|---|---|
| | | យុវជន | មនុស្សជំនាន់មុន | បុរស | ស្ត្រី | ជនបទ | ទីប្រជុំជន |
| ជាមួយគ្រួសារ/សាច់ញាតិ | 58 | 60 | 58 | 61 | 57 | 57 | 61 |
| ជាមួយអ្នកជិតខាង | 38 | 33 | 40 | 43 | 35 | 40 | 32 |
| ជាមួយមិត្តភក្តិ | 37 | 42 | 35 | 49 | 28 | 34 | 43 |
| ជាមួយអ្នករួមការងារ | 24 | 26 | 23 | 34 | 17 | 22 | 27 |
| តាមអ៊ិនធើណិតជាមួយមនុស្សជិតស្និទ | 7 | 15 | 4 | 9 | 5 | 4 | 14 |
| តាមអ៊ិនធើណិតជាមួយមនុស្សទូទៅ | 5 | 11 | 3 | 7 | 4 | 3 | 11 |
| មិនចែកចាយព័ត៌មាននយោបាយទេ | 35 | 31 | 37 | 28 | 40 | 37 | 31 |

## ៤.៩. អាទិភាព និងការរំពឹងទុកទៅអនាគត

### របកគំហើញសំខាន់ៗ

- យុវជន និងមនុស្សជំនាន់មុនមានទស្សនៈប្រហាក់ប្រហែលគ្នាទាក់ទងនឹងអាទិភាពក្នុងជីវិត។ ទាំងយុវជន និងមនុស្សជំនាន់មុន បានកំណត់ថា កាតព្វកិច្ចចំពោះគ្រួសារធ្វើឲ្យឪពុកម្តាយមានមោទនភាព និង ការក្លាយជាជនគំរូសម្រាប់សង្គម វាមានអាទិភាពខ្ពស់ជាង ការរកចំណូលបានច្រើន និង ការអប់រំកម្រិតឧត្តមសិក្សា។
- យុវជន និងមនុស្សជំនាន់មុន មានគំនិតខុសគ្នាតែបន្តិចបន្តួចទាក់ទងនឹង អាទិភាពក្នុងការអភិវឌ្ឍប្រទេសជាតិ។ សម្រាប់ការអភិវឌ្ឍប្រទេសជាតិ យុវជន និងមនុស្សជំនាន់មុន ផ្តល់អាទិភាពខ្ពស់បំផុតដល់ ការបោះឆ្នោត ហេដ្ឋារចនាសម្ព័ន្ធ សេវាសង្គម (ការអប់រំ ការថែទាំសុខភាព) សេដ្ឋកិច្ចនិងការងារ និង បរិស្ថាន។ រីឯ ចំណាកស្រុក វិសមភាពសង្គម និងភាពអយុត្តិធម៌ គឺទទួលបានអាទិភាពទាបជាងគេ។
- អ្នកឆ្លើយសម្ភាសន៍មានសុទិដ្ឋិនិយមលើអនាគតរបស់ខ្លួនផ្ទាល់ (៦២%) និង អនាគតប្រទេសជាតិ (៦១%) ហើយក្នុងនេះ យុវជនមានសុទិដ្ឋិនិយម ច្រើនជាងមនុស្សជំនាន់មុន។ យុវជន ៧៤% និង មនុស្សជំនាន់មុន ៥៨% មានសុទិដ្ឋិនិយមលើអនាគតរបស់ខ្លួន។ មនុស្សទាំងពីរជំនាន់មានការខុសប្លែកគ្នាបន្តិចបន្តួចទាក់ទងនឹងទស្សនៈ ស្តីពីអនាគតប្រទេសជាតិ។ យុវជន (៦៦%) មានសុទិដ្ឋិនិយមច្រើនជាងបន្តិច បើធៀបនឹងមនុស្សជំនាន់មុន (៦០%) ។

### ៤.៩.១ សារៈសំខាន់សម្រាប់បុគ្គល

អង្កេតបានស្នើឲ្យ អ្នកឆ្លើយសម្ភាសន៍កំណត់ពីសារៈសំខាន់នៃបញ្ហាមួយចំនួនក្នុងជីវិតរបស់ខ្លួន ។ រូបភាព៣៣ បង្ហាញថា អ្នកឆ្លើយសម្ភាសន៍បានផ្តល់ សារៈសំខាន់ខ្ពស់បំផុតដល់ កាតព្វកិច្ចគ្រួសារតាមរយៈការធ្វើឲ្យឪពុកម្តាយមានមោទនភាព និង ការក្លាយខ្លួនជាជនគំរូល្អសម្រាប់សង្គម ។ យុវជន និងមនុស្សជំនាន់មុនមានទស្សនៈប្រហាក់ប្រហែលគ្នាលើបញ្ហាទាំងពីរនេះ។ យុវជន ៨០% និង មនុស្សជំនាន់មុន ៧៧% បានកំណត់ "ការធ្វើឲ្យគ្រួសារមានមោទនភាព" ថា សំខាន់ខ្លាំងណាស់ សម្រាប់រូបគាត់។ បន្ទាប់មក យុវជន ៦៦% និង មនុស្សជំនាន់មុន ៧១% បានកំណត់ "ការក្លាយជាជនគំរូល្អសម្រាប់សង្គម" ថា សំខាន់ខ្លាំងណាស់ទី២ ។ បន្ទាប់មកទៀត យុវជន ៥៣% និង មនុស្សជំនាន់មុន ៥៨% បានយល់ស្របថា "អាពាហ៍ពិពាហ៍ និងការមានគ្រួសារ" ក៏សំខាន់ខ្លាំងណាស់ដែរ។ ប៉ុន្តែ យុវជន និងមនុស្សជំនាន់មុនមានគំនិតខុសគ្នាខ្លះទាក់ទងនឹង ការរកប្រាក់បានច្រើន និង ការបញ្ចប់ការអប់រំកម្រិតឧត្តមសិក្សា។ យុវជនដែលកំណត់ការរកប្រាក់បានច្រើនថា សំខាន់ខ្លាំងណាស់ មានដល់ ៤៩% គឺច្រើនជាង សម្រាប់ ការអប់រំកម្រិតឧត្តមសិក្សា ដែលមានយុវជនត្រឹម ៤៣%។ មនុស្សជំនាន់មុន បានកំណត់ថា សំខាន់ខ្លាំងណាស់ ស្មើគ្នាដល់ ការរកប្រាក់បានច្រើន (៦០%) និង ការអប់រំកម្រិតឧត្តមសិក្សា (៦០%)។ យុវជន និងមនុស្សជំនាន់មុន មិនសូវខុសគ្នាខ្លាំងទេសម្រាប់សារៈសំខាន់ក្នុងជីវិត។ មនុស្សទាំងពីរជំនាន់ជាងពាក់កណ្តាល ក៏បានកំណត់ សុភមង្គលក្នុងគ្រួសារ កិត្តិយសគ្រួសារក្នុងសង្គម និងអាពាហ៍ពិពាហ៍ សំខាន់ខ្លាំងណាស់ ដែរ។

រូបភាព៣៣៖ តើអាទិភាពក្នុងជីវិតទាំងនេះសំខាន់កម្រិតណា តាមយោបល់របស់អ្នក? (N=១៥៨៧-១៥៨៩)




### ៤.៩.២ អាទិភាពសម្រាប់ប្រទេសជាតិ

អង្កេតបានស្នើឲ្យ អ្នកឆ្លើយសម្ភាសន៍កំណត់ពី សារៈសំខាន់នៃ បញ្ហាសំខាន់ៗមួយចំនួនសម្រាប់ការអភិវឌ្ឍប្រទេសជាតិ។ រូបភាព៣៤ បង្ហាញថា សម្រាប់ការអភិវឌ្ឍប្រទេសជាតិ អ្នកឆ្លើយសម្ភាសន៍ភាគច្រើនបានផ្តល់លក្ខណៈ "សំខាន់ខ្លាំងណាស់" ដល់ ការបោះឆ្នោត ហេដ្ឋារចនាសម្ព័ន្ធ សេវាសង្គម ការងារ និង បរិស្ថាន និងបានកំណត់ថា ចំណាកស្រុក វិសមភាពសង្គម និង ភាពអយុត្តិធម៌ គឺ សំខាន់តិចជាងគេ។ ក្នុងនេះ សេវាសុខភាព ត្រូវបានកំណត់ថា សំខាន់ខ្លាំងណាស់ ពីសំណាក់អ្នកឆ្លើយសម្ភាសន៍ ៧៦% ហើយបន្ទាប់មក គឺ សេដ្ឋកិច្ចនិងការងារ (៧១%) បរិស្ថាន (៦៤%) និង ភាពក្រីក្រ ការអត់ដីធ្លី និងបំណុល (៥១%)។ វិសមភាពសង្គម អយុត្តិធម៌ និង ចំណាកស្រុក មានអ្នកឆ្លើយសម្ភាសន៍តិចនាក់ជាងគេ ដែលកំណត់ថា សំខាន់ខ្លាំងណាស់។ គួរកត់សំគាល់ថា មានយុវជនត្រឹម ២៩% និង មនុស្សជំនាន់មុន ៣១% ដែលបានកំណត់ថា ចំណាកស្រុក សំខាន់ខ្លាំងណាស់។

យុវជន និងមនុស្សជំនាន់មុន កំណត់ថា សំខាន់ខ្លាំងណាស់ ដូចគ្នា ដល់ ការបោះឆ្នោត ការទទួលបានការអប់រំ និងហេដ្ឋារចនាសម្ព័ន្ធ។ ក្នុងនោះ យុវជនបានកំណត់ ការបោះឆ្នោតជាអាទិភាពទី១ ហើយបន្ទាប់មកគឺ ការអប់រំ និងហេដ្ឋារចនាសម្ព័ន្ធ។ មនុស្សជំនាន់មុនបានកំណត់ ហេដ្ឋារចនាសម្ព័ន្ធជាអាទិភាពទី១ ហើយបន្ទាប់មកគឺ ការបោះឆ្នោត និងការអប់រំ។ មនុស្សទាំងពីរជំនាន់ផ្តល់អាទិភាពមិនខុសគ្នាទេ បើធ្វើវិភាគតាម យេនឌ័រ តំបន់ភូមិសាស្ត្រ ឬ កម្រិតអប់រំ។ ស្រដៀងគ្នាដែរ អ្នករស់នៅជនបទ ៨៥% និង អ្នករស់នៅទីប្រជុំជន ៨០% បានកំណត់ការបោះឆ្នោតថា សំខាន់ខ្លាំងណាស់។

រូបភាព៣៤៖ ចំពោះយោបល់របស់អ្នក តើបញ្ហាទាំងអស់នេះសំខាន់កម្រិតណាសម្រាប់ការអភិវឌ្ឍប្រទេសជាតិ? (%) (N=១៥២៩-១៥៨៩)




រូបភាព៣៥៖ តាមយោបល់របស់អ្នក តើបញ្ហាទាំងនេះសំខាន់កម្រិតណាសម្រាប់ការអភិវឌ្ឍប្រទេសជាតិ (N=៣៩២-៣៩៧) (យុវជន)



រូបភាព៣៦៖ ចំពោះទស្សនៈរបស់អ្នក តើអ្នកកំណត់លំដាប់លំដោយអាទិភាពសម្រាប់អភិវឌ្ឍន៍ប្រទេសជាតិកម្រិតណា? (N=១១៣៧-១១៩២)(មនុស្សជំនាន់មុន)




### *៤.៩.៣ ការរំពឹងទុកទៅអនាគត*

អ្នកឆ្លើយសម្ភាសន៍មានសុទិដ្ឋិនិយមលើអនាគតរបស់ខ្លួន និងអនាគតប្រទេសជាតិ។ អ្នកឆ្លើយសម្ភាសន៍ភាគច្រើន (៦២%) មានសុទិដ្ឋិនិយមខ្លាំង ហើយ ១១% មានសុទិដ្ឋិនិយមខ្លាំងបំផុតលើអនាគតរបស់ខ្លួន។ ស្រដៀងគ្នាដែរ អ្នកឆ្លើយសម្ភាសន៍ភាគច្រើន (៦១%) មានសុទិដ្ឋិនិយមខ្លាំង ហើយ ១៩% មានសុទិដ្ឋិនិយមខ្លាំងបំផុតលើអនាគតប្រទេសជាតិ។ ម៉្យាងទៀត អ្នកឆ្លើយសម្ភាសន៍ ២២% គិតថា អនាគតរបស់គាត់គ្មានការប្រែប្រួល ហើយ ១៣% ទៀតគិតថា អនាគតប្រទេសជាតិគ្មានការប្រែប្រួល ។

យុវជនមានទំនុកចិត្តលើអនាគតរបស់ខ្លួន ជាងមនុស្សជំនាន់មុន។ យុវជន ៧៤% និង មនុស្សជំនាន់មុន ៥៨% មានសុទិដ្ឋិនិយមខ្លាំងលើអនាគតរបស់ខ្លួន ហើយ យុវជន ១៥% មានសុទិដ្ឋិនិយមខ្លាំងបំផុត ធៀបនឹង មនុស្សជំនាន់មុនមានត្រឹម ៩%។ មនុស្សទាំងពីរជំនាន់ មានគម្លាតគ្នាតិចតួចក្នុងការមាន សុទិដ្ឋិនិយមខ្លាំងលើអនាគតប្រទេសជាតិ ដោយ យុវជនមាន ៦៦% ហើយ មនុស្សជំនាន់មុនមាន ៦០%។ ម៉្យាងទៀត យុវជន ២០% មានសុទិដ្ឋិនិយមខ្លាំងបំផុត។ មនុស្សជំនាន់មុន ២៦% និង យុវជន ១០% គិតថា អនាគតរបស់ខ្លួនគ្មានការប្រែប្រួល។ ស្រដៀងគ្នាដែរ មនុស្សជំនាន់មុន ១៥% និង យុវជន ១០% គិតថា អនាគតប្រទេសជាតិគ្មានការប្រែប្រួល។

ទស្សនៈលើអនាគតប្រទេសជាតិ មិនប្រែប្រួលខុសគ្នាទេ បើសិនធ្វើវិភាគតាម យេនឌ័រ និងតំបន់ភូមិសាស្ត្រ។ អ្នករស់នៅជនបទ (៦១%) និងអ្នករស់ទីប្រជុំជន (៦៤%) មានសុទិដ្ឋិនិយមខ្លាំងប្រហែលគ្នាលើអនាគតប្រទេសជាតិ។ បុរស (៥៩%) និង ស្ត្រី (៦៣) ក៏មានមានសុទិដ្ឋិនិយមខ្លាំងប្រហាក់ប្រហែលគ្នាដែរ។ បើគិតតាមកម្រិតអប់រំវិញ អ្នកមានកម្រិតអប់រំខ្ពស់ មានសុទិដ្ឋិនិយមខ្លាំងជាង អ្នកមិនដែលចូលរៀន ឬ អ្នកមានកម្រិតអប់រំទាប។

រូបភាព៣៧៖ តើអ្នកមានសុទិដ្ឋិនិយមកម្រិតណាលើអនាគតរបស់អ្នកផ្ទាល់ និងអនាគតប្រទេសជាតិ? (N=១៥៥៧)




រូបភាព៣៨៖ តើអ្នកមានសុទិដ្ឋិនិយមកម្រិតណាលើអនាគតប្រទេសជាតិ? (N=១៥៥៧)



# ការស្ទង់មតិអំពីការចូលរួមរបស់ប្រជាពលរដ្ឋក្នុងសង្គម

## កម្រងសំណួរសម្រាប់អ្នកប្រមូលទិន្នន័យ

**ពន្យល់ពាក្យ**

- រូបិយប័ណ្ណ= រៀល
- ចំណាកស្រុក= ចាកចេញពីស្រុករបស់ខ្លួនចាប់ពី ៦ខែឡើងទៅ

Z0. លេខកូដភូមិ.........................................

Z1. លេខកូដផ្ទះ..........................................

A1. ភេទ

1. ប្រុស
2. ស្រី

A2. តើអ្នកអាយុប៉ុន្មាន? .........................

A3. តើអ្នកបានសិក្សាត្រឹមកម្រិតណា?

1. មិនដែលបានចូលរៀន
2. បឋមសិក្សា
3. អនុវិទ្យាល័យ
4. វិទ្យាល័យ
5. អប់រំបច្ចេកទេស (បណ្តុះបណ្តាលវិជ្ជាជីវៈ)
6. ឧត្តមសិក្សា
7. ផ្សេងៗ
8. មិនឆ្លើយ

A4. ជនជាតិ

1. ខ្មែរ
2. មិនឆ្លើយ
3. ផ្សេងៗ

**B. អត្តសញ្ញាណ**

B1. ក្នុងពេល១ខែចុងក្រោយតើអ្នកធ្លាប់ចូលរួមសកម្មភាពណាខ្លះដូចខាងក្រោម? (អាចមានចម្លើយលើសពី១)

1. សិល្បៈ និងវប្បធម៌
2. កីឡា
3. បណ្តុះបណ្តាល/ហាត់ការ (ឧ. បណ្តុះបណ្តាលកសិកម្ម...)
4. ការងារស្ម័គ្រចិត្ត (ការងារសហគមន៍, សប្បុរសធម៌, អង្គការមិនមែនរដ្ឋាភិបាល)
5. ក្លឹប និងសមាគម (ឧ. ក្លឹបយុវជន, ប្រជុំសមាគមកសិកម្ម)
6. សាសនា (ឧ. ទៅវត្ត ទៅបុណ្យ)
7. សកម្មភាពនយោបាយ (ឧ. ប្រជុំឃុំ, ប្រជុំគណបក្ស)
8. មិនធ្លាប់ចូលរួម
9. មិនឆ្លើយ

B2. តើអ្នកយល់ស្របនឹងប្រយោគខាងក្រោមដែរឬទេ? ការសិក្សានៅមហាវិទ្យាល័យរបស់បុរសសំខាន់ជាងការសិក្សានៅមហាវិទ្យាល័យរបស់ស្ត្រី

1. យល់ស្រប
2. មិនយល់ស្រប
3. មិនឆ្លើយ

B3. តើអ្នកយល់ស្របនឹងប្រយោគខាងក្រោមដែរ ឬទេ? បុរសសក្តិសមជាអ្នកដឹកនាំនយោបាយជាងស្ត្រី

1. យល់ស្រប
2. មិនយល់ស្រប
3. មិនឆ្លើយ

B4. តើអ្នកយល់ស្របនឹងប្រយោគខាងក្រោមដែរឬទេ? ភេទ (ស្រី ឬប្រុស) ជាឧបសគ្គដល់ជោគជ័យរបស់ខ្ញុំ

1. យល់ស្រប
2. មិនយល់ស្រប
3. មិនឆ្លើយ

B5. តើអ្នកយល់ស្របនឹងប្រយោគខាងក្រោមដែរឬទេ? ដៃគូដែលស្រឡាញ់គ្នាគួររស់នៅជាមួយគ្នាមុនអាពាហ៍ពិពាហ៍

1. យល់ស្រប
2. មិនយល់ស្រប
3. មិនឆ្លើយ

B6. តើអ្នកគិតគូរពីប្រទេសជាតិដែរឬទេ?

1. មិនគិតគូរ
2. គិតគូរខ្លះមិនគិតគូរខ្លះ
3. គិតគូរ
4. មិនឆ្លើយ

B7. តើអ្នកគោរពមេឃុំ/ចៅសង្កាត់របស់អ្នកដែរឬទេ?

1. មិនគោរព
2. គោរពខ្លះមិនគោរពខ្លះ
3. គោរព
4. មិនឆ្លើយ

B8. តើមនុស្សជំនាន់អ្នកខុសពីមនុស្សជំនាន់ផ្សេងដែរឬទេ?

1. មិនខុស
2. ខុសតិចតួច
3. ខុសខ្លាំង
4. មិនឆ្លើយ

B9. តើអ្នកជឿលើសាសនារបស់អ្នកដែរឬទេ?

1. មិនជឿ
2. ជឿខ្លះមិនជឿខ្លះ
3. ជឿ
4. មិនឆ្លើយ

B10. តើអ្នកគិតគូរពីសហគមន៍របស់អ្នកដែរឬទេ ?

1. មិនគិតគូរ
2. គិតគូរខ្លះមិនគិតគូរខ្លះ
3. គិតគូរ
4. មិនឆ្លើយ

B11. តើអ្នកណាគួរមានសិទ្ធិសម្រេចចិត្តចុងក្រោយលើការសិក្សារបស់យុវជន ? (បង្ហាញរូបភាព)

1. សាម៉ីខ្លួន
2. ឪពុកម្ដាយ
3. សាច់ញាតិ
4. មិត្តភក្តិ
5. អាជ្ញាធរ
6. ចាស់ទុំ និងព្រះសង្ឃ
7. មិនឆ្លើយ

B12. តើអ្នកណាគួរមានសិទ្ធិសម្រេចចិត្តចុងក្រោយលើការងាររបស់យុវជន ? (បង្ហាញរូបភាព)

1. សាម៉ីខ្លួន
2. ឪពុកម្ដាយ
3. សាច់ញាតិ
4. មិត្តភក្តិ
5. អាជ្ញាធរ
6. ចាស់ទុំ និងព្រះសង្ឃ
7. មិនឆ្លើយ

B13. តើអ្នកណាគួរមានសិទ្ធិសម្រេចចិត្តចុងក្រោយលើអាពាហ៍ពិពាហ៍របស់យុវជន ? (បង្ហាញរូបភាព)

1. សាម៉ីខ្លួន
2. ឪពុកម្ដាយ
3. សាច់ញាតិ
4. មិត្តភក្តិ
5. អាជ្ញាធរ
6. ចាស់ទុំ និងព្រះសង្ឃ
7. មិនឆ្លើយ

B14. តើអ្នកណាគួរមានសិទ្ធិសម្រេចចុងក្រោយក្នុងការទិញទូរស័ព្ទដៃរបស់យុវជន ? (បង្ហាញរូបភាព)

1. សាម៉ីខ្លួន
2. ឪពុកម្ដាយ
3. សាច់ញាតិ
4. មិត្តភក្តិ
5. អាជ្ញាធរ
6. ចាស់ទុំ និងព្រះសង្ឃ
7. មិនឆ្លើយ

B15. តើអ្នកណាគួរមានសិទ្ធិសម្រេចចុងក្រោយក្នុងការបោះឆ្នោតរបស់យុវជន ? (បង្ហាញរូបភាព)

1. សាម៉ីខ្លួន
2. ឪពុកម្ដាយ
3. សាច់ញាតិ
4. មិត្តភក្តិ
5. អាជ្ញាធរ
6. ចាស់ទុំ និងព្រះសង្ឃ

7. មិនឆ្លើយ

B16. តើអ្នកយល់ស្របនឹងប្រយោគខាងក្រោមដែរឬទេ? <u>យុវជនអាចជំទាស់នឹងឪពុកម្តាយរបស់ខ្លួន</u>

1. យល់ស្រប
2. មិនយល់ស្រប
3. មិនឆ្លើយ

B17. តើអ្នកយល់ស្របនឹងប្រយោគខាងក្រោមដែរឬទេ? <u>យុវជនមានទស្សនៈនយោបាយផ្ទាល់ខ្លួនគឺជារឿងសំខាន់</u>

1. យល់ស្រប
2. មិនយល់ស្រប
3. មិនឆ្លើយ

B18. ចូររៀបលំដាប់ខាងក្រោមតាមកម្រិតនៃសារៈសំខាន់សម្រាប់ជីវិតរបស់អ្នក៖ (បង្ហាញរូប)

1. មិត្តភក្តិ
2. ពេលកម្សាន្ត
3. គ្រួសារ
4. នយោបាយ/ សហគមន៍
5. ការអប់រំ និងការងារ
6. សាសនា

## C. ទំនុកចិត្ត និងការគោរព

C1. តើបុគ្គល/ស្ថាប័នណាដែលអ្នកផ្តល់ទំនុកចិត្ត? (បង្ហាញរូប)

1. ប្រព័ន្ធផ្សព្វផ្សាយ
2. អាជ្ញាធរមូលដ្ឋាន
3. ប៉ូលីស និងតុលាការ
4. សេវាសង្គម (ឧ. មន្ទីរពេទ្យ សាលារៀន...)
5. អ្នកនយោបាយ
6. មិនទុកចិត្តទាំងអស់

C2. ពី 1 ទៅ 5 តើអ្នកទុកចិត្តលើ<u>សាច់ញាតិ</u> (ដូចជា បងប្អូនជីដូនមួយ ពូ មីង) កម្រិតណា? (សូមអូសលើបន្ទាត់ត្រង់ដើម្បីជ្រើសរើសចម្លើយ)

1. មិនទុកចិត្តសោះ
2. មិនទុកចិត្ត
3. ទំនុកចិត្តខ្លះ និងមិនទុកចិត្តខ្លះ
4. ទុកចិត្ត
5. ទុកចិត្តខ្លាំងណាស់

C3. ពី 1 ទៅ 5 តើអ្នកទុកចិត្តលើ<u>មិត្តភក្តិ</u>កម្រិតណា? (សូមអូសលើបន្ទាត់ត្រង់ដើម្បីជ្រើសរើសចម្លើយ)

1. មិនទុកចិត្តសោះ
2. មិនទុកចិត្ត
3. ទំនុកចិត្តខ្លះ និងមិនទុកចិត្តខ្លះ
4. ទុកចិត្ត
5. ទុកចិត្តខ្លាំងណាស់

C4. ពី 1 ទៅ 5 តើអ្នកទុកចិត្តលើ<u>អ្នកធ្វើការជាមួយគ្នា</u>កម្រិតណា?

1. មិនទុកចិត្តសោះ
2. មិនទុកចិត្ត
3. ទំនុកចិត្តខ្លះ និងមិនទុកចិត្តខ្លះ
4. ទុកចិត្ត
5. ទុកចិត្តខ្លាំងណាស់

C5. ពី 1 ទៅ 5 តើអ្នកទុកចិត្ត អ្នកជិតខាង ឬសហគមន៍ កម្រិតណា?
1. មិនទុកចិត្តសោះ
2. មិនទុកចិត្ត
3. ទំនុកចិត្តខ្លះ និងមិនទុកចិត្តខ្លះ
4. ទុកចិត្ត
5. ទុកចិត្តខ្លាំងណាស់

C6. ពី 1 ទៅ 5 តើអ្នកទុកចិត្ត អង្គការសង្គមស៊ីវិល (អង្គការចុះអភិវឌ្ឍតាមភូមិឃុំ) កម្រិតណា?
1. មិនទុកចិត្តសោះ
2. មិនទុកចិត្ត
3. ទំនុកចិត្តខ្លះ និងមិនទុកចិត្តខ្លះ
4. ទុកចិត្ត
5. ទុកចិត្តខ្លាំងណាស់

C7. ពី 1 ទៅ 5 តើអ្នកទុកចិត្តលើ អ្នកនយោបាយ កម្រិតណា?
1. មិនទុកចិត្តសោះ
2. មិនទុកចិត្ត
3. ទំនុកចិត្តខ្លះ និងមិនទុកចិត្តខ្លះ
4. ទុកចិត្ត
5. ទុកចិត្តខ្លាំងណាស់

C8. ពី 1 ទៅ 5 តើអ្នកទុកចិត្តលើ អ្នកមិនស្គាល់ កម្រិតណា?
1. មិនទុកចិត្តសោះ
2. មិនទុកចិត្ត
3. ទំនុកចិត្តខ្លះ និងមិនទុកចិត្តខ្លះ
4. ទុកចិត្ត
5. ទុកចិត្តខ្លាំងណាស់

## D. ចក្ខុវិស័យ

D1. ពី 1 ទៅ 5 តើអ្នកគិតថា មនុស្សគួរឲ្យតម្លៃកម្រិតណា ទៅលើការបញ្ចប់ឧត្តមសិក្សា? (សូមគូសលើបន្ទាត់ត្រង់ដើម្បីជ្រើសរើសចម្លើយ)
1. មិនគួរឲ្យតម្លៃសោះ
2. មិនគួរឲ្យតម្លៃ
3. ធម្មតា
4. គួរឲ្យតម្លៃ
5. គួរឲ្យតម្លៃខ្លាំង

D2. ពី 1 ទៅ 5 តើអ្នកគិតថាមនុស្ស គួរឲ្យតម្លៃកម្រិតណា ទៅលើ អាពាហ៍ពិពាហ៍ និងការមានគ្រួសារ?
1. មិនគួរឲ្យតម្លៃសោះ
2. មិនគួរឲ្យតម្លៃ
3. ធម្មតា
4. គួរឲ្យតម្លៃ
5. គួរឲ្យតម្លៃខ្លាំង

D3. ពី ១ ទៅ ៥ តើអ្នកគិតថា មនុស្សគួរឲ្យតម្លៃកម្រិតណាទៅលើ ការរកលុយឲ្យបានច្រើន?
1. មិនគួរឲ្យតម្លៃសោះ
2. មិនគួរឲ្យតម្លៃ
3. ធម្មតា

4. គួរឲ្យតម្លៃ
5. គួរឲ្យតម្លៃខ្លាំង

D4. ពី 1 ទៅ 5 តើអ្នកគិតថា មនុស្សគួរឲ្យតម្លៃកម្រិតណា ទៅលើការក្លាយខ្លួនជាជនគំរូ?
1. មិនគួរឲ្យតម្លៃសោះ
2. មិនគួរឲ្យតម្លៃ
3. ធម្មតា
4. គួរឲ្យតម្លៃ
5. គួរឲ្យតម្លៃខ្លាំង

D5. ពី 1 ទៅ 5 តើអ្នកគិតថា មនុស្សគួរឲ្យតម្លៃកម្រិតណា ទៅលើការធ្វើឲ្យឪពុកម្តាយមានមោទនភាព?
1. មិនគួរឲ្យតម្លៃសោះ
2. មិនគួរឲ្យតម្លៃ
3. ធម្មតា
4. គួរឲ្យតម្លៃ
5. គួរឲ្យតម្លៃខ្លាំង

D6. ពី 1 ទៅ 5 តើអ្នកគិតថា ការអប់រំសំខាន់កម្រិតណាសម្រាប់ប្រទេសកម្ពុជា?
1. មិនសំខាន់សោះ
2. សំខាន់ខ្លះ
3. សំខាន់
4. សំខាន់ខ្លាំង
5. សំខាន់ខ្លាំងណាស់

D7. ពី 1 ទៅ 5 តើអ្នកគិតថា សេវាសុខភាពសំខាន់កម្រិតណាសម្រាប់ប្រទេសកម្ពុជា?
1. មិនសំខាន់សោះ
2. សំខាន់ខ្លះ
3. សំខាន់
4. សំខាន់ខ្លាំង
5. សំខាន់ខ្លាំងណាស់

D8. ពី 1 ទៅ 5 តើអ្នកគិតថា ហេដ្ឋារចនាសម្ព័ន្ធ(ឧ. ផ្លូវថ្នល់ ស្ពាន) សំខាន់កម្រិតណាសម្រាប់ប្រទេសកម្ពុជា?
1. មិនសំខាន់សោះ
2. សំខាន់ខ្លះ
3. សំខាន់
4. សំខាន់ខ្លាំង
5. សំខាន់ខ្លាំងណាស់

D9. ពី 1 ទៅ 5 តើអ្នកគិតថា អំពើហិង្សានិងអសន្តិសុខជាបញ្ហាចោទកម្រិតណាសម្រាប់ប្រទេសកម្ពុជា?
1. មិនចោទសោះ
2. ចោទខ្លះ
3. ចោទ
4. ចោទខ្លាំង
5. ចោទខ្លាំងណាស់

D10. ពី1 ទៅ 5 តើអ្នកគិតថា សេដ្ឋកិច្ចនិងការងារសំខាន់កម្រិតណាសម្រាប់ប្រទេសកម្ពុជា?
1. មិនសំខាន់សោះ
2. សំខាន់ខ្លះ
3. សំខាន់
4. សំខាន់ខ្លាំង
5. សំខាន់ខ្លាំងណាស់

D11. ពី 1 ទៅ 5 តើអ្នកគិតថា <u>បរិស្ថាន</u>សំខាន់កម្រិតណាសម្រាប់ប្រទេសកម្ពុជា?
1. មិនសំខាន់សោះ
2. សំខាន់ខ្លះ
3. សំខាន់
4. សំខាន់ខ្លាំង
5. សំខាន់ខ្លាំងណាស់

D12. ពី 1 ទៅ 5 តើអ្នកគិតថា <u>ភាពក្រីក្រគ្មានដីធ្លីនិងបំណុល</u>ជាបញ្ហាចោទកម្រិតណាសម្រាប់ប្រទេសកម្ពុជា?
1. មិនចោទសោះ
2. ចោទខ្លះ
3. ចោទ
4. ចោទខ្លាំង
5. ចោទខ្លាំងណាស់

D13. ពី 1 ទៅ 5 តើអ្នកគិតថា <u>អ្នកក្រកាន់តែក្រទៅអ្នកមានកាន់តែមានទៅ</u>ជាបញ្ហាចោទកម្រិតណាសម្រាប់ប្រទេសកម្ពុជា?
1. មិនចោទសោះ
2. ចោទខ្លះ
3. ចោទ
4. ចោទខ្លាំង
5. ចោទខ្លាំងណាស់

D14. ពី 1 ទៅ 5 តើអ្នកគិតថា <u>អយុត្តិធម៌</u>ជាបញ្ហាចោទកម្រិតណាសម្រាប់ប្រទេសកម្ពុជា?
1. មិនចោទសោះ
2. ចោទខ្លះ
3. ចោទ
4. ចោទខ្លាំង
5. ចោទខ្លាំងណាស់

D15. ពី 1 ទៅ 5 តើអ្នកគិតថា <u>ជម្លោះរវាងគណបក្សនយោបាយ</u> ជាបញ្ហាចោទកម្រិតណាសម្រាប់ប្រទេសកម្ពុជា?
1. មិនចោទសោះ
2. ចោទខ្លះ
3. ចោទ
4. ចោទខ្លាំង
5. ចោទខ្លាំងណាស់

D16. ពី 1 ទៅ 5 តើអ្នកគិតថា <u>អំពើពុករលួយ</u>ជាបញ្ហាចោទកម្រិតណាសម្រាប់ប្រទេសកម្ពុជា?
1. មិនចោទសោះ
2. ចោទខ្លះ
3. ចោទ
4. ចោទខ្លាំង
5. ចោទខ្លាំងណាស់

D17. ពី 1 ទៅ 5 តើអ្នកគិតថា <u>ការបោះឆ្នោត</u>សំខាន់កម្រិតណាសម្រាប់ប្រទេសកម្ពុជា?
1. មិនសំខាន់សោះ
2. សំខាន់ខ្លះ
3. សំខាន់
4. សំខាន់ខ្លាំង
5. សំខាន់ខ្លាំងណាស់

D18. ពី 1 ទៅ 5 តើអ្នកគិតថា បញ្ហាព្រំដែនជាបញ្ហាចោទកម្រិតណាសម្រាប់ប្រទេសកម្ពុជា?
1. មិនចោទសោះ
2. ចោទខ្លះ
3. ចោទ
4. ចោទខ្លាំង
5. ចោទខ្លាំងណាស់

D19. ពី 1 ទៅ 5 តើអ្នកគិតថា ចំណាកស្រុកជាបញ្ហាចោទកម្រិតណាសម្រាប់ប្រទេសកម្ពុជា?
1. មិនចោទសោះ
2. ចោទខ្លះ
3. ចោទ
4. ចោទខ្លាំង
5. ចោទខ្លាំងណាស់

D20. ពី 1 ទៅ 5 តើអ្នកគិតថា អនាគតរបស់ខ្លួនអ្នកផ្ទាល់នឹងល្អជាងឬអាក្រក់ជាងបច្ចុប្បន្នកម្រិតណា?
1. អាក្រក់ជាងខ្លាំង
2. អាក្រក់ជាង
3. នៅដដែល
4. ល្អជាង
5. ល្អជាងខ្លាំង

D21. ពី 1 ទៅ 5 តើអ្នកគិតពីអនាគតរបស់ប្រទេសកម្ពុជានឹងល្អជាងឬអាក្រក់ជាងបច្ចុប្បន្នកម្រិតណា?
1. អាក្រក់ជាងខ្លាំង
2. អាក្រក់ជាង
3. នៅដដែល
4. ល្អជាង
5. ល្អជាងខ្លាំង

## E. ការចូលរួមក្នុងវិស័យនយោបាយ

E1. តើអ្នកធ្លាប់ចូលរួមសកម្មភាពនៅថ្នាក់មូលដ្ឋានណាខ្លះ? (អាចមានចម្លើយលើសពី 1)
1. ប្រជុំភូមិ
2. ប្រជុំឃុំ/សង្កាត់
3. តាមដានគម្រោងអភិវឌ្ឍន៍ឃុំសង្កាត់
4. ប្រជុំទាក់ទងនឹងការសិក្សា
5. ប្រជុំទាក់ទងនឹងសុខភាព
6. វេទិកាសាធារណៈ
7. មិនដែលចូលរួម (រំលងទៅE4)
8. មិនឆ្លើយ (រំលងទៅE4)

E2. បើធ្លាប់ចូលរួម តើអ្នកធ្លាប់បញ្ចេញយោបល់ក្នុងសកម្មភាពណាខ្លះ? (អាចមានចម្លើយលើសពី 1)
1. ប្រជុំភូមិ
2. ប្រជុំឃុំ/សង្កាត់
3. ការតាមដានគម្រោងអភិវឌ្ឍន៍ឃុំសង្កាត់
4. ប្រជុំទាក់ទងនឹងការសិក្សា
5. ប្រជុំទាក់ទងនឹងសុខភាព
6. វេទិកាសាធារណៈ
7. មិនបានបញ្ចេញយោបល់ (រំលងទៅE4)
8. មិនឆ្លើយ (រំលងទៅE4)

9. រំលងទៅ E4

E3. តើអ្នកមានការបារម្ភដែរឬទេ នៅពេលបញ្ចេញមតិនៅក្នុងសកម្មភាពខាងក្រោម (អាចមានចម្លើយ លើសពី 1)

1. ប្រជុំភូមិ
2. ប្រជុំឃុំ/សង្កាត់
3. ការតាមដានគម្រោងអភិវឌ្ឍន៍ឃុំសង្កាត់
4. ប្រជុំទាក់ទងនឹងការសិក្សា
5. ប្រជុំទាក់ទងនឹងសុខភាព
6. វេទិកាសាធារណៈ
7. មិនមានការបារម្ភ
8. មិនឆ្លើយ
9. រំលងទៅ E4

E4. តើឃុំ/សង្កាត់គួរធ្វើគម្រោងថ្មីដែលគាត់មិនទាន់បានធ្វើដែរឬទេ?

1. គួរ
2. មិនគួរ
3. មិនដឹង
4. មិនឆ្លើយ

E5. ប្រសិនបើគួរ តើគួរធ្វើអ្វី? (អាចមានចម្លើយលើសពី 1)

1. ផ្លូវថ្នល់/ស្ពាន/ប្រព័ន្ធធារាសាស្ត្រ/ប្រព័ន្ធលូ/អគ្គិសនី
2. សាលារៀន/អាហារូបករណ៍
3. ទឹកស្អាត និងអនាម័យ
4. មណ្ឌលសុខភាព
5. សន្តិសុខសង្គម
6. អាហាររូបត្ថម្ភ/ចំណីអាហារ
7. គាំទ្រជនរងគ្រោះ
8. ទីកន្លែង/អគារសាធារណៈ
9. ផ្សេងៗ
10. មិនឆ្លើយ

E6. តើអ្នកបាន<u>បោះឆ្នោតឃុំ/សង្កាត់</u>ឆ្នាំ២០១៧ដែរឬទេ?

1. បាទ/ចាស (រំលងទៅ E8)
2. ទេ
3. មិនមានចម្លើយ (រំលងទៅ E10)

E7. ប្រសិនបើមិនបានបោះឆ្នោត មកពីមូលហេតុអ្វី? (រំលងទៅ E10)

1. ជាប់រវល់
2. ទៅការិយាល័យបោះឆ្នោតមិនបាន
3. មិនចាប់អារម្មណ៍នយោបាយថ្នាក់ក្រោមជាតិ
4. មិនចាប់អារម្មណ៍រឿងនយោបាយ
5. មិនទាន់គ្រប់អាយុ
6. គ្មានព័ត៌មានគ្រប់គ្រាន់អំពីការបោះឆ្នោត
7. មិនមានឯកសារអត្តសញ្ញាណ
8. មិនឆ្លើយ

E8. នៅពេលបោះឆ្នោតឃុំសង្កាត់ ហេតុអ្វីអ្នកបោះឲ្យគណបក្សហ្នឹង?

1. គណបក្ស (គោលនយោបាយ, ប្រធានគណបក្ស។ល។)
2. បេក្ខជនឈរឈ្មោះ
3. កត្តាផ្សេងៗ (គ្រួសារ, មិត្តភក្តិ, មិត្តរួមការងារ។ល។)

4. មិនដឹង / ចេះតែបោះ
5. មិនឆ្លើយ

E9. ក្នុងការបោះឆ្នោតឃុំខែមិថុនា ឆ្នាំ២០១៧ តើបានបោះឆ្នោតឲ្យគណបក្សដដែលដូចនៅពេលបោះឆ្នោតឃុំ ឆ្នាំ២០១២ ដែរឬទេ?

1. បាទ/ចាស
2. ទេ
3. មិនធ្លាប់
4. មិនឆ្លើយ

E10. តើអ្នកយល់ស្របនឹងប្រយោគខាងក្រោមដែរឬទេ?ប្រទេសយើងដើរលើផ្លូវត្រូវ

1. យល់ស្រប
2. មិនយល់ស្រប
3. មិនឆ្លើយ

E11. តើអ្នកយល់ស្របនឹងប្រយោគខាងក្រោមដែរឬទេ? រដ្ឋាភិបាលបានជួយប្រជាជន ក្រីក្របានគ្រប់គ្រាន់

1. យល់ស្រប
2. មិនយល់ស្រប
3. មិនឆ្លើយ

E12.តើអ្នកយល់ស្របនឹងប្រយោគខាងក្រោមដែរឬទេ?រដ្ឋាភិបាលបានជួយគ្រប់គ្រាន់ដល់យុវជនឲ្យមានការងារធ្វើ

1. យល់ស្រប
2. មិនយល់ស្រប
3. មិនឆ្លើយ

E13. តើអ្នកយល់ស្របនឹងការលើកឡើងដូចខាងក្រោមដែរឬទេ? រដ្ឋាភិបាលបានបំពេញតួនាទីគ្រប់គ្រាន់ក្នុងការរក្សាស្ថិរភាពនយោបាយ

1. យល់ស្រប
2. មិនយល់ស្រប
3. មិនឆ្លើយ

E14. តើអ្នកយល់ស្របនឹងប្រយោគខាងក្រោមដែរឬទេ? ប្រជាជនភាគច្រើននៅកម្ពុជាមានជីវភាពប្រសើរជាងប្រាំឆ្នាំមុន

1. យល់ស្រប
2. មិនយល់ស្រប
3. មិនឆ្លើយ

E15. តើអ្នកបានដឹង និងចាប់អារម្មណ៍ដែរឬទេ នឹងព្រឹត្តិការណ៍ដូចខាងក្រោមៈ (សំណួរមានចម្លើយលើសពី 1)

1. ការប្រារព្ធកម្មវិធីអបអរសាទរប្រាសាទសំបូរព្រៃគុកជាបិតិកភណ្ឌពិភពលោក
2. កសិករធ្វើបាតុកម្មពីការធ្លាក់ចុះតម្លៃស្រូវ
3. ការកាត់ទោសនិងដោះលែងបុគ្គលិកអាដហុក៥នាក់
4. ការចរចាប្រាក់ឈ្នួលអប្បបរិមាកម្មករកាត់ដេរ
5. សន្ទរកថារបស់នាយករដ្ឋមន្ត្រី
6. ការបោះឆ្នោតឃុំសង្កាត់
7. វិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ
8. ការផ្លាស់ប្តូរអភិបាលរាជធានីនិងអភិបាលខេត្ត
9. ការអនុវត្តការងាររបស់ក្រុមប្រឹក្សាឃុំ/សង្កាត់ថ្មី
10. មិនឆ្លើយ

E16.តើស្ថាប័នរដ្ឋណាខ្លះដែលអ្នកពេញចិត្តជាងគេជាមួយនឹងការអនុវត្តការងាររបស់ពួកគេ?(បង្ហាញរូបភាព)

1. អប់រំ
2. សុខាភិបាល
3. ហេដ្ឋារចនាសម្ព័ន្ធ

4. ប៉ូលីស
5. តុលាការ
6. រដ្ឋសភា

E17. តើអ្នកបានចូលរួមបោះឆ្នោតជាតិឆ្នាំ2013 ដែរឬទេ?
1. បាទ/ចាស
2. ទេ (រំលងទៅ E19)
3. មិនឆ្លើយ

E18. នៅពេលបោះឆ្នោតថ្នាក់ជាតិ ហេតុអ្វីអ្នកបោះឆ្នោតគាំទ្រគណបក្សហ្នឹង?
1. គណបក្ស (គោលនយោបាយ, ប្រធានគណបក្ស។ល។)
2. បេក្ខជនឈរឈ្មោះ
3. កត្តាផ្សេងៗ (គ្រួសារ, មិត្តភក្តិ, មិត្តរួមការងារ។ល។)
4. មិនដឹង / ចេះតែបោះ
5. មិនឆ្លើយ

E19. នៅពេលបោះឆ្នោតថ្នាក់ជាតិកន្លងមក តើអ្នកតែងតែបោះឆ្នោតឲ្យគណបក្សដដែលមែនឬទេ?
1. បាទ\ចាស
2. ទេ
3. មិនធ្លាប់
4. មិនឆ្លើយ

E20. តើអ្នកអាចរៀបរាប់ឈ្មោះអ្នកនយោបាយ 3នាក់បានទេ? (ចូរស្តាប់ការរៀបរាប់ចម្លើយ)
1. អាចរៀបរាប់បាន
2. រៀបរាប់បានខ្លះ
3. មិនដឹង
4. មិនឆ្លើយ

E21. តើស្ថាប័នអំណាចកំពូលទាំងបីមានអ្វីខ្លះ? (ចូរស្តាប់ការរៀបរាប់ចម្លើយ)
1. ចម្លើយត្រឹមត្រូវ
2. ចម្លើយត្រូវខ្លះ
3. ចម្លើយមិនត្រូវ
4. មិនដឹងចម្លើយ
5. មិនឆ្លើយ

E22. តើអ្នកយល់ស្របជាមួយនឹងការលើកឡើងដូចខាងក្រោមដែរឬទេ? ខ្ញុំមានកាតព្វកិច្ចទៅបោះឆ្នោត
1. យល់ស្រប
2. មិនយល់ស្រប
3. មិនឆ្លើយ

E23. តើអ្នកយល់ស្របជាមួយនឹងការលើកឡើងដូចខាងក្រោមដែរឬទេ? សន្លឹកឆ្នោតរបស់ខ្ញុំអាចមានឥទ្ធិពលដល់អនាគតប្រទេសជាតិរបស់ខ្ញុំ
1. យល់ស្រប
2. មិនយល់ស្រប
3. មិនឆ្លើយ

E24. តើអ្នកមានគម្រោងទៅបោះឆ្នោតជាតិឆ្នាំ2018 ដែរឬទេ?
1. បាទ\ចាស
2. ទេ (រំលងទៅសំណួរ E25)
3. មិនច្បាស់
4. មិនឆ្លើយ

E25. តើនរណាដែលអ្នកគិតថាមានឥទ្ធិពលលើទស្សនៈនយោបាយរបស់អ្នក? (បង្ហាញរូបភាព)
1. សាសនា
2. អ្នកនយោបាយ (ថ្នាក់ជាតិ មូលដ្ឋាន...)
3. អ្នកធ្វើការជាមួយគ្នា/មិត្តភក្តិ

4. គ្រូបង្រៀន/អប់រំ
5. ប្រព័ន្ធផ្សព្វផ្សាយ
6. គ្រួសារ/សាច់ញាតិ

**F. ប្រព័ន្ធផ្សព្វផ្សាយ**

F1. តើអ្នកប្រើប្រាស់អ៊ិនធើណិតដែរឬទេ?
1. បាទ\ចាស
2. ទេ (រំលងទៅ F7)
3. មិនឆ្លើយ

F2. តើអ្នកប្រើអ៊ិនធើណិតតាមមធ្យោបាយណា? (សំណួរមានចម្លើយលើសពីមួយ)
1. ទូរស័ព្ទដៃ
2. កុំព្យូទ័រផ្ទាល់ខ្លួន
3. កុំព្យូទ័រនៅកន្លែងធ្វើការ
4. កុំព្យូទ័រនៅទីសាធារណៈ(សាលា)
5. មិនឆ្លើយ

F3. ជាទូទៅ អ្នកចំណាយពេលប្រើអ៊ិនធើណិតប៉ុន្មានម៉ោងក្នុងមួយថ្ងៃ?...............................

F4. តើអ្នកប្រើអ៊ិនធើណិតសម្រាប់គោលបំណងអ្វីខ្លះ?(អាចមានចម្លើយលើសពី1)
1. ទំនាក់ទំនងក្នុងគ្រួសារ និងបងប្អូន
2. ទំនាក់ទំនងជាមួយមិត្តភក្តិ
3. ស្តាប់ភ្លេង និងមើលវីដេអូ
4. អានព័ត៌មានទូទៅ និងព័ត៌មាននយោបាយ
5. រកឯកសារសិក្សា
6. រកព៌តមានទាក់ទងនឹងជំនាញថ្មីៗ
7. ការងារ/អាជីវកម្ម
8. មិនឆ្លើយ

F5. តើអ្នកយល់ស្របនឹងប្រយោគខាងក្រោមដែរឬទេ? <u>មានការបារម្ភក្នុងការស្វែងរកព័ត៌មាននយោបាយក្នុងអ៊ិនធើណិត</u>
1. យល់ស្រប
2. មិនយល់ស្រប
3. មិនឆ្លើយ

F6. តើអ្នកយល់ស្របនឹងប្រយោគខាងក្រោមដែរឬទេ? <u>មានការបារម្ភក្នុងការចែកចាយបញ្ចេញទស្សនៈនយោបាយនៅក្នុងអ៊ិនធើណិត</u>
1. យល់ស្រប
2. មិនយល់ស្រប
3. មិនឆ្លើយ

F7. តើអ្នកមានរបស់ខាងក្រោមនេះដែរឬទេ? (អាចមានចម្លើយលើសពី 1)
1. ទូរស័ព្ទដៃ
2. ទូរស័ព្ទទំនើប
3. កុំព្យូទ័រ
4. ទូរទស្សន៍
5. វិទ្យុ
6. មិនមាន
7. មិនឆ្លើយ

F8. ជាទូទៅ អ្នកចំណាយពេលមើលទូរទស្សន៍ប៉ុន្មានម៉ោងក្នុងមួយថ្ងៃ?...........................

F9. ជាទូទៅ អ្នកចំណាយពេលអានសារព័ត៌មាន (បោះពុម្ព) ប៉ុន្មានម៉ោងក្នុងមួយថ្ងៃ?..............................

F10. តើអ្នកទទួលព័ត៌មាននយោបាយពីប្រភពណាខ្លះ? (អាចមានចម្លើយលើសពី1)

1. ការសែត
2. អ៊ិនធើណិត
3. ទូរទស្សន៍
4. វិទ្យុ
5. មិត្តភក្តិ
6. គ្រួសារ/សាច់ញាតិ
7. អ្នកជិតខាង
8. អ្នកធ្វើការជាមួយគ្នា
9. អាជ្ញាធរ
10. អង្គការសង្គមស៊ីវិល
11. មិនបានទទួលព័ត៌មាននយោបាយទេ
12. មិនឆ្លើយ

F11. តើអ្នកចែកចាយព័ត៌មាននយោបាយដូចម្តេចខ្លះ? (អាចមានចម្លើយលើសពី 1)

1. តាមរយៈអ៊ិនធើណិត ជាមួយមនុស្សជិតស្និត
2. តាមរយៈអ៊ិនធើណិត ជាមួយមនុស្សទូទៅ
3. ជាមួយមិត្តភក្តិ
4. ជាមួយគ្រួសារ/សាច់ញាតិ
5. ជាមួយអ្នកធ្វើការជាមួយគ្នា
6. ជាមួយអ្នកជិតខាង
7. មិនបានចែកចាយព័តមាននយោបាយទេ
8. មិនឆ្លើយ

F12. តើអ្នកយល់ស្របនឹងប្រយោគខាងក្រោមដែរឬទេ? មានការបារម្ភក្នុងការបញ្ចេញទស្សនៈនយោបាយ

1. យល់ស្រប
2. មិនយល់ស្រប
3. មិនឆ្លើយ

## បញ្ជីឯកសារពិភាក្សារបស់វិទ្យាស្ថាន CDRI

១១៣. *អៀ សុធី ស៊ឹម សុខចេង ឈឹម ឈុន និង ខៀវ ភិរម្យ* (មករា ២០១៨). *Rice Policy Study: Implications of Rice Policy Changes in Vietnam for Cambodia's Rice Policy and Rice Producers in South-Eastern Cambodia*

១១២. *រ័ត្ន វឌ្ឍនា* Abdelkrim Araarz, *ស្រ៊ី បុប្ផារ័ត្ន និង ផាន់ដាលីស* (មីនា ២០១៧). *The Dynamics of Microcredit Borrowings in Cambodia.* ជាភាសាអង់គ្លេស *Published online by PEP at www.pep-net.org/dynamics-microcredit-borrowings-cambodia-march-2017*

១១១. *អៀ សុធី ស៊ឹម សុខចេង និងខៀវ ភារម្យ* (មីនា ២០១៦). *Cambodia Macroeconomic Impacts of Public Consumption on Education – A Computable General Equilibrium Approach.* ជាភាសាអង់គ្លេស *Published online by PEP at www.pep-net.org/sites/pep-net.org/files/typo3doc/pdf/files_events/2016_Manila_conference/final_report/MPIA-12804-Conference_Version.pdf*

១១០. *វង់ ម៉ាន់* (ធ្នូ ២០១៦). *Progress and Challenges of Deconcentration in Cambodia: The Case of Urban Solid Waste Management.* ជាភាសាអង់គ្លេស តម្លៃ ២,០០ដុល្លារ។

១០៩. *សំ ស្រីមុំ គី ចាន់និមល* *Keum Kyungwoo, សារុំ ម៉ូលីដែត និង សុខ រក្សា* (ធ្នូ ២០១៦). *Common Pool Resources and Climate Change Adaptation: Community-based Natural Resource Management in Cambodia.* ជាភាសាអង់គ្លេស តម្លៃ ៣,០០ដុល្លារ។

១០៨. *លី តឹម* (មករា ២០១៦). *Leadership Pathways for Local Women: Case Studies of Three Communes in Cambodia.* ជាភាសាអង់គ្លេស តម្លៃ ៣,០០ដុល្លារ។

១០៧. *ឈឹម ឈន់ ប៊ុត ប៉ូរ៉ា និង អៀ សុធី* (កញ្ញា ២០១៥). *Effect of Labour Movement on Agricultural Mechanisation in Cambodia.* ជាភាសាអង់គ្លេស តម្លៃ ២,៥០ដុល្លារ។

១០៦. *ឈឹម ឈន់ តុង គឹមស៊ុន, Ge Yu, Timothy Ensor and Barbara McPake* (កញ្ញា ២០១៥). *Impact of Health Financing Policies on Household Spending: Evidence from Cambodia Socio-Economic Surveys 2004 and 2009.* ជាភាសាអង់គ្លេស មាននៅក្នុងគេហទំព័រ https://cdri.org.kh។

១០៥. *រ័ត្ន វឌ្ឍនា និង លន់ពិដ* (សីហា ២០១៥). *សុខាភិបាល និងការអប់រំ នៅប្រទេសកម្ពុជា៖ គោលនយោបាយ ស្ថាប័ន និងការអនុវត្ត* (*Health and Education in Cambodia: Policies, Institutions and Practices*) ជាភាសាអង់គ្លេស មាននៅក្នុងគេហទំព័រ https://cdri.org.kh។

១០៤. *ស៊ុំ ស្រីមុំ និង ខៀវ ភារម្យ (សីហា ២០១៥). Contract Farming in Cambodia: Different Models, Policy and Practice.* ជាភាសាអង់គ្លេស តម្លៃ ៣,០០ដុល្លារ។

១០៣. *ឈឹម ឈន់ តុង គឹមស៊ុន, Ge Yu, Timothy Ensor and Barbara McPake (មិថុនា ២០១៥). Catastrophic Payments and Poverty in Cambodia: Evidence from Cambodia Socio-Economic Surveys 2004, 2007, 2009, 2010 and 2011.* ជាភាសាអង់គ្លេស តម្លៃ ២,០០ដុល្លារ។

១០២. *អេង នេត្រា វង់ ម៉ាន់ និង ហ៊ិត ណារី (មិថុនា ២០១៥). Social Accountability in Service Delivery in Cambodia* ជាភាសាអង់គ្លេស តម្លៃ ៣,០០ដុល្លារ។

១០១. *អ៊ូ ស៊ីវហួច (មេសា ២០១៥). A Rights-Based Approach to Development: A Cambodian Perspective.* ជាភាសាអង់គ្លេស តម្លៃ ២,០០ដុល្លារ។

១០០. សំ ស្រីមុំ ជាមួយ អ៊ុច ឈួង *(មីនា ២០១៥).* ការអនុវត្ត និងចន្លោះខ្វះខាតផ្នែកបច្ចេកវិទ្យាកសិកម្ម ក្នុងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ (*Agricultural Technological Practices and Gaps for Climate Change Adaptation*) ជាភាសាអង់គ្លេស តម្លៃ ២,៥០ដុល្លារ ភាសាខ្មែរ តម្លៃ ១០.០០០រៀល។

៩៩. ផៃ សុខចេង និង តុង គឹមស៊ុន (ធ្នូ ២០១៤) *Public Spending on Education, Health and Infrastucture and Its Inclusiveness in Cambodia: Benefit Incidence Analysis* ជាភាសាអង់គ្លេស តម្លៃ ២,៥០ដុល្លារ។

៩៨. Srinivasa MADHUR (ធ្នូ ២០១៥) *Cambodia's Skill Gap: An Anatomy of Issue and Policy Options* ជាភាសាអង់គ្លេស តម្លៃ ៣,០០ដុល្លារ ភាសាខ្មែរ តម្លៃ ១០.០០០រៀល។

៩៧. គឹម សួ, ចែម ផល្លា, សូ សុវណ្ណារិទ្ធ, គឹម ស៊ាន ស៊ូម៉ាត្រា, ប៊ិច សុខេម (សីហា ២០១៤) *Methods and Tools Applied for Climate Change Vulnerability and Adaptation Assessment in Cambodia's Tonle Sap Basin* ជាភាសាអង់គ្លេស តម្លៃ ៣,០០ដុល្លារ។

៩៦. គឹម ស៊ាន ស៊ូម៉ាត្រា និង ហួត ណារី (សីហា ២០១៤), *Cambodian State: Developmental, Neoliberal? A Case Study of the Rubber Sector* ជាភាសាអង់គ្លេស តម្លៃ ២,០០ដុល្លារ។

៩៥. ថេង វុទ្ធី, កែវ សុជាតិ, នូ កែវសុទ្ធា, ស៊ុំ ស្រីមុំ និង ខៀវ ភិរម្យ (សីហា ២០១៤), *Impact of Farmer Organisations on Food Security: The Case of Rural Cambodia* ជាភាសាអង់គ្លេស តម្លៃ ៣,០០ដុល្លារ។

៩៣. ហេង សីហា, វង់ ម៉ាន់, និង ឈាត ស្រ៊ាង ដោយមានជំនួយពី ឈួន ណារ៉េត (កក្កដា ២០១៤), *The Enduring Gap: Decentralisation Reform and Youth Participation in Local Rural Governance* ជាភាសាអង់គ្លេស តម្លៃ ២,៥០ដុល្លារ។

៩៣. ណាំង ភិរុណ, សំ ស្រីមុំ, លន់ ពេជ្រតារា (មិថុនា ២០១៤), *Adaptation Capacity of Rural People in the Main Agro-Ecological Zones in Cambodia* ជាភាសាអង់គ្លេស តម្លៃ ២,០០ដុល្លារ។

៩២. ផាន់ ដាលីស (មិថុនា២០១៤) *Links between Employment and Poverty in Cambodia* ជាភាសាអង់គ្លេស តម្លៃ ២,០០ដុល្លារ។

៩១. ថេង វុទ្ធី, ខៀវ ភិរម្យ និង ផុន ដារី (មេសា ២០១៤), *Development of the Fertiliser Industry in Cambodia: Structure of the Market, Challenges in the Demand and Supply Sidesand the Way Forward* ជាភាសាអង់គ្លេស តម្លៃ ២,០០ដុល្លារ។

៩០. ការបោះពុម្ពផ្សាយរបស់ CDRI (មករា ២០១៤), *ASEAN 2030: Growing Together for Economic Prosperity–the Challenges (Cambodia Background Paper)* ជាភាសាអង់គ្លេស តម្លៃ ១,៥០ដុល្លារ។

៨៩. ណាំង ភិរុណ និង អ៊ូច ឈួង (មករា ២០១៤), *Gender and Water Governance: Women's Role in Irrigation Management and Development in the Context of Climate Change* ជាភាសាអង់គ្លេស តម្លៃ ២,៥០ដុល្លារ។

៨៨. ឈាត ស្រ៊ាង (ធ្នូ ២០១៣), *Impact of Decentralisation on Cambodia's Urban Governance* ជាភាសាអង់គ្លេស តម្លៃ ២,៥០ដុល្លារ។

៨៧. គឹម សេតារា និង Joakim Öjendal ដោយមានជំនួយពី ឈួន ណារ៉េត (វិច្ឆិកា 2013), *Gatekeepers in Local Politics: Political Parties in Cambodia and their Gender Policy* ជាភាសាអង់គ្លេស តម្លៃ ២,៥០ដុល្លារ។

៨៦. សែន វិចិត្រ, រស់ សុវាចា និង ហៀង ធីរ៉ាភមរី (តុលា ២០១៣), *Anatomy of Higher Education Governance in Cambodia* ជាភាសាអង់គ្លេស តម្លៃ ២,០០ដុល្លារ។

៨៥. អ៊ូ ស៊ីវហួច និង គឹម សេតារា (សីហា ២០១៣), *20 Years' Strengthening of Cambodian Civil Society: Time for Reflection* ជាភាសាអង់គ្លេស តម្លៃ ២,០០ដុល្លារ។

៨៤. អ៊ូ ស៊ីវហួច (សីហា ២០១៣), *Sub-National Civil Society in Cambodia: A Gramscian Perspective* ជាភាសាអង់គ្លេស តម្លៃ ២,០០ដុល្លារ។

៨៣. តុង គឹមស៊ុន, លន់ ពិដេ និង ស្រ៊ី បុប្ផារ័ត្ន ដោយមានជំនួយពី ប៊ុន ដូរីណា (សីហា ២០១៣) *Levels and Sources of Household Income in Rural Cambodia 2012* មានក្នុងគេហទំព័រវិទ្យាស្ថាន CDRI។

៨២. ណាំង ភិរុណ (កក្កដា ២០១៣), *Climate Change Adaptation and Livelihoods in Inclusive Growth: A Review of Climate Change Impacts and Adaptive Capacity in Cambodia* ជាភាសាអង់គ្លេស តម្លៃ ២,០០ដុល្លារ។

៨១. ហ៊ីង វុត្ថា (មិថុនា), *Leveraging Trade for Economic Growth in Cambodia* ជាភាសាអង់គ្លេស តម្លៃ ១,៥០ ដុល្លារ។

៨០. សាំង ច័ន្ទហង្ស (មីនា ២០១៣), *Binding Constraints on Economic Growth in Cambodia: A Growth Diagnostic Approach មានក្នុងគេហទំព័រវិទ្យាស្ថាន CDRI។*

៧៩. លន់ ពិដេរ (មីនា ២០១៣), *The Role of Rural Credit during the Global Financial Crisis: Evidence From Nine Villages in Cambodia មានក្នុងគេហទំព័រវិទ្យាស្ថាន CDRI។*

៧៨. តុង គឹមស៊ុន និង ផៃ សុខចេង (មីនា ២០១៣), *The Role of Income Diversification during the Global Financial Crisis: Evidence from Nine Villages in Cambodia មានក្នុងគេហទំព័រវិទ្យាស្ថាន CDRI។*

៧៧. សាំង ច័ន្ទហង្ស (មីនា ២០១៣), *Household Vulnerability to Global Financial Crisis and Their Risk Coping Strategies: Evidence from Nine Rural Villages in Cambodia មានក្នុងគេហទំព័រវិទ្យាស្ថាន CDRI។*

៧៦. ហ៊ីង វុត្ថា (មីនា ២០១៣), *Impact of the Global Financial Crisis on the Rural Labour Market: Evidence from Nine Villages in Cambodia មានក្នុងគេហទំព័រវិទ្យាស្ថាន CDRI។*

៧៥. តុង គឹមស៊ុន (មីនា ២០១៣), *Impact of the Global Financial Crisis on Poverty: Evidence from Nine Villages in Cambodia មានក្នុងគេហទំព័រវិទ្យាស្ថាន CDRI។*

៧៤. Ngin Chanrith (March 2013), *Impact of the Global Financial Crisis on Employment in SMEs in Cambodia មានក្នុងគេហទំព័រវិទ្យាស្ថាន CDRI។*

៧៣. Hay Sovuthea (April 2013), *Government Response to Inflation Crisis and Global Financial Crisis មានក្នុងគេហទំព័រវិទ្យាស្ថាន CDRI។*

៧២. ហែម សុចិត្ត (មេសា ២០១៣), *Impact of the Global Financial Crisis on Cambodian Economy at Macro and Sectoral Levels មានក្នុងគេហទំព័រវិទ្យាស្ថាន CDRI។*

៧១. គឹម សេតារា, Joakim Öjendal, ឈួន ណារ៉េត និង លី តឹម (ធ្នូ ២០១៣) *ការវិភាគខាងយេនឌ័រលើកំណែទម្រង់វិមជ្ឈការនៅកម្ពុជា* ជាភាសាខ្មែរ តម្លៃ ៨.០០០ រៀល អង់គ្លេស តម្លៃ ២,៥០ដុល្លារ។

៧០. ហ៊ីង វុត្ថា, សាំង ច័ន្ទហង្ស និង យៀង សុធី (សីហា ២០១២), *Baseline Survey for Socioeconomic Impact Assessment: Greater Mekong Sub-region Transmission Project* មានក្នុងគេហទំព័រវិទ្យាស្ថាន CDRI។

៦៩. *ការបោះពុម្ពរបស់ CDRI (មីនា ២០១២), Understanding Poverty Dynamics: Evidence from Nine Villages in Cambodia ជាភាសាអង់គ្លេស តម្លៃ ៤,៥០ដុល្លារ។*

៦៨. រ័ត្ន វឌ្ឍនា *(មីនា ២០១២)*, *Sectoral Composition of China's Economic Growth, Poverty Reduction and Inequality: Development and Policy Implications for Cambodia ជាភាសាអង់គ្លេស តម្លៃ ២,៥០ដុល្លារ។*

៦៧. Keith Carpenter ដោយមានជំនួយពី ប៉ុន ដូរីណា (*កុម្ភៈ ២០១២*), *A Basic Consumer Price Index for Cambodia 1993–2009 ជាភាសាអង់គ្លេស តម្លៃ ៣,០០ដុល្លារ។*

៦៦. តុង គឹមស៊ុន (*កុម្ភៈ ២០១២*), *Analysing Chronic Poverty in Rural Cambodia Evidence from Panel Data ជាភាសាអង់គ្លេស តម្លៃ ២,០០ដុល្លារ។*

៦៥. រស់ បានសុខ, ណាំង ភិរុណ និង ឈឹម ឈុន (តុលា ២០១៣), *Agricultural Development and Climate Change: The Case of Cambodia ជាភាសាអង់គ្លេស តម្លៃ ៣,០០ ដុល្លារ។*

៦៤. តុង គឹមស៊ុន និងស្រ៊ី បុប្ផារត្ន (វិច្ឆិកា ២០១១), *Poverty and Evironment Links: The Case of Rural Cambodia* ជាភាសាអង់គ្លេស តម្លៃ ២,៥០ដុល្លារ។

៦៣. ហេង សីហា, គឹម សេតារា និងសូ សុខប៊ុនធឿន(តុលា ២០១១), *Decentralised Governance in Hybrid Polity: Localisation of Decentralisation Reform in Cambodia* ជាភាសាអង់គ្លេស តម្លៃ ៣,០០ដុល្លារ។

៦២. ជា ជូ, ណាំង ភិរុណ, Isabelle Whitehead, Phillip Hirsch និង Anna Thompson (តុលា ២០១១), *Decentralised Governance of Irrigation Water in Cambodia: Matching Principles to Local Realities* ជាភាសាអង់គ្លេស តម្លៃ ២,៥០ដុល្លារ។

៦១. *រស់ បណ្ណេត, លី តឹម និង Anna Thompson (កញ្ញា ២០១១), Catchment Governance and Cooperation Dilemmas: A Case Study from Cambodia ជាភាសាអង់គ្លេស តម្លៃ ៣,០០ដុល្លារ។*

៦០. *ការបោះពុម្ពរបស់ CDRI (តុលា ២០១១), Poverty Dynamics Study: Evidence from Nine Villages in Cambodia ជាភាសាអង់គ្លេស តម្លៃ ៣,០០ដុល្លារ។*

៥៩. *ចែម ផល្លា, Philip Hirsch និង សុមេធ ប៉ារ៉ាឌី (កញ្ញា ២០១១), Hydrological Analysis in Support of Irrigation Management: A Case Study of Stung Chrey Bak Catchment, Cambodia* ជាភាសាអង់គ្លេស តម្លៃ ២,៥០ដុល្លារ។

៥៨. ហ៊ីង វុត្ថា លន់ ពិដេ និង ផាន់ ដាលីស (តុលា ២០១១) *ទេសន្តរប្រវេសន៍មិនស្របច្បាប់ពីកម្ពុជា៖ លក្ខណៈសម្គាល់ បញ្ហាប្រឈម និងការរៀបចំច្បាប់គ្រប់គ្រង* ជាភាសាខ្មែរ តម្លៃ ១០.០០០ រៀល អង់គ្លេស តម្លៃ ២,៥០ដុល្លារ។

៥៧. តុង គឹមស៊ុន ហែម សុចិត្ត និង Paulo Santos (កក្កដា ២០១១), *The Impact of Irrigation on Household Assets* ជាភាសាអង់គ្លេស តម្លៃ ២,០០ដុល្លារ។

៥៦. តុង គឹមស៊ុន ហែម សុចិត្ត និង Paulo Santos (កក្កដា ២០១១), *What Limits Agricultural Intensification in Cambodia? The Role of Emigration, Agricultural Extension Services and Credit Constraints* ជាភាសាអង់គ្លេស តម្លៃ ២,៥០ដុល្លារ។

៥៥. កឹម សុធន ឈឹម ឈន់ ចេង វុទ្ធី និង សូ សុវណ្ណារិទ្ធ (កក្កដា ២០១១), *Policy Coherence in Agricultural and Rural Development: Cambodia* ជាភាសាអង់គ្លេស តម្លៃ ៣,០០ដុល្លារ។

៥៤. ណាំង ភិរុណ ខៀវ ដារ៉ាវី, Philip HIRSCH និង Isabelle WHITEHEAD (កក្កដា ២០១១), *លើកកម្ពស់អភិបាលកិច្ច ធនធានទឹកនៅកម្ពុជា៖ ការវិភាគអ្នកពាក់ព័ន្ធ* ជាភាសាអង់គ្លេស តម្លៃ ២,៥០ដុល្លារ ភាសាខ្មែរ ១២.០០០រៀល។

៥៣. Chann Sopheak, Nathan Wales and Tim Frewer (August 2011), *An Investigation of Land Cover and Land Use Change in Stung Chrey Bak Catchment, Cambodia* ជាភាសាអង់គ្លេស តម្លៃ ៣.០០ដុល្លារ។

៥២. អ៊ួច ច័ន្ទតារ៉ានី សាំង ច័ន្ទហង្ស និង ផាន់ ដាលីស (សីហា ២០១១), *ការវាយតម្លៃផលប៉ះពាល់នៃប្រទេសចិន លើការកាត់បន្ថយភាពក្រីក្រនៅមហាអនុតំបន់ទន្លេមេគង្គ៖ករណីសិក្សាប្រទេសកម្ពុជា* ជាភាសាអង់គ្លេស តម្លៃ ៣,៥០ដុល្លារ ជាភាសាខ្មែរ តម្លៃ ១០.០០០រៀល។

៥១. Christopher Wokker, Paulo Santos, រស់ បានសុខ និង Kate Griffiths (មិថុនា ២០១១), *Irrigation Water Productivity in Cambodian Rice System* ជាភាសាអង់គ្លេស តម្លៃ ២,៥០ដុល្លារ។

៥០. ប៉ក់ គឹមជឿន (ឧសភា ២០១១), *វិមជ្ឈការហិរញ្ញវត្ថុនៅកម្ពុជា៖ ការងារសម្រេចបាន និងជំហានបន្ទាប់* ជាភាសាអង់គ្លេសតម្លៃ ២,៥០ដុល្លារ ជាភាសាខ្មែរ តម្លៃ ៨.០០០រៀល។

៤៩. ចែម ផល្លា និង សុមេធ ប៉ារ៉ាឌី (ឧសភា ២០១១), *ការប្រើប្រាស់ចំណេះដឹងជលសាស្ត្រនៃអាងស្ទឹង និងការចូលរួមរបស់សហគមន៍ដើម្បីលើកកម្ពស់ការធ្វើសេចក្តីសម្រេចចិត្តប្រកបដោយការចូលរួម ស្តីពីការបែងចែកទឹកសម្រាប់ស្រោចស្រព* ជាភាសាអង់គ្លេស តម្លៃ ២,៥០ដុល្លារ ជាភាសាខ្មែរ តម្លៃ ៨.០០០រៀល។

៤៨. ការបោះពុម្ពរបស់CDRI (សីហា 2010), *Empirical Evidence of Irrigation Management in the Tonle Sap Basin: Issues and Challenges* ជាភាសាអង់គ្លេស តម្លៃ ២,៥០ដុល្លារ។

៤៧. ជា ជូ (សីហា 2010), *The Local Governance of Common Pool Resources: The Case of Irrigation Water in Cambodia* ជាភាសាអង់គ្លេស តម្លៃ ២,៥០ដុល្លារ។

៤៦. ការបោះពុម្ពរបស់ CDRI (ធ្នូ 2009), *Agricultural Trade in the Greater Mekong Sub-region: Synthesis of the Case Studies on Cassava and Rubber Production and Trade in GMS Countries* ជាភាសាអង់គ្លេស តម្លៃ ១,៥០ដុល្លារ។

៤៥. ការបោះពុម្ពរបស់ CDRI ( ធ្នូ 2009 ), *Costs and Benefits of Cross-country Labour Migration in the GMS: Synthesis of the Case Studies in Thailand, Cambodia, Laos and Vietnam* ជាភាសាអង់គ្លេស តម្លៃ ១,៥0ដុល្លារ។

៤៤. ច័ន្ទ សុផល (ធ្នូ ២០០៩) *ផលប្រយោជន៍ និងចំណាយនៃទេសន្តរប្រវេសន៍កម្លាំងពលកម្មក្នុងមហាអនុតំបន់មេគង្គ៖ ករណីសិក្សានៅប្រទេសកម្ពុជា* ជាភាសាខ្មែរតម្លៃ ៨,០០០រៀល ជាភាសាអង់គ្លេស តម្លៃ ៣.០០ដុល្លារ។

៤៣. ហ៊ីង វុត្ថា និង បណ្ឌិត ធន់ វឌ្ឍនា (ធ្នូ ២០០៩) *ពាណិជ្ជកម្មកសិកម្មក្នុងមហាអនុតំបន់មេគង្គ៖ ករណីដំឡូងឈើ និងកៅស៊ូនៅកម្ពុជា* (ឯកសារពិភាក្សាលេខ ៤៣) ជាភាសាខ្មែរ តម្លៃ ៦.០០០រៀល ជាភាសាអង់គ្លេស ៣,០០ដុល្លារ។

៤២. ធន់ វិមាលា អ៊ូ ស៊ីវហួច អេង នេត្រា និង លី តឹម ( តុលា 2009 ), *Leadership in Local Politics of Cambodia: A Study of Leaders in Three Communes of Three Provinces* ជាភាសាអង់គ្លេស ៣,០០ដុល្លារ។

៤១. ហ៊ីង វុត្ថា និង Hossein Jalilian ( មេសា ២០០៩ ) *ផលប៉ះពាល់នៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ចិនចំពោះបរិស្ថាននៅតាមបណ្ដាប្រទេសក្នុងមហាអនុតំបន់មេគង្គ (ឯកសារពិភាក្សាលេខ ៤១)* ជាភាសាខ្មែរ តម្លៃ ៨.០០០រៀល ជាភាសាអង់គ្លេស តម្លៃ៣,០០ដុល្លារ។

៤០. អេង នេត្រា និង David Craig ( មីនា ២០០៩ ), *Accountability and Human Resource Management in Decentralised Cambodia* ( Working Paper No. 40 ) ជាភាសាអង់គ្លេស តម្លៃ ៥,០០ដុល្លារ។

៣៩. ហ៊ាង វុទ្ធី និង David Craig, *Accountability and Planning in Decentralised Cambodia* ( Working Paper No. 39 ) ជាភាសាអង់គ្លេស តម្លៃ ៥,០០ដុល្លារ។

៣៨. ប៉ាក់ គឹមជឿន និង David Craig, *Accountability and Public Expenditure Management in Decentralised Cambodia* ( Working Paper No. 38 ) ជាភាសាអង់គ្លេស តម្លៃ ៥,០០ដុល្លារ។

៣៧. ចែម ផល្លា និងអ្នកផ្សេងទៀត ( ឧសភា 2008 ), *Framing Research on Water Resources Management and Governance in Cambodia: A Literature Review* ជាភាសាអង់គ្លេស តម្លៃ ៥,០០ដុល្លារ។

៣៦. លឹម-សុវណ្ណារា ( វិច្ឆិកា ២០០៧ ) *ចំណាកស្រុករបស់យុវជន និងនគរូបនីយកម្ម នៅកម្ពុជា* ( ឯកសារពិភាក្សាលេខ ៣៦ ) ជាភាសាខ្មែរ ៦.០០០រៀល ជាភាសាអង់គ្លេស ៣,៥0ដុល្លារ។

៣៥. គឹម-សេតារា និង Joakim Öjendal ( ឧសភា ២០០៧ ) *Where Decentralisation Meets Democracy: Civil Society, Local Government, and Accountability in Cambodia* (ឯកសារពិភាក្សាលេខ៣៥) ជាភាសាអង់គ្លេស តម្លៃ ៤,00ដុល្លារ។

៣៤. ប៉ាក់-គឹមជឿន ហ៊ាង-វុទ្ធី អេង-នេត្រា អាន-សុវត្ថា គឹម-សេតារា, Jenney Knowles និង David Craig ( មីនា ២០០៧ ) *Accountability and Neo-patrimonialism in Cambodia: A Critical Literature Review* ( ឯកសារពិភាក្សាលេខ៣៤ ) ជាភាសាអង់គ្លេស ៦,00ដុល្លារ។

៣៣. Hansen, Kasper K. និង តុប-នេត ( ធ្នូ ២០០៦ ) *Natural Forest Benefits and Economic Analysis of Natural Forest Conversion in Cambodia* ( Working Paper No. 33 ) ជាភាសាអង់គ្លេស តម្លៃ ៨.០០ដុល្លារ។

៣២. K. A. S. Murshid និង ទួត-សុខផល្លី ( ឧសភា ២០០៥ ) *សេដ្ឋកិច្ចឆ្លងកាត់ព្រំដែនរបស់ ប្រទេសកម្ពុជា៖ ការសិក្សាជំហានដំបូង* ( ឯកសារពិភាក្សាលេខ៣២ ) ជាភាសាខ្មែរ ៨.០០០រៀល ជាភាសាអង់គ្លេស ៥,០០ដុល្លារ។

៣១. Robert Oberndorf ( កក្កដា ២០០៤ ) *សុខដុមនីយកម្មច្បាប់ទាក់ទងនឹងដំណើរការវិមជ្ឈការនៅកម្ពុជា* ( ឯកសារពិភាក្សាលេខ ៣១ ) ជាភាសាខ្មែរ តម្លៃ ៥.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ៦,៥0ដុល្លារ។

៣០. Caroline Hughes និង គឹម-សេតារា ( មិថុនា ២០០៤ ) *ការវិវត្តន៍នៃដំណើរការប្រជាធិបតេយ្យ និងការគ្រប់គ្រងទំនាស់នៅកម្ពុជា៖ ការសិក្សាប្រៀបធៀបការបោះឆ្នោតបីលើកនៅកម្ពុជា* ( ឯកសារពិភាក្សាលេខ ៣០ ) ជាភាសាខ្មែរតម្លៃ ១០.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ១៣,៥0ដុល្លារ។

២៩. យឹម-ជា និង Bruce McKenney ( វិច្ឆិកា ២០០៣ ) *ពាណិជ្ជកម្មត្រីក្នុងស្រុក៖ ករណីសិក្សានៃម៉ាយីទីងត្រីពីបឹងទន្លេសាបទៅក្រុងភ្នំពេញ* ( ឯកសារពិភាក្សាលេខ២៩ ) ជាភាសាខ្មែរ ៥.០០០រៀល ជាភាសាអង់គ្លេស ៥,០០ដុល្លារ។

២៨. ព្រុំ-តុលា និង Bruce McKenney (ធ្នូ ២០០៣) *ការធ្វើពាណិជ្ជកម្មផលព្រៃឈើនៅកម្ពុជា៖ ការប្រឈម ការគំរាមកំហែង និងឱកាសសម្រាប់ពាណិជ្ជកម្មជរទឹក* (ឯកសារពិភាក្សាលេខ២៨) ជាភាសាខ្មែរ ៧.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ១០,០០ដុល្លារ។

២៧. យឹម-ជា និង Bruce McKenney (ធ្នូ ២០០៣) *ការនាំចេញត្រីពីបឹងទន្លេសាបទៅប្រទេសថៃ៖ ការវិភាគលើការរាំងស្ទះពាណិជ្ជកម្ម អភិបាលកិច្ច និងបរិយាកាសសម្រាប់ការលូតលាស់* (ឯកសារពិភាក្សាលេខ២៧) ជាភាសាខ្មែរ តម្លៃ ៧.០០០រៀល ជាភាសាអង់គ្លេស ១០,០០ដុល្លារ។

២៦. Sarthi Acharya គីម-សេតារា ចាប-សុចារិទ្ធ និង មាច-យ៉ាឌី (កញ្ញា ២០០៣) *ការងារក្រៅកសិដ្ឋាន និងការងារមិនមែនកសិកម្ម៖ ទស្សនៈស្ដីពីការបង្កើតការងារនៅកម្ពុជា* (ឯកសារពិភាក្សាលេខ ២៦) ជាភាសាខ្មែរ តម្លៃ ៧.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ៥,០០ដុល្លារ។

២៥. ច័ន្ទ-សុផល និង Sarthi Acharya (ធ្នូ ២០០២) *បញ្ហាប្រឈមចំពោះការចិញ្ចឹមជីវិតនៅ ជនបទ៖ ការសិក្សាលើភូមិចំនួន ៩ នៅកម្ពុជា* (ឯកសារពិភាក្សា លេខ២៥) ជាភាសាខ្មែរ ៨.០០០រៀល ជាភាសាអង់គ្លេស ១០.០០ ដុល្លារ។

២៤. ច័ន្ទ-សុផល គីម-សេតារា និង Sarthi Acharya (ធ្នូ ២០០២) *ដីធ្លី ជីវភាពជនបទ និងសន្តិសុខស្បៀងនៅកម្ពុជា៖ ទស្សនៈបានពីអង្កេតតាមមូលដ្ឋាន* (ឯកសារពិភាក្សាលេខ ២៤) ជាភាសាខ្មែរ តម្លៃ ៦.០០០រៀល ជាអង់គ្លេស តម្លៃ ៧.០០ដុល្លារ។

២៣. Bruce McKenney និងព្រុំ-តុលា (កញ្ញា ២០០២) *ធនធានធម្មជាតិនិងជីវភាពនៅតាមជនបទក្នុងប្រទេសកម្ពុជា៖ ការវាយតម្លៃជាមូលដ្ឋាន* (ឯកសារពិភាក្សាលេខ ២៣) ជាភាសា ខ្មែរ តម្លៃ ១០.០០០រៀល ជាអង់គ្លេស តម្លៃ ១០.០០ដុល្លារ។

២២. ច័ន្ទ-សុផល និង Sarthi Acharya (កក្កដា ២០០២) *ការលក់ដូរដីធ្លីនៅកម្ពុជា៖ ការវិភាគទិន្នន័យនៃការផ្ទេរ និងការលក់ដូរដីធ្លី* (ឯកសារពិភាក្សាលេខ ២២) ជាភាសាខ្មែរ តម្លៃ ៨.០០០រៀល។

២១. Bhargavi Ramamurthy ស៊ិក-បូរ័ក្ស, Per Ronnås និង សុក-ហាច (មីនា ២០០២) ប្រទេសកម្ពុជាឆ្នាំ១៩៩៩-២០០០៖ *ការផ្ដោតលើបញ្ហាដីធ្លី កម្លាំងពលកម្ម និងការចិញ្ចឹមជីវិត នៅជនបទ* (ឯកសារពិភាក្សាលេខ ២១) តម្លៃ ៨.០០០រៀល។

២០. សូ-សុវណ្ណារិទ្ធ រៀល-សុភាព អ៊ុច-ឧទេយ្យ ស៊ី-រត្នមុនី, Brett Ballard និង Sarthi Acharya (មីនា ២០០២) *ការវាយតម្លៃសង្គមពាក់ព័ន្ធនឹងដីធ្លីនៅកម្ពុជា* (ឯកសារពិភាក្សាលេខ ២០) ជាភាសាខ្មែរ តម្លៃ ៨.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ១០,០០ដុល្លារ។

១៩. ច័ន្ទ-សុផល ទេព-សារ៉ាវី និង Sarthi Acharya, (ធ្នូ ២០០១) *ការកាន់កាប់ដីនៅកម្ពុជា៖ ការវិភាគលើទិន្នន័យចុងក្រោយ* (ឯកសារពិភាក្សាលេខ ១៩) ជាភាសាខ្មែរ តម្លៃ ៨.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ១០,០០ដុល្លារ។

១៨. Martin Godfrey, សូ-សុវណ្ណារិទ្ធ ទេព-សារ៉ាវី ប៉ុន-ដូរីណា Claude-Katz, Sarthi-Acharya, ស៊ីសុវត្ថិ-ឌួង-ចាន់តូ និងហ៊ីង ថូរ៉ាក់ស៊ី (តុលា ២០០១) *ការសិក្សាអំពីទីផ្សារពលកម្មនៅកម្ពុជា៖ ការកាត់បន្ថយភាពក្រីក្រ ការលូតលាស់ និងការកែតម្រូវចំពោះវិបត្តិ* (ឯកសារពិភាក្សា លេខ១៨) ជាភាសាខ្មែរ ៨.០០០រៀល ជាភាសាអង់គ្លេស ៧,០០ដុល្លារ។

១៧. ច័ន្ទ-សុផល សូ-សុវណ្ណារិទ្ធ និងប៊ុន-ដូរីណា (មិថុនា ២០០១) *ជំនួយបច្ចេកទេស និងការអភិវឌ្ឍន៍សមត្ថភាព នៅសាលាកសិកម្មព្រែកលៀប* (ឯកសារពិភាក្សាលេខ ១៧) ជាភាសាខ្មែរ តម្លៃ ៨.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ៨,០០ដុល្លារ។

១៦. ស៊ិក បូរ័ក្ស (ធ្នូ ២០០០) *កម្មសិទ្ធិ ការលក់ដូរ និងការប្រមូលផ្តុំដីធ្លីនៅកម្ពុជា៖ ការពិនិត្យ វិភាគដោយគ្រួសៗនូវទិន្នន័យទីពីរ និងទិន្នន័យដើម ដែលបានមកពីអង្កេតថ្មីៗចំនួនបួន* (ឯកសារពិភាក្សាលេខ ១៦) ជាភាសាខ្មែរ តម្លៃ ៨.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ៧,០០ដុល្លារ។

១៥. Toshiyasu Kato ច័ន្ទ-សុផល Jeffrey A. Kaplan, (សីហា ២០០០) *ជំនួយបច្ចេកទេស និងការអភិវឌ្ឍន៍សមត្ថភាពនៅក្នុងសេដ្ឋកិច្ចមួយដែលពឹងផ្អែកលើជំនួយ៖ បទពិសោធន៍កម្ពុជា* (ឯកសារពិភាក្សាលេខ ១៥) ជាភាសាខ្មែរ តម្លៃ ១០.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ១០,០០ដុល្លារ។

១៤. Toshiyasu-Kato, Jeffrey A. Kaplan, ច័ន្ទ-សុផល និង រៀល-សុភាព (សីហា ២០០០) *ប្រទេសកម្ពុជា៖ លើកកម្ពស់អភិបាលកិច្ចសម្រាប់ការអភិវឌ្ឍន៍មាននិរន្តរភាព* (ឯកសារពិភាក្សា លេខ ១៤) ជាភាសាខ្មែរ តម្លៃ ៦.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ៦,០០ដុល្លារ។

១៣. អ៊ិង-ប៊ុនឡេង (សីហា ២០០០) *ការប្រែប្រួលតាមរដូវកាលនៃសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅក្នុងប្រទេសកម្ពុជា* (ឯកសារពិភាក្សាលេខ ១៣) ជាភាសាអង់គ្លេស តម្លៃ ៣,០០ដុល្លារ។

១២. ច័ន្ទ-សុផល Toshiyasu Kato ឡុង-វុទ្ធិសិដ្ឋ ទា-សាវ៉ា សូ-សុវណ្ណារិទ្ធ ហង់-ជួនណារ៉ុន កៅ-គឹមហួន និង ជា-វុធណា (តុលា ១៩៩៩) *ផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុអាស៊ីលើសេដ្ឋកិច្ចអន្តរកាលនៅបណ្តាប្រទេសអាស៊ីអគ្នេយ៍៖ ទស្សនៈកម្ពុជា* (ឯកសារពិគ្រោះលេខ ១២) ជាភាសាខ្មែរ តម្លៃ ៤.៥០០រៀល ជាភាសាអង់គ្លេស តម្លៃ ៤,៥០ដុល្លារ។

១១. ច័ន្ទ-សុផល និង សូ-សុវណ្ណារិទ្ធ (មិថុនា ១៩៩៩) *ចំណាកពលកម្មកម្ពុជាទៅប្រទេសថៃ៖ ការប៉ាន់ស្មានជំហានដំបូង* (ឯកសារពិគ្រោះលេខ ១១) ជាភាសាខ្មែរ តម្លៃ ៣.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ៣,០០ដុល្លារ។១០. Gormna, Siobham, ជាមួយ ប៉ុន-ដូរីណា និង សុខ-ខេង (មិថុនា ១៩៩៩) *បញ្ហាតួនាទីបុរស-ស្ត្រី និងការអភិវឌ្ឍន៍នៅប្រទេសកម្ពុជា៖ ការពិនិត្យមើលជាទូទៅ* (ឯកសារពិភាក្សាលេខ១០) ជាភាសាខ្មែរ តម្លៃ ៤.៥០០រៀល ជាភាសាអង់គ្លេស តម្លៃ ៦,០០ដុល្លារ។

៩. តេង-យូគី ប៉ុន-ដូរីណា សូ-សុវណ្ណារិទ្ធ និង ចន-ម៉ាកឃិនRDU (មេសា ១៩៩៩) *បទពិសោធន៍របស់សកម្មភាពសហគមន៍ដើម្បីអភិវឌ្ឍន៍សង្គមនៃអង្គការយូនីសេហ្វ* (ឯកសារពិភាក្សាលេខ ៩) ជាភាសាខ្មែរ ៤.៥០០រៀល ជាភាសាអង់គ្លេស ៤,៥០ដុល្លារ។

៨. ច័ន្ទ-សុផល Martin-Godfrey, Toshiyasu-Kato, ឡុង-វូ-ពិសិដ្ឋ Nina-Orlova, Per-Ronnås ទា-សាវ៉ា (មករា ១៩៩៩) *ប្រទេសកម្ពុជា៖ បញ្ហាប្រឈមមុខនៃការបង្កើតការងារដែលមានផលិតភាព* (ឯកសារពិភាក្សាលេខ ៨) ជាភាសាខ្មែរ តម្លៃ ៦.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ៩,០០ដុល្លារ។

៧. McAndrew, John P. (ធ្នូ ១៩៩៨) *ការពឹងពាក់គ្នាទៅវិញទៅមកក្នុងយុទ្ធសាស្ត្រចិញ្ចឹមជីវិត គ្រួសារនៅក្នុងភូមិខ្មែរ ពីរ* (ឯកសារពិភាក្សាលេខ ៧) ជាភាសាខ្មែរ តម្លៃ ៧.៥០០រៀល ជាភាសាអង់គ្លេស តម្លៃ ១០,០០ដុល្លារ។

៦. Murshid, K. A. S. (ធ្នូ ១៩៩៨) *សន្តិសុខស្បៀងនៅក្នុងសេដ្ឋកិច្ចអន្តរៈអាស៊ី៖ បទពិសោធន៍ កម្ពុជា* (ឯកសារពិភាក្សាលេខ ៦) ជាភាសាខ្មែរ តម្លៃ ៧.៥០០រៀល ជាភាសាអង់គ្លេស តម្លៃ ៩,០០ដុល្លារ។

៥. Toshiyasu-Kato ច័ន្ទ-សុផល និង ឡុង-វូ-ពិសិដ្ឋ (កញ្ញា ១៩៩៨) *សមាហរណកម្មសេដ្ឋកិច្ច តំបន់សម្រាប់ការអភិវឌ្ឍន៍ជានិរន្តរ៍ក្នុងប្រទេសកម្ពុជា* (ឯកសារពិភាក្សាលេខ ៥) ជាភាសាខ្មែរ តម្លៃ ៩.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ៦,០០ដុល្លារ។

៤. ជឹម-ចរិយា ស្រ៊ុន-ពិធូ សូ-សុវណ្ណារិទ្ធ ចន-ម៉ាកឃិនឌ្រូ ងួន-សុគន្ធា ប៉ុន-ដូរីណា និងរ៉ូប៊ីន-ប៊ិដឺលវ៍ (មិថុនា ១៩៩៨) *ការរៀនសូត្រពីកម្មវិធីអភិវឌ្ឍន៍ជនបទក្នុងប្រទេសកម្ពុជា* (ឯកសារ ពិភាក្សាលេខ ៤) ជាភាសាខ្មែរ តម្លៃ ៩.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ៧,៥០ដុល្លារ។

៣. Kannan, K. P. (មករា ១៩៩៧) *កំណែទំរង់សេដ្ឋកិច្ច កំណែតម្រូវរចនាសម្ព័ន្ធនិងការអភិវឌ្ឍន៍កម្ពុជា* (ឯកសារពិភាក្សាលេខ ៣) ជាភាសាខ្មែរ តម្លៃ ៤.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ៥,០០ដុល្លារ។

២. McAndrew, John P. (មករា ១៩៩៦) *ជំនួយហូរចូលជំនួយស្រពិចស្រពិល៖ ជំនួយសង្គ្រោះ និងអភិវឌ្ឍន៍ទ្វេ និងពហុភាគី ១៩៩២-៩៥* (ឯកសារពិភាក្សាលេខ ២) ជាភាសាខ្មែរ ៤.០០០រៀល ជាភាសាអង់គ្លេស ៥,០០ដុល្លារ។

១. Kannan, K.P. (វិច្ឆិកា ១៩៩៥) *ការកសាងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់សម្រាប់ប្រទេសកម្ពុជា៖ ការពិនិត្យឡើងវិញលើការអនុវត្តន៍នាពេលបច្ចុប្បន្ន និងការលើកមតិកែលម្អ* (ឯកសារពិភាក្សា លេខ ១) ជាភាសាខ្មែរ តម្លៃ ៤.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ៥,០០ដុល្លារ។

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

☞ អគារលេខ 56 ផ្លូវ 315 ខ័ណ្ឌទួលគោក

✉ ប្រអប់សំបុត្រលេខ 622 ភ្នំពេញ កម្ពុជា

☎ (855-23) 881-384/881-701/881-916/883-603/012 867-278

🖷 (855-23) 880-734

អ៊ីមែល៖ cdri@cdri.org.kh

គេហទំព័រ៖ http://www.cdri.org.kh

តម្លៃ ១០.០០០រៀល

9 789996 389115